ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីធ្លី ឃុំអណ្តូងទឹក

## ឆ្នាំ ២០០៩-២០២២

## ស្រុក បូទុមសាគរ ខេត្ត កោះកុង



រៀបចំដោយៈ គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

គាំទ្រដោយៈ ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

មាតិការ

**អារម្ភកថា** ........ 1

**សេចក្តីផ្តើម** ........ 2

**គោលបំណង** ........ 3

**ប្រវត្តិនៃឃុំអណ្តូងទឹក** ........ 4

**ជំពូក ១ : ព័ត៌មាន និង ទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ........ 5

**១.១. ស្ថានភាពទូទៅ** ........ 5

១.១.១. ទីតាំងរដ្ឋបាល ........ 6

១.១.២. ប្រជាសាស្ត្រ ........ 7

១.១.៣. ភាពគ្មានដីធ្លី ........ 8

១.១.៤. ស្ថានភាពសេដ្ឋកិច្ច ........ 9

១.១.៥. ស្ថានភាពរបបរំ និងសិក្សាធិការ ........ 10

១.១.៦. ស្ថានភាពសុខាភិបាល ........ 12

១.១.៦.១. ផ្នែកសុខាភិបាល ........ 12

១.១.៦.២. ស្ថានភាពប្រើប្រាស់ទឹកស្អាត និង អនាម័យ ........ 13

**១.២. ស្ថានភាពភូមិសាស្ត្រ :** ........ 14

១.២.១ ទីតាំងភូមិសាស្ត្រ : ........ 14

១.២.២. អាកាសធាតុ : ........ 15

១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន : ........ 16

**១.៣. ស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន :** ........ 17

១.៣.១. ស្ថានភាពនៃការប្រើប្រាស់ដី : ........ 17

១.៣.២. ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី : ........ 18

១.៣.៣. ផលិតកម្មកសិកម្ម : ........ 18

១.៣.៤. ធនធានធម្មជាតិ ........ 21

១.៣.៤.១. ធនធានព្រៃឈើ ........ 21

១.៣.៤.២. ធនធានជលផល ........ 22

១.៣.៥. ធនធានរ៉ែ ........ 23

**១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល :** ........ 23
១.៤.១. ទីផ្សារ និងតំលៃកសិផល អនុផលព្រៃឈើ និងផលនេសាទ ........ 24
១.៤.២. ខ្សែសង្វាក់ និង ចរាចរផលិតផល : ........ 24
១.៤.៣. ឱកាស-ឧបស័គ្គ ........ 24
**ជំពូក ២ : ការវិភាគពីតំរូវការសំរាប់អនាគត ឧបស័គ្គ និងសក្តានុពល** ........ 25
**២.១. តំបន់រសើប** ........ 25
**២.២. ការប្រឈម/ឧបស័គ្គ** ........ 25
**២.៣. កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំអណ្តូងទឹក** ........ 26
**២.៤. តំរូវការសំរាប់អនាគត** ........ 27
២.៤.១ ប្រជាសាស្ត្រ ........ 27
២.៤.១.១. អត្រាកំណើន ........ 27
២.៤.១.២. ការធ្វើចំណោលប្រជាសាស្ត្រ ........ 28
២.៤.២. តំរូវការសំរាប់លំនៅដ្ឋាន ........ 28
២.៤.៣. តំរូវការដីកសិកម្ម ........ 29
២.៤.៤. តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ ........ 30
២.៤.៥. តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ........ 30
២.៤.៥.១. តំរូវការដីសាលារៀន ........ 31
២.៤.៥.២. សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ........ 32
២.៤.៥.៣. ផ្នែកវប្បធម៌ និងសាសនា ........ 33
២.៤.៥.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព ........ 33
**ជំពូក ៣ : ផែនការប្រើប្រាស់ដីអនាគត** ........ 35
**៣.១. ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ........ 35
៣.១.១. ស្ថានភាពដីទូទៅ និងសក្តានុពល ........ 35
៣.១.២. តំរូវការដីតាមប្រភេទ ........ 35
**៣.២. ការបែងចែកដីតាមតំរូវការប្រើប្រាស់** ........ 37
៣.២.១. ការវិភាគអន្តរអំពើ ........ 37
៣.២.២. ផែនទីប្រើប្រាស់ដីពេលអនាគត ........ 38

៣.២.៣. ការបរិយាយការប្រើប្រាស់តាមក្បាលដី....39

៣.២.៣.១. ដីលំនៅដ្ឋាន (បញ្ញត្តិ គោលការណ៍ និងការប្រើប្រាស់ដី)....40

៣.២.៣.២. ដីស្រែវស្សា និងស្រែប្រាំង....40

៣.២.៣.៣. ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព....42

៣.២.៣.៤. ការសាងសង់ស្ពានឆ្លងព្រែក និងទ្វារទឹក....43

៣.២.៣.៥. ការប្រើប្រាស់ផ្លូវថ្នល់....44

៣.២.៣.៦. ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ និង ទីតាំងសាលាថ្មី....45

៣.២.៣.៧. ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន....45

**ឧបសម្ព័ន្ធ ១ : ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន**....47

**ឧបសម្ព័ន្ធ ២ : ស្ថានភាពនៃការគ្រប់គ្រង និង កាន់កាប់ដីបច្ចុប្បន្ន**....53

**ឧបសម្ព័ន្ធ ៣ : បញ្ហាពាក់ព័ន្ធការប្រើប្រាស់ដី(បញ្ហាមូលហេតុ ដំណោះស្រាយ)**....56

**ឧបសម្ព័ន្ធ ៤ : ក្របខណ្ឌនៃការអភិវឌ្ឍន៍ និង ជំរើសនៃការប្រើប្រាស់ដីថ្មីអនាគត**....58

**កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ(តារាង)**....58

**ឧបសម្ព័ន្ធ ៥ : បញ្ជីគំរោង ឬ សកម្មភាពសំខាន់របស់ឃុំក្នុងរយៈពេល ១៥ ឆ្នាំ**....61

**ឧបសម្ព័ន៦ : ផែនទីប្រើប្រាស់ដីលំអិតក្នុងឃុំ**

**ឧបសម្ព័ន៧ : ផែនទីប្រើប្រាស់ដីសាមញ្ញក្នុងឃុំ**

**ឧបសម្ព័ន៨ : ផែនទីប្រើប្រាស់ដីនៅពេលអនាគតក្នុងឃុំឆ្នាំ ២០០៩-២០២២**

# អារម្ភកថា

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំអណ្ដូងទឹក គឺជាការងារដ៏ចាំបាច់សំរាប់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិឱ្យមានប្រសិទ្ធភាព ផលិតភាព និងនិរន្តរភាព ដើម្បីបំរើដល់គោលនយោបាយអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង រួមចំណែកក្នុងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងកាត់បន្ថយភាពក្រីក្រនៅតាមជនបទដែលជីវភាពស្ទើរតែទាំងស្រុងពឹងផ្អែកលើធនធានធម្មជាតិ ។

របាយការណ៍ស្ដីអំពីការរៀបចំផែនការប្រើប្រាស់ដីធ្លីនៅឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង រយៈពេល ១៥ ឆ្នាំ ត្រូវបានរៀបចំឡើងដោយក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីស្រុកបូទុមសាគរ ក្រុមប្រឹក្សាឃុំអណ្ដូងទឹក និង ប្រជាពលរដ្ឋ ដោយមានកិច្ចសហការពីក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីខេត្តកោះកុង (P-LUP) និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដីរបស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/ DFID-NZAID តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ។ ដោយផ្ដល់ឱកាសឱ្យមានការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងឃុំ ដើម្បីដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំរយៈពេល ១៥ ឆ្នាំ ពីឆ្នាំ ២០០៩-២០២២ ។ ការអនុវត្តន៍គំរោង ឬ សកម្មភាពអភិវឌ្ឍន៍ ដើម្បីឆ្លើយតបទៅនឹងតំរូវការពិតប្រាកដរបស់ប្រជាពលរដ្ឋនៅក្នុងឃុំ ដោយរៀបចំគំរោងអាទិភាព និងរៀបចំកម្មវិធី វិនិយោគតាមលំដាប់ប្រចាំឆ្នាំរបស់ឃុំ ។

ក្រុមប្រឹក្សាឃុំអណ្ដូងទឹក និង ក្រុមការងាររៀបចំផែនការប្រើប្រាស់ដីធ្លីរបស់ស្រុកបូទុមសាគរ សូមថ្លែងអំណរគុណដល់ប្រជាពលរដ្ឋក្នុងឃុំដែលបានចូលរួមក្នុងការលើកឡើងអំពីបញ្ហាជាក់ស្ដែងនូវសេចក្ដីត្រូវការរបស់យើងទាំងអស់គ្នាដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ឃុំ ។ ជាមួយគ្នានេះក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមអ្នកសំរបសំរួលរៀបចំផែនការប្រើប្រាស់ដីធ្លីខេត្ត (P-LUP) នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តកោះកុង ដែលបានជួយសំរបសំរួលក្នុងការរៀបចំផែនការនេះឱ្យទទួលបានជោគជ័យ ។

ជាថ្មីម្ដងទៀត ក្នុងនាមក្រុមប្រឹក្សាឃុំសូមអំពាវនាវដល់ក្រសួង មន្ទីរ ស្ថាប័ន អង្គភាព អង្គការមិនមែនរដ្ឋាភិបាលសប្បុរសជន និង ដៃគូអភិវឌ្ឍន៍នានា ជួយគាំទ្រគំរោង ឬសកម្មភាពដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ក្នុងឆ្នាំ (២០០៩-២០២២) របស់ឃុំអណ្ដូងទឹកឱ្យទទួលលទ្ធផលល្អ ។

ធ្វើនៅអណ្ដូងទឹក.ថ្ងៃទី ២៧...ខែ...៧.....ឆ្នាំ ២០០៩

**មេឃុំ**

ហ៊ី ~ តាន់

# សេចក្តីផ្តើម

ការរៀបចំផែនការប្រើប្រាស់ដីក្នុងឃុំអណ្តូងទឹកសំរាប់ឆ្នាំ ២០០៩-២០២២ ដោយយោងអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំអណ្តូងទឹកទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន របស់បុគ្គលឯកជន ។

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំអណ្តូងទឹកនេះមានគោលបំណង :

- ផ្តល់សមត្ថកិច្ចដល់ក្រុមប្រឹក្សាឃុំអណ្តូងទឹករៀបចំផែនការគ្រប់គ្រង និងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព និងកាត់បន្ថយទំនាស់ក្នុងការប្រើប្រាស់ដីធ្លី
- គាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយសំរេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អាជ្ញាធរនានា និងប្រជាពលរដ្ឋនៅក្នុងឃុំអណ្តូងទឹកទាំងមូល
- ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងទៀតមិនឱ្យបាត់បង់គុណភាពដី និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំឱ្យបានល្អប្រសើរ តាមតួនាទីជាភ្នាក់ងារតំណាងរបស់រដ្ឋ របស់ក្រុមប្រឹក្សាឃុំអណ្តូងទឹក
- ស្វែងរកការគាំទ្របច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំអណ្តូងទឹក ។

ពិនិត្យជាមួយការប្រើប្រាស់ដីនៅក្នុងឃុំនេះ ជាឧបករណ៍មួយដ៏សំខាន់ដែលជួយដល់ក្រុមប្រឹក្សាឃុំផ្ទាល់ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព

ការគ្រប់គ្រង និងប្រើប្រាស់ដីគឺជាកត្តាស្នូលនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ ដូច្នេះក្រោយពីមានផែនការប្រើប្រាស់ដីនេះ អាជ្ញាធរគ្រប់ផ្នែកនៅថ្នាក់ក្រោមជាតិ ពិសេសអាជ្ញាធរដែនដីនឹងមានមូលដ្ឋានកាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីនៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរណកម្មផែនការនៅថ្នាក់ស្រុក និងការអនុម័តនៅថ្នាក់ខេត្ត តាមនីតិវិធីដែលបានអនុវត្តន៍ក្នុងការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកន្លងមក ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុការចូលរួមធ្វើការសំរេច ។

ឯកសារផែនការអភិវឌ្ឍន៍នេះនឹងបរិយាយពីស្ថានភាពជាក់ស្តែងរបស់ឃុំ សេចក្តីត្រូវការអភិវឌ្ឍន៍ និងគោលដៅអភិវឌ្ឍន៍ដែលជាគំរោងសកម្មភាពអាទិភាពរបស់ឃុំអណ្តូងទឹក ដែលត្រូវអនុវត្តក្នុងរយៈពេលជាបន្តបន្ទាប់ ។

# គោលបំណង

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំអណ្តូងទឹកដែលត្រូវបានធ្វើផែនការលំអិត ដើម្បីឱ្យស៊ីសង្វាក់គ្នាក្នុងដំណើរការរៀបចំធ្វើផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ឃុំ ។

ការងារនេះមានគោលបំណងគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំផែនការ និងជំរើសនានាសំរាប់ការប្រើប្រាស់ដីនៅពេលអនាគត ។

អ្នកអនុវត្តគោលការណ៍ជាបឋមគឺ ក្រុមប្រឹក្សាឃុំ និងមន្ត្រីដែលទទួលភារកិច្ចគាំទ្រដល់ក្រុមប្រឹក្សាឃុំ និងការរៀបចំផែនការប្រើប្រាស់ដីឃុំ ។

ដំណើរការនៃការរៀបចំផែនការប្រើប្រាស់ដីនេះ ឃុំត្រូវធ្វើតាមដំណាក់កាលនីមួយៗ សំដៅឱ្យមានការប្រើប្រាស់ដីឱ្យចំគោលដៅ កាត់បន្ថយទំនាស់ និងការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាពដែលមានការចូលរួមពីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធដោយតម្លាភាព ។

# ប្រវត្តិនៃឃុំអណ្តូងទឹក

តាមតំណាលតៗគ្នាពីបូរាណមក មានអ្នកប្រមាញ់ដើរបបាញ់សត្វព្រៃ នៅភ្នំមួយគឺភ្នំដូនលាវ កាលសម័យនោះ តំបន់នេះគឺជាតំបន់ព្រៃឈើធំៗ ហើយសំបូរដោយសត្វព្រៃច្រើនប្រភេទណាស់ នៅពេលនោះអ្នកប្រមាញ់បានដើរស្វែងរកប្រមាញ់សត្វព្រៃ ក៏ជួបអណ្តូងថ្មបូរាណមួយកន្លែង ហើយមានអណ្តូងជាច្រើនជាប់ៗគ្នា អណ្តូងថ្មបូរាណនេះមានទឹកអាចប្រើប្រាស់បាន កន្លែងនេះក៏ជាតំបន់សំណាក់ធមិរបស់លោកយាយដូនលាវ ។ រហូតដល់បច្ចុប្បន្នប្រជាពលរដ្ឋនៅតំបន់នេះបានឱ្យឈ្មោះថា**ភ្នំដូនលាវ** ប៉ុន្តែអាជ្ញាធរភូមិ ឃុំ បានដាក់ឈ្មោះតំបន់នេះថាជា **ភូមិអណ្តូងទឹក ឃុំអណ្តូងទឹក** ទៅវិញ ដោយសារតំបន់នេះសំបូរអណ្តូងបូរាណធម្មជាតិ ហើយសព្វថ្ងៃបានក្លាយជាតំបន់សំណាក់ធមិ និងជាតំបន់ទេសចរណ៏វប្បធមិនៅក្នុងភូមិអណ្តូងទឹក ឃុំអណ្តូងទឹកសព្វថ្ងៃ ។

# ជំពូក ១

# ព័ត៌មាន និង ទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ

## ១.១. ស្ថានភាពទូទៅ

មានតំណាលតៗគ្នាពីបូរាណមកមានអ្នកប្រមាញ់ដើរបបាញ់សត្វព្រៃនៅភ្នំមួយគឺភ្នំដូនលាវ កាលពីសម័យនោះ តំបន់នេះគឺជាតំបន់ព្រៃឈើធំៗ ហើយសំបូរដោយសត្វព្រៃច្រើនប្រភេទណាស់ នៅពេលនោះអ្នកប្រមាញ់បានដើរស្វែងរកប្រមាញ់សត្វព្រៃក៏ជួបអណ្តូងថ្មបូរាណមួយកន្លែង ហើយមានអណ្តូងជាច្រើនជាប់ៗគ្នា អណ្តូងថ្មបូរាណនេះមានទឹកអាចប្រើប្រាស់បាន កន្លែងនេះជាតំបន់សំណាក់ធម៌របស់លោកយាយដូនលាវ ។ រហូតដល់បច្ចុប្បន្នប្រជាពលរដ្ឋនៅទីនោះបានឱ្យឈ្មោះថាភ្នំដូនលាវ ប៉ុន្តែអាជ្ញាធរភូមិ ឃុំ បានដាក់ឈ្មោះតំបន់នេះថាជាភូមិអណ្តូងទឹកទេវិញ ដោយសារតំបន់នេះសំបូរអណ្តូងបូរាណធម្មជាតិ ហើយសព្វថ្ងៃបានក្លាយជាតំបន់សំណាក់ធម៌ និងជាតំបន់ទេសចរណ៍វប្បធម៌នៅក្នុងភូមិអណ្តូងទឹក ឃុំអណ្តូងទឹកសព្វថ្ងៃ ។

ឃុំអណ្តូងទឹកគឺជាឃុំមួយក្នុងចំណោមឃុំទាំង ៤ របស់ស្រុកបូទុមសាគរ ខេត្តកោះកុង មានផ្ទៃដីសរុប ៥.៤០២គម² ។ ឃុំអណ្តូងទឹកមានភូមិចំនួន ៧ គឺ ភូមិអណ្តូងទឹក ភូមិជីមាល ភូមិប្រៃ ភូមិជីត្រេះ ភូមិតាអុក ភូមិតាមាយ និងភូមិប្រទាល ។ ឃុំអណ្តូងទឹកមានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៤៨ ជាឃុំទីរួមស្រុកបូទុមសាគរ មានចម្ងាយផ្លូវប្រមាណ ៩៦ គម. ពីទីរួមខេត្តកោះកុង ។ ឃុំអណ្តូងទឹកមានព្រំប្រទល់ខាងជើងជាប់ជាមួយឃុំជីផាត និងឃុំត្រពាំងរូង ខាងត្បូងជាប់ជាមួយឃុំតានូន និងឃុំថ្មស ខាងកើតជាប់ជាមួយឆកសមុទ្រកំពង់សោម និងឃុំកណ្តោល និងខាងលិចជាប់ជាមួយឃុំភ្ញីមាស ។

ពីអតីតកាលឃុំនេះមានផ្ទៃដីព្រៃស្រោងប្រមាណ ២/៣ នៃផ្ទៃដីសរុប ព្រមទាំងសំបូរដោយសត្វព្រៃ អនុផលព្រៃឈើ ផលត្រីសមុទ្រ ។ ប៉ុន្តែចាប់ពីឆ្នាំ ១៩៩៩ មក ធនធានធម្មជាតិទាំងនេះត្រូវបានថយចុះជាបន្តបន្ទាប់ ដោយសារមានកំណើនប្រជាជន ការកាប់ទន្ទ្រានព្រៃឈើ ការនេសាទខុសច្បាប់ជាដើម ។ បច្ចុប្បន្ននេះប្រជាពលរដ្ឋឃុំអណ្តូងទឹកសរុបមានចំនួន ៥.៩៣២ នាក់ ក្នុងនោះគ្រួសារមានមុខរបរធ្វើកសិកម្មជាចម្បងមានប្រមាណ ៥៧,៣៨% គ្រួសារមានមុខរបរនេសាទជាចម្បងប្រមាណ ៧,៣៤% គ្រួសារមុខរបរធ្វើសិប្បកម្មជាចម្បងមាន ០,១០ % គ្រួសារប្រកបមុខរបរសេវាកម្មជាចម្បងមាន ១០,៦៨ % និងគ្រួសារដែលប្រកបមុខរបរចំរុះក្រៅពីខាងលើមាន ២៤,៥០% ។

ឃុំអណ្តូងទឹកជាឃុំមួយក្នុងចំណោមឃុំទាំង ៤ របស់ស្រុកបូទុមសាគរ ខេត្តកោះកុង ឃុំអណ្តូងទឹកស្ថិតនៅសងខាងផ្លូវជាតិលេខ ៤៨ ដែលមានប្រវែងផ្លូវជាតិ ១៩.២៣៤,៧០ ម៉ែត្រកាត់ភូមិ ២ គឺភូមិអណ្តូងទឹក និងភូមិជីមាល ក្នុងឃុំអណ្តូងទឹក ឃុំនេះមានផ្លូវក្រាលគ្រួសក្រហម ១ ខ្សែ ភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុចអូរម្កាក់ ឆ្ពោះទៅឃុំថ្មស ឆ្លងកាត់ភូមិជីមាល ភូមិជីត្រេះ ភូមិប្រៃ ភូមិតាអុក ភូមិប្រទាល ក្នុងឃុំអណ្តូងទឹក ក្រៅពីនេះមានផ្លូវចូលភូមិដូចជាផ្លូវក្រាលគ្រួសក្រហមចូលភូមិតាមាយប្រមាណជាង ៣ គ.ម ភ្ជាប់ពីផ្លូវចូលឃុំថ្មសត្រង់ចំណុចកែងភូមិប្រទាល និងមានផ្លូវលំដីសអមសងខាងព្រែកអណ្តូងទឹកប្រមាណ ១ គ.ម ដែលជាទីប្រជុំជនក្នុងឃុំអណ្តូងទឹក ឃុំនេះមានព្រែកបីធំៗគឺព្រែកអណ្តូងទឹក ព្រែកកន្ទួត និងព្រែកតាអុក ភ្ជាប់ពីឆកសមុទ្រកំពង់សោម ដែលជាលក្ខណៈងាយស្រួលក្នុងរបរនេសាទ

របស់ប្រជាពលរដ្ឋក្នុងតំបន់នេះ ។ ឃុំអណ្តូងទឹកមានផ្សារមួយកន្លែង បណ្តោយប្រមាណ ៧០ ម៉ែត្រ ទទឹងប្រមាណ ៣០ ម៉ែត្រ ស្ថិតនៅជាប់ផ្លូវជាតិលេខ ៤៨ ចំងាយចេញពីគល់ស្ពានអណ្តូងទឹកប្រមាណជាង ១០០ ម៉ែត្រ ផ្សារនេះមានឈ្មោះថា ផ្សារអណ្តូងទឹក ។ មានវត្ត ០២ កន្លែង មួយស្ថិតនៅក្នុងភូមិអណ្តូងទឹក ឈ្មោះវត្តចន្ទមុនីរាមអណ្តូងទឹក មួយកន្លែងទៀត ស្ថិតនៅភូមិប្រទាល ឈ្មោះវត្តតាអុក ដោយសារវត្តនេះពីមុនស្ថិតក្នុងភូមិតាអុក ក្រោយមកដោយភូមិតាអុកមានទំហំធំពិបាកក្នុងការគ្រប់គ្រង អាជ្ញាធរដែនដីបានធ្វើសំណើទៅក្រសួងមហាផ្ទៃដើម្បីកាត់ភូមិនេះជាពីរ គឺភូមិតាអុកដដែលមួយ និងមួយទៀតគឺភូមិប្រទាល នៅពេលកាត់ភូមិនេះដោយទាំងវត្តមកជាមួយភូមិប្រទាលផង ហេតុនេះហើយទើបឈ្មោះវត្តនៅតែឈ្មោះវត្តតាអុកដដែល ។

- ឃុំអណ្តូងទឹកមានមណ្ឌលសុខភាព ១ កន្លែង មាន ២ អគារ ចេញពីផ្លូវជាតិលេខ ៤៨ ប្រមាណ ១០០ម
- មានសាលាស្រុក ១ អគាររាងអក្សរអិល ជាប់ផ្លូវជាតិលេខ ៤៨ ក្នុងភូមិអណ្តូងទឹក
- មានស្នាក់ការគណបក្សប្រជាជន ១ អគារជាប់ផ្លូវជាតិលេខ ៤៨ ស្ថិតក្នុងភូមិអណ្តូងទឹក
- មានបញ្ជាការ PM ១ អាគារជាប់ផ្លូវជាតិលេខ ៤៨ ស្ថិតក្នុងភូមិអណ្តូងទឹក
- មានអធិការដ្ឋាននគរបាលជាប់ផ្លូវជាតិលេខ ៤៨ ស្ថិតក្នុងភូមិអណ្តូងទឹក
- មានបញ្ជាការសឹករងស្រុកជាប់ផ្លូវជាតិលេខ ៤៨ ស្ថិតក្នុងភូមិជីមាល
- មានសាលារៀនក្នុងភូមិអណ្តូងទឹក សាលាបឋមសិក្សា ១ កន្លែង ក្នុងនោះថ្នាក់មត្តេយ្យ ១ បន្ទប់ (ខ្ទីសាលាបឋមសិក្សា) ជាប់ផ្លូវជាតិលេខ ៤៨ សាលាមធ្យមសិក្សា ១ កន្លែង មាន ១ ខ្នង ចេញពីផ្លូវជាតិលេខ ៤៨ ប្រមាណ ៣០០ម ស្ថិតនៅ ពីក្រោយសាលាបឋមសិក្សាអណ្តូងទឹក ។
- សាលាបឋមសិក្សាស្ថិតនៅភូមិប្រទាល ត្រង់វត្តតាអុក ១ខ្នង
- សាលាឃុំអណ្តូងទឹក ស្ថិតក្នុងភូមិជីមាលជាប់ផ្លូវជាតិលេខ ៤៨
- ទីស្នាក់ការឧទ្យានជាតិបូទុមសាគរស្ថិតនៅក្នុងភូមិជីមាលជាប់ផ្លូវជាតិលេខ ៤៨

### ១.១.១. ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| ខេត្ត | កោះកុង | |
| ស្រុក | បូទុមសាគរ | |
| ឃុំ | អណ្តូងទឹក | លេខកូដ ៩០១០១ |
| ចំនួនភូមិ | ៧ ភូមិ ក្នុងនោះមាន : ភូមិអណ្តូងទឹក-ជីមាល-ប្រែ-ជីត្រេះ-តាអុក-តាមាឃ និងប្រទាល | |

**ផែនទីបង្ហាញទីតាំង ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង**




### ១.១.២. ប្រជាសាស្ត្រ

ឃុំអណ្តូងទឹកមានប្រជាជនសរុបចំនួន ១.០៤៩ គ្រួសារ មានប្រជាជនសរុប ៥.៤៣២ នាក់ ក្នុងនោះស្រីមានចំនួន ២.៥៣៧ នាក់ មានដង់ស៊ីតេ ១នាក់ ០,៩៧ គីឡូម៉ែត្រក្រឡា ។

របាយការណ៍ប្រជាជនរស់នៅតាមបណ្តាភូមិខាងលើ :

- ភូមិអណ្តូងទឹកមានរបាយប្រជាជនរស់នៅ

  ១- ជនជាតិខ្មែរ កាន់សាសនាព្រះពុទ្ធ

  ២- ជនជាតិខ្មែរឥស្លាម កាន់សាសនាឥស្លាម

  ៣- ជនជាតិវៀតណាម កាន់សាសនាព្រះពុទ្ធ

- ភូមិជីមាល, ប្រៃ, ជីត្រេះ និងភូមិតាអុក មានជនជាតិខ្មែររស់នៅកាន់សាសនាព្រះពុទ្ធ
- ភូមិតាមាឃ ប្រទាល មានជនជាតិខ្មែរ និងជនជាតិវៀតណាមរស់នៅលាយឡំគ្នា កាន់សាសនាព្រះពុទ្ធ តែក៏នៅមានជំនឿទៅលើការសែនព្រេនអារក្ខអ្នកតាខ្លះដែរ ។

**តារាងស្ថិតិប្រជាជនឃុំអណ្តូងទឹក ឆ្នាំ ២០០៩ តាមក្រុមអាយុ**

| ស្ថិតិតាមក្រុមអាយុ | ប្រុស (នាក់) | ស្រី (នាក់) | សរុប (នាក់) | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម ០៥ ឆ្នាំ | 315 | 281 | 596 | |

| | | | | |
|---|---|---|---|---|
| អាយុ ០៥ ឆ្នាំ | 109 | 54 | 163 | អាយុចូលរៀនកំរិតសិក្សាមត្តេយ្យ |
| អាយុពី ៦-១១ ឆ្នាំ | 355 | 363 | 718 | អាយុចូលរៀនកំរិតសិក្សាបឋម |
| អាយុពី ១២-១៤ ឆ្នាំ | 229 | 238 | 467 | អាយុចូលរៀនកំរិតសិក្សាអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ ឆ្នាំ | 249 | 198 | 447 | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ ឆ្នាំ | 433 | 346 | 779 | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ២៥-៦០ ឆ្នាំ | 1,122 | 949 | 2,071 | អាយុពេញពលកម្ម |
| អាយុ ៦១ ឆ្នាំឡើង | 183 | 108 | 291 | |
| ប្រជាជនសរុប | 2,995 | 2,537 | 5,532 | |
| **ចំនួនគ្រួសារ** | | | **1,049 គ្រួសារ** | |

*( ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

### ១.១.៣. ភាពគ្មានដីធ្លី

ឃុំអណ្តូងទឹកជាឃុំមួយដែលមានព្រែកធំៗ ៣ និង ព្រែកតូចៗជាច្រើន ហើយក៏ជាឃុំមួយជាប់តំបន់ឆ្នេរសមុទ្រ ហេតុនេះហើយបានជាប្រជាពលរដ្ឋភាគច្រើនជាអ្នកនេសាទ ពួកគាត់រស់នៅលើចំណីព្រែក និង ចំណីសមុទ្រ ( ដែលជាដីសាធារណៈរបស់រដ្ឋ ) ។ ដូច្នេះពួកគាត់គ្មានដីសំរាប់សង់លំនៅដ្ឋាន ដីស្រែ និង ដីចំការផ្ទាល់ខ្លួនទេ ។ ក្នុងនោះមាន :

- គ្រួសារគ្មានដីធ្លីផ្ទាល់ខ្លួនចំនួន ៨២ គ្រួសារ រស់នៅដោយការជួលដីគេធ្វើស្រែ ដាំបន្លែ និង ប្រកបរបរស៊ីឈ្នួលដកស្ទូង ច្រូតស្រូវ ហើយនៅរដូវប្រាំងប្រកបរបរ នេសាទត្រី តាមដងព្រែក និង សមុទ្រ ។
- គ្រួសារមានដីស្រែតិចជាង ១ ហិកតា ១៧១ គ្រួសារ គ្រួសារទាំងនេះក៏ត្រូវរកចំណូលបន្ថែមទើបអាចហូបចុកគ្រប់គ្រាន់ ដែលក្នុងនោះពួកគាត់ត្រូវស៊ីឈ្នួលដកស្ទូង និងរកនេសាទ ដើម្បីបំពេញការទិញអង្ករហូបចុកនៅរដូវវស្សា គ្រួសារទាំងនេះមានអ្នកខ្លះមានគោ ក្របី ។ គ្រួសារប្រភេទនេះបច្ចុប្បន្នរស់នៅលើដីសាធារណៈរបស់រដ្ឋដូចជាតាំងលំនៅដ្ឋានតាមមាត់ព្រែក ឬក្នុងឆ្នេរសមុទ្រ ហើយគ្រួសារប្រភេទនេះប្រកបមុខរបរនេសាទត្រី ស៊ីឈ្នួលដកស្ទូង ច្រូតស្រូវ និងរុករកអនុផលព្រៃឈើ ដូចជា ជ័រ វល្លិ៍ តាអោន ផ្លែសំរោង ផ្តៅ ។ល។

តារាងគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់

| បរិយាយ | ចំនួនគ្រួសារ | ភាគរយ ប្រ/ជ សរុប | ផ្សេងៗ |
|---|---|---|---|
| ជួលដីគេធ្វើស្រែនិងដាំបន្លែ | 82 | 7.81% | |
| មានដីស្រែតិចជាង ១ ហ.ត | 171 | 16.30% | |

*( ស្រង់ចេញពីឯកសារព័ត៌មានស្ថានភាពឃុំ ឆ្នាំ ២០០៨)*



### ១.១.៤. ស្ថានភាពសេដ្ឋកិច្ច

- ឃុំអណ្តូងទឹកគឺជាឃុំមួយសំបូរទៅដោយធនធានធម្មជាតិ ដូចជាព្រៃឈើ សត្វព្រៃ វាលស្មៅ អូរ បឹង និងមច្ឆា ។ ឃុំនេះមានព្រែក ៣ ធំៗគឺ ព្រែកជីផាត ព្រែកកន្ទួត និងព្រែកតាអុក សុទ្ធតែជាព្រែកជាប់ឆ្នេរដែលសមុទ្រ នាវាអាចចេញចូលបាន សក្តានុពលរបស់វាគឺ មានឆ្នេរខ្សាច់ មានព្រៃលិចទឹក និងព្រៃកោងកាង ដោយប្រជាពលរដ្ឋនៅក្នុងឃុំនេះ អាចទាញយកផលនេសាទបានគ្រប់រដូវ ក្នុងនោះមានប្រជាពលរដ្ឋប្រមាណ ៧,៣៤% មានមុខរបរនេសាទប្រចាំថ្ងៃ ស្មើនឹង ៧៧ គ្រួសារ ។

- ដោយឡែកធនធានដីធ្លី សំរាប់ប្រកបមុខរបរធ្វើស្រែចំការមានប្រមាណ ១.៦៤៨,១៨ ហ.ត ប៉ុន្តែផ្ទៃដីស្រែចំការទាំងនេះពុំទាន់បានប្រើប្រាស់អស់លទ្ធភាពនៅឡើយ ។ ក្នុងនោះប្រជាពលរដ្ឋប្រកបមុខរបរធ្វើស្រែចំការមានចំនួន ៥៣,៥៨% ក្នុងនោះគ្រួសារមានមុខរបរធ្វើស្រែជាចំបងមានចំនួន ៣៥,៥៦% ស្មើនឹង ៣៧៣ គ្រួសារ និងមានផ្ទៃដីស្រែចំនួន ៦៨៦,៧៣ ហ.ត ។ ប្រជាជនធ្វើស្រូវតែមួយរដូវកាលតែប៉ុណ្ណោះដោយក្នុង ០១ ហ.ត ទទួលបានទិន្នផលស្រូវ ១,៥០ តោន ដូច្នេះការផលិតប្រចាំឆ្នាំបានចំនួន ១.០៣០,១០ តោន/១ឆ្នាំ ក្នុងករណីដែលផ្ទៃដីទាំងអស់ត្រូវបានដាំដុះ ។ រីឯប្រជាពលរដ្ឋប្រមាណ ១០% ផ្សេងទៀត មានមុខរបរលក់ដូរនៅទីផ្សារ ព្រមទាំងមន្ត្រីរាជការបំរើការងារនៅក្នុងសាលាស្រុក និងក្រុមប្រឹក្សាឃុំផងដែរ ។

- ប្រភពរបាយការណ៍បានមកពីទិន្នន័យស្ថានភាពឃុំ និងការធ្វើបច្ចុប្បន្នភាពផែនទីឃុំ

**តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំអណ្តូងទឹក**

| ល.រ | ប្រភេទមុខរបរ | ឆ្នាំ ២០០៨ | | ផ្សេងៗ |
|---|---|---|---|---|
| | | ភាគរយ(%) | ចំនួនគ្រួសារ | |

| | | | | |
|---|---|---|---|---|
| ១ | គ្រួសារមានមុខរបរកសិកម្មជាចំបង | 64.73 | 679 | |
| ២ | គ្រួសារធ្វើស្រែចំបង | 35.56 | 373 | ធ្វើស្រែវស្សាបាន ១ដង/១ឆ្នាំ |
| ៣ | គ្រួសារមានដាំដំណាំរយៈពេលវែងជាចំបង | 6.20 | 65 | ដូង, ខ្នុរ, ស្វាយ, ស្វាយចន្ទី |
| ៤ | គ្រួសារមានដាំដំណាំរយៈពេលខ្លីជាចំបង | 6.20 | 65 | ពោត, ដំឡូងជ្រា, ឪឡឹក |
| ៥ | គ្រួសារមានដាំបន្លែជាចំបង | 5.62 | 59 | ត្រកួន,ស្លែ,ត្រសក់ |
| ៦ | គ្រួសារមានធ្វើនេសាទចំបង | 7.34 | 77 | ត្រី, បង្គារ, ក្តាម, មឹក |
| ៧ | គ្រួសារមានចិញ្ចឹមសត្វចំបង | 2.96 | 31 | គោ,ក្របី,ជ្រូក,មាន់,ទា |
| ៨ | គ្រួសារមានអនុផលព្រៃឈើចំបង | 0.86 | 09 | បោចវល្លិ៍ ផ្តៅ ជ័រ |
| ៩ | គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចំបង | 0.10 | 01 | ធ្វើទឹកកក |
| ១០ | គ្រួសារមានមុខរបរធ្វើសិប្បកម្មផ្សេងៗ | 0.10 | 01 | ជួសជុល តុ ទូ |
| ១១ | គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង | 10.86 | 11 | |
| ១២ | គ្រួសារប្រកបមុខរបរធ្វើជំនួញ | 1.05 | 11 | ទិញផលនេសាទ បន្លែ |
| ១៣ | គ្រួសារប្រកបមុខរបរធ្វើជាង | 1.05 | 11 | ជួសជុលម៉ូតូ |
| ១៤ | គ្រួសារប្រកបមុខរបរដឹកជញ្ជូន | 0.57 | 06 | ដឹកទំនិញ និងផលនេសាទ |
| ១៥ | គ្រួសារប្រកបមុខរបរសេវាកម្មផ្សេងៗ | 8.01 | 84 | |
| ១៦ | គ្រួសារប្រកបមុខរបរចំរុះក្រៅពីខាងលើ | 24.50 | 257 | |

*(ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

### ១.១.៥. ស្ថានភាពអប់រំ និងសិក្សាធិការ

ចំពោះស្ថានភាពនៃការអប់រំរបស់ឃុំអណ្តូងទឹក មានសាលា ២ កន្លែង ក្នុងនោះ ១ កន្លែងស្ថិតនៅភូមិប្រទាល និង ១ កន្លែងទៀត ស្ថិតនៅភូមិអណ្តូងទឹក។ សាលាបឋមសិក្សាមានចំនួន ២ សាលា ស្មើ ១៦ បន្ទប់ ត្រូវជា ១៣ ថ្នាក់ ។ ថ្នាក់មត្តេយ្យនៅមិនទាន់មានសាលានៅដាច់ដោយឡែកនៅឡើយ ។ កុមារអាយុ ៥ ឆ្នាំមានចំនួន ១៦៣ នាក់ ក្នុងនោះបានចូលរៀនតែចំនួន ៣៦ នាក់ ស្មើ ២២ % (សព្វថ្ងៃខ្ចីបន្ទប់សាលាបឋមសិក្សា អណ្តូងទឹក ចំនួន ០១ បន្ទប់) និង កុមារមិនបានចូលរៀនចំនួន ១២៧ នាក់ ស្មើនឹង ៧៨ %។

នៅក្នុងកំរិតបឋមសិក្សាឃុំអណ្តូងទឹកមានគ្រូចំនួន ២២ នាក់ និង កុមារចំនួន ៧១៨ នាក់ ដែលនៅក្នុងនោះ កុមារមិនបានចូលរៀនចំនួន ១២១ នាក់ (ប្រុស ៦៦ នាក់ ស្រី ៥៥ នាក់)ស្មើ ១៦,៨៥% ។ ចំណែកកំរិតអនុវិទ្យាល័យ មានកុមារចំនួន ៤៦៧ នាក់ ដែលនៅក្នុងនោះកុមារមិនបានចូលរៀនចំនួន ៦៩ នាក់ (ប្រុស ៣៤ នាក់ ស្រី ៣៥ នាក់)ស្មើ ១៤,៧៨ % ។ កំរិតវិទ្យាល័យមាន ០១ សាលា ១០ បន្ទប់ ០៨ ថ្នាក់ គ្រូបង្រៀនចំនួន ១៧ នាក់ កុមារសរុប ៤៤៧ នាក់ កុមារមិនបានចូលរៀន ៨២ នាក់ ស្មើ ១៨,៣៤ % ។ ដូច្នេះតាមព័ត៌មានឃុំបានឱ្យដឹងថា បច្ចុប្បន្នសាលាកំពុងជួបបញ្ហាខ្វះ គ្រូបង្រៀនបណ្តាលឱ្យសិស្សដែលត្រូវឡើងពីកំរិតបឋមត្រូវខ្វះគ្រូបង្រៀនដដែល ។



**តារាងស្ថិតិសាលា និងចំនួនសិស្សប្រចាំឆ្នាំ ២០០៨**

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | អត្រាមិនចូលរៀន |
|---|---|---|---|---|---|---|---|
| | សាលា | បន្ទប់ | ថ្នាក់ | កុមារសរុប | សិស្សសរុប | សិស្សស្រី | |
| ថ្នាក់មត្តេយ្យសិក្សា | 00 | 00 | 00 | 163 | 36 | - | 127នាក់ស្មើ78% |
| ថ្នាក់បឋមសិក្សា | 02 | 16 | 13 | 718 | 597 | 308 | 121នាក់ស្មើ16.85% |
| ថ្នាក់អនុវិទ្យាល័យ | 00 | 00 | 00 | 467 | 398 | 203 | 69នាក់ស្មើ14.78% |
| ថ្នាក់វិទ្យាល័យ | 01 | 10 | 08 | 447 | 365 | - | 82នាក់ស្មើ18.34% |

*(ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

### ១.១.៦. ស្ថានភាពសុខាភិបាល

#### ១.១.៦.១. ផ្នែកសុខាភិបាល

បច្ចុប្បន្នសេវាមណ្ឌលសុខភាពមាន ១ កន្លែង និងមានអគារ ២ ខ្នង នៅឃុំអណ្តូងទឹក ដោយពុំទាន់បំពេញនូវសេចក្តីត្រូវការរបស់ប្រជាជនទូទាំងភូមិ ឃុំ បានឡើយ ព្រោះមានភូមិមួយចំនួនស្ថិតនៅឆ្ងាយពីមណ្ឌលសុខភាពដូចជាភូមិ ប្រៃ ជីត្រេះ ប្រទាល តាអុក តាមាយ កត្តាទាំងនេះគឺអាស្រ័យលើផ្លូវធ្វើដំណើរ ។ ជំងឺកើតលើប្រជាពលរដ្ឋក្នុងឃុំដែលកាចសាហាវជាងគេគឺជំងឺរបេង អេដស៍ គ្រុនចាញ់ ។

ស្ថិតក្នុងដំណាក់កាលនេះ ឃុំអណ្តូងទឹកក៏ពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិសំរាប់ជួយសំរួលទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពនៅឡើយ ។



**តារាងស្ថិតិ មណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ**

| មណ្ឌល/ប៉ុស្តិ៍សុខភាព | អគារ | សមត្ថភាពផ្តត់ផ្គង់សេវាកម្ម | | | | | |
|---|---|---|---|---|---|---|---|
| | | ចំនួនមណ្ឌល | គ្រែ | បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណតាមភូមិ |
| មណ្ឌលសុខភាព | ០២ | ០១ | ១២ | ១២ | ០៣ | ០៣<br>ឥតក្របខណ្ឌ | ២៤ នាក់ |
| ប៉ុស្តិ៍សុខភាពភូមិ | 0 | 0 | 0 | 0 | 0 | 0 | 0 |

*( ប្រភពឯកសារស្រង់ចេញពីមណ្ឌលសុខភាពឃុំអណ្តូងទឹក)*

- ចម្ងាយជាមធ្យមពីភូមិមកមណ្ឌលសុខភាពឃុំ ចំពោះភូមិជីត្រេះ ១២ គ.ម ដោយឡែកភូមិតាមាយ និងភូមិប្រទាលមានចំងាយពី ២៨-៣0 គ.ម ផ្លូវធ្វើដំណើរមានការលំបាកដោយត្រូវឆ្លងព្រែកធំៗ ចំនួន ០២ គឺព្រែកកន្ទួត និងព្រែកតាអុក ព្រែកទាំងពីរនេះពុំទាន់មានស្ពានឆ្លងនៅឡើយ សព្វថ្ងៃនេះការធ្វើដំណើររបស់ប្រជាពលរដ្ឋត្រូវឆ្លងសាឡង់ ឬ ទូកដរ ដែលត្រូវចំណាយប្រាក់ ។

- ផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនៃឃុំអណ្តូងទឹក ដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា បណ្តាលឱ្យមានការលំបាកក្នុងសេវាដឹកជញ្ជូនកន្លងមក ការដឹកជញ្ជូនត្រូវធ្វើតាមទូក និង តាមម៉ូតូ ។



### ១.១.៦.២. ស្ថានភាពប្រើប្រាស់ទឹកស្អាត និង អនាម័យ

ប្រភពនៃការប្រើប្រាស់ទឹកស្អាតខាងលើនេះ ពុំទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាពលនៅក្នុងឃុំអណ្តូងទឹកនេះនៅឡើយ ពីព្រោះប្រជាជនក្នុងឃុំអណ្តូងទឹកភាគច្រើនប្រើទឹកអណ្តូង និង ទឹកស្រះ ក៏នៅតែមានកង្វះខាតប្រភពទឹកស្អាតសំរាប់ប្រើប្រាស់ដដែល ដោយសារទឹកអណ្តូង ឬ ទឹកស្រះ មួយចំនួនអាចរីងនៅរដូវប្រាំង ។

- តែទោះជាយ៉ាងនេះក៏ដោយ ក៏ប្រជាពលរដ្ឋមិនអាចមានទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់នៅឡើយ ដោយសារអណ្តូងស្នប់មួយចំនួនខូច អណ្តូងលូមិនចេញទឹកនៅរដូវប្រាំង តំរូវការជួសជុលទាំងស្រុង ។



**តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំអណ្តូងទឹក**

| ល.រ | ប្រភេទអណ្តូង | ឆ្នាំ ២០០៦ | ឆ្នាំ ២០០៧ | ឆ្នាំ ២០០៨ |
|---|---|---|---|---|
| ១ | ចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះ | 165 | 210 | 158 |
| ២ | ចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះ ប្រើពេញ ១ ឆ្នាំ | 158 | 168 | 129 |
| ៣ | ចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះ មិនអាចប្រើបានរដូវប្រាំង | 07 | 42 | 29 |
| ៤ | ចំនួនអណ្តូងស្នប់ ឬអណ្តូងចំរុះ ដែលត្រូវជួសជុល | 23 | 53 | 29 |
| ៥ | ចំនួនអណ្តូងលូ | 37 | 67 | 37 |
| ៦ | ចំនួនអណ្តូងលូប្រើបានពេញ ១ ឆ្នាំ | 33 | 38 | 30 |
| ៧ | ចំនួនអណ្តូងលូមិនអាចប្រើបានរដូវប្រាំង | 04 | 29 | 07 |
| ៨ | ចំនួនស្រះទឹកធម្មតា | 02 | 06 | 39 |

*( ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៨)*



## ១.២. ស្ថានភាពភូមិសាស្ត្រ :

### ១.២.១ ទីតាំងភូមិសាស្ត្រ :

ឃុំអណ្តូងទឹកមានលក្ខណៈសណ្ឋានដីជាតំបន់ភ្នំ គ្របដណ្តប់ដោយព្រៃឈើ មានរយៈកំពស់ខ្ពស់នៅប៉ែកខាងជើង និងខាងលិច ដែលមានរយៈកំពស់ខ្ពស់បំផុតពី ២១៦-៤០២ ម និងមានរយៈកំពស់ទាបនៅប៉ែកខាងកើត និងខាងត្បូង ដែលមានរយៈកំពស់ទាបបំផុតពី ០-៨ម តំបន់ជាប់ឆ្នេរសមុទ្រ និងព្រែក ។

**ផែនទីរយៈកំពស់ ក្នុងឃុំអណ្ដូងទឹក**




### ១.២.២. អាកាសធាតុ :

ឃុំអណ្ដូងទឹកមានលក្ខណៈអាកាសធាតុក្ដៅហើយសើម ។ មានរដូវពីរ គឺរដូវប្រាំង និងរដូវវស្សា ។ រដូវប្រាំងចាប់ពីខែ វិច្ឆិកា ដល់ខែមេសា និងរដូវវស្សាចាប់ពីខែ ឧសភា ដល់ខែតុលា ។ មានកំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ :

- ឆ្នាំ ២០០៦ កំពស់ទឹកភ្លៀងខ្ពស់នៅខែមេសា ឧសភា មិថុនា សីហា កញ្ញា និង ខែ តុលា និង កំពស់ខ្ពស់បំផុតនៅខែ សីហា ហើយកំពស់សរុបប្រចាំឆ្នាំមាន ៣.២២២,៦៩ មម ។
- ឆ្នាំ ២០០៧ កំពស់ទឹកភ្លៀងខ្ពស់នៅខែ ឧសភា មិថុនា កក្កដា សីហា កញ្ញា និង ខែ តុលា និង កំពស់ខ្ពស់បំផុតនៅខែ កក្កដា ហើយកំពស់សរុបប្រចាំឆ្នាំមាន ២.០២១,៦១ មម ។
- ឆ្នាំ ២០០៨ កំពស់ទឹកភ្លៀងខ្ពស់នៅខែ មិនា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា និង ខែ វិច្ឆិកា និង កំពស់ខ្ពស់បំផុតនៅខែ មិថុនា ហើយកំពស់សរុបប្រចាំឆ្នាំមាន ២.៣០៤,៤៣ មម ។

*( ទិន្នន័យបានមកពីមន្ទីរធនធានទឹក និងឧតុនិយមខេត្ត)*




### ១.២.៣. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន :

- ឃុំអណ្ដូងទឹកគឺជាឃុំមួយមានទីតាំងរដ្ឋបាលជាប់ផ្លូវជាតិលេខ ៤៨ និងមានផ្លូវលំក្រាលគ្រួសក្រហមភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុចអូរម្កាក់ឆ្ពោះទៅឃុំថ្មស ព្រមទាំងមានព្រែកធំៗចំនួន ៣ នាវាអាចចេញចូលបានគ្រប់រដូវ និងមានផ្លូវលំ តូចៗជាច្រើន អាចសំរួលដំណើរប្រជាពលរដ្ឋពីភូមិមួយ ទៅភូមិមួយបានយ៉ាងល្អប្រសើរ ។

- ផ្លូវជាតិលេខ ៤៨ ប្រភេទ បេទីមីណឺ ចំនួន ១ ខ្សែ ដែលភ្ជាប់ពីផ្លូវជាតិលេខ ៤ ទៅទីរួមខេត្តកោះកុង កាត់តាមទីតាំងរដ្ឋបាលឃុំអណ្ដូងទឹក ដែលមានប្រវែងសរុប ១៩.២៣៤,៧០ ម៉ែត្រ ។

- ផ្លូវលំក្រាលគ្រួសក្រហមមានប្រវែងសរុប ២៨.៤១៦,៦០ម៉ែត្រ ។

- ផ្លូវលំដីសឬផ្លូវថ្មើរជើងមានប្រវែងសរុប ៦០១,៣៩ ម៉ែត្រ ។

- ផ្លូវលំធម្មតាមិនទាន់លើកមានប្រវែងសរុប ៩.៧៩៣,២៩ម៉ែត្រ ដែលភ្ជាប់ពីភូមិ ១ ទៅភូមិ ១ នៅក្នុងឃុំទាំងមូល ហើយផ្លូវនេះប្រជាពលរដ្ឋអាចធ្វើដំណើរដោយថ្មើរជើង ដោយម៉ូតូ ឬរទេះ ។ ក្រៅពីនេះក៏នៅមានផ្លូវលំរទេះមួយចំនួនអាចសំរួលដល់ការដឹកជញ្ជូនផលិតផលរបស់ប្រជាពលរដ្ឋបានមួយចំនួនផងដែរ ។

- ផ្លូវរទេះ ឬ ថ្មើរជើង មានប្រវែងសរុប ៨៦.០៤៣,៤៨ ម៉ែត្រ ។

- កំពង់ចម្លងមានប្រវែង ១៧០ ម៉ែត្រ នៅព្រែកកន្ទួត និង ព្រែកតាអុក ( ផ្លូវ ០១ ខ្សែនេះក្រាលគ្រួសក្រហមភ្ជាប់ពីផ្លូវជាតិលេខ ៤៨ ត្រង់ចំណុចអូរម្កាក់ឆ្ពោះទៅឃុំថ្មសឆ្លងកាត់ភូមិជីមាល ប្រៃ ជីត្រេះ តាអុក តាមាយ និងភូមិប្រទាល ) ។

- ស្ពានបេតុងក្នុងឃុំអណ្ដូងទឹកតាមផ្លូវជាតិលេខ ៤៨ មាន ០៥ កន្លែង ប្រវែងសរុប ៣០៨ ម៉ែត្រ ។

*( តួលេខខាងលើទទួលបានពីផ្នែក GIS នៃសមាសភាគរៀបចំដែនដីខេត្តកោះកុង)*



## ១.៣. ស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន ៖

### ១.៣.១. ស្ថានភាពនៃការប្រើប្រាស់ដី ៖

ការប្រើប្រាស់ដីក្នុងឃុំអណ្តូងទឹកអាចចែកចេញជា ០៦ ប្រភេទសាមញ្ញមាន ដីលំនៅដ្ឋានភូមិ ដីកសិកម្ម ដីព្រៃឈើ ដីព្រៃកោងកាង ដីវាលស្មៅ-វាលស្បូវ ផ្ទៃទឹក ។

**តារាងប្រភេទប្រើប្រាស់ដីលំអិត**

| ល.រ | ការប្រើប្រាស់ដី | ផ្ទៃដី (ហ.ត | ចំណាក់ថ្នាក់មូលដ្ឋាន |
|---|---|---|---|
| ១ | ដីលំនៅដ្ឋានភូមិ | 216.7154 | |
| ២ | ហេដ្ឋារចនាសម្ព័ន្ធ | 8.7284 | |
| ៣ | ដីកប់ខ្មោច | 19.738 | |
| ៤ | ដីស្រូវវស្សា | 539.6982 | |
| ៥ | ដីស្រែជាមួយភូមិ | 147.0485 | |
| ៦ | ដីស្រែក្នុងបឹង ឬ អូរ | 35.2985 | |
| ៧ | ដីចំការដំណាំ | 107.0193 | |
| ៨ | ដីចំការឈើហូបផ្លែ | 451.7338 | |
| ៩ | ដីកសិកម្មពនេចរ | 367.3797 | |
| ១០ | ដីព្រៃស្រោង | 25,485.6112 | |
| ១១ | ដីព្រៃដុះតាមមាត់ទឹក( អូរឬព្រែក) | 31.5903 | |

| | | | |
|---|---|---|---|
| ១២ | ដីព្រៃដុះឡើងវិញ | 1,070.1137 | |
| ១៣ | ដីព្រៃលិចទឹក | 631.1302 | |
| ១៤ | ដីព្រៃលិចទឹក(ក្រាស់) | 45.2531 | |
| ១៥ | ដីព្រៃកោងកាង | 3,476.3266 | |
| ១៦ | ដីព្រៃកោងកាងស្តើង | 431.8622 | |
| ១៧ | ដីល្បាយព្រៃលាយដីចំការ | 3,381.4979 | |
| ១៨ | ដីវាលស្មៅ | 1,263.5136 | |
| ១៩ | ដីចំការបោះបង់ដុះស្មៅ | 40.4269 | |
| ២០ | វាលស្មៅលិចទឹក | 975.1736 | |
| ២១ | ដីព្រៃកម្ពោត | 915.2836 | |
| ២២ | ដីព្រៃកម្ពោតលាយដើមឈើធំៗ | 400.3579 | |
| ២៣ | ដីបឹង | 5.9993 | |
| ២៤ | អាង ឬ ទំនប់ | 8.7902 | |
| ២៥ | ស្រះ | 0.3698 | |
| ២៦ | ព្រែក ឬ អូរ | 13.9587 | |
| ២៧ | សមុទ្រ | 698.1989 | |
| ២៨ | ដីព្រៃកាប់ឆ្ការ | 25.1093 | |
| **ផ្ទៃដីសរុប** | | **40,793.9268** | |

*(ប្រភព:ផ្នែក GIS នៃមន្ទីរ ដនសស ខេត្តកោះកុង)*

### ១.៣.២. ស្ថានភាពនៃការកាន់កាប់គ្រប់គ្រងដី :

ស្ថានភាពនៃការកាន់កាប់ដី និងគ្រប់គ្រងដីនៅក្នុងឃុំអណ្តូងទឹក ក្រៅពីដីលំនៅដ្ឋាន ដីស្រែចំការ ដែលជាកម្មសិទ្ធិរបស់ឯកជនគឺសុទ្ធសឹងជាដីសាធារណៈរបស់រដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រងតាមស្ថាប័ន និងជំនាញផ្សេងៗគ្នាដូចជា :

- តំបន់ឧទ្យានជាតិបូទុមសាគរ គ្រប់គ្រងដោយក្រសួងបរិស្ថាន
- តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង គ្រប់គ្រងដោយក្រសួងបរិស្ថាន
- តំបន់ការពារ គឺតំបន់អភិរក្សព្រៃឈើ និងសត្វព្រៃ គ្រប់គ្រងដោយអង្គការវ៉ាយអេដស៍ និង រដ្ឋបាលព្រៃឈើ

នៅក្នុងឃុំអណ្តូងទឹកទាំងមូល ប្រជាជនរស់នៅក្នុងតំបន់ឧទ្យានជាតិបូទុមសាគរមួយផ្នែក រីឯមួយផ្នែកទៀតរស់នៅក្នុតំបន់ការពារ តំបន់អភិរក្សព្រៃឈើ និងសត្វព្រៃ គ្រប់គ្រងដោយអង្គការវ៉ាយអេដស៍ និង រដ្ឋបាលព្រៃឈើ (សូមបញ្ជាក់ថាប្រជាជនទាំងនេះរស់នៅតាំងពីបូរុមបូរាណមកម្លេះ) ដីក្រុមហ៊ុនដាំដំណាំអំពៅ ក្រុមហ៊ុនព្រៃសម្បទានធីពាណិជ្ជ ក្រុមហ៊ុនព្រៃសម្បទានតាឡាម ។

តារាងសង្ខេបស្ថានភាពកាន់កាប់ និងគ្រប់គ្រងដី

| ល.រ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហ.ត) | ផ្សេងៗ |
|---|---|---|---|
| ១ | តំបន់ឧទ្យានជាតិបូទុមសាគរ | 23,680.41 | |
| ២ | តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង | 554.44 | |
| ៣ | ដីក្រុមហ៊ុនព្រៃសម្បទានតាឡាម | 1,291.00 | |
| ៤ | ដីក្រុមហ៊ុនដាំអំពៅ | 241.34 | |
| ៥ | ដីក្រុមហ៊ុនព្រៃសម្បទានធីពានិជ្ជ | 12,704.54 | |
| **<u>ផ្ទៃដីសរុប</u>** | | **<u>38,471.73</u>** | |

*(ប្រភព:ផ្នែកGIS នៃមន្ទីរ ដនសស ខេត្តកោះកុង)*

### ១.៣.៣. ផលិតកម្មកសិកម្ម :

ឃុំអណ្តូងទឹកមានផ្ទៃដីកសិកម្មចំនួន ១.២៨០,៧៩៨៣ ហ.ត ក្នុងនោះដីស្រូវវស្សាមានចំនួន ៥៣៩,៦៩៨២ ហ.ត បានដាំដុះស្រូវវស្សាជាក់ស្តែង ៤២៤,៩០ ហ.ត ឃុំអណ្តូងទឹកបង្កបង្កើនផលស្រូវបានតែមួយរដូវប៉ុណ្ណោះគឺរដូវវស្សា ទិន្នផលស្រូវវស្សាជាមធ្យមក្នុង ១ ហ.ត ១,៥០ តោន សរុបបរិមាណផលិតផលស្រូវវស្សា (ប៉ាន់ស្មានក្នុងឆ្នាំ) ចំនួន ៦០០ តោន ។

- ផ្ទៃដីចំការស្រូវដែលបានដាំដុះជាក់ស្តែងចំនួន ១៧៥ ហ.ត ទិន្នផលស្រូវចំការជាមធ្យមក្នុង ១ហ.ត ១,៥០ តោន សរុបរិមាណផលិតផលស្រូវចំការ (ប៉ាន់ស្មានក្នុងឆ្នាំ ២៥០ តោន)
- ចំនួនផ្ទៃដីទឹកប្រៃហូរចូលចំនួន ១៥០ ហ.ត បច្ចុប្បន្នបានធ្វើទំនប់ការពារទឹកប្រៃ
- ផ្ទៃដីចំការចំនួន ៥៥៨,៧៥៣១ ហ.ត ក្នុងនោះមានចំការដូង ចំការស្វាយចន្ទី ចំការស្វាយ ចំការធូរេន ចំការសាវម៉ាវ ចំការមង្ឃុត ចំការដំណាំស្រូវ ចំការកៅស៊ូ

តារាងប្រភេទកសិកម្មសំខាន់ៗ និងទិន្នផលទទួលបាន ឆ្នាំ ២០០៨

| ល.រ | ប្រភេទកសិកម្ម | ផ្ទៃដី ហ.ត | | ផល/ទិន្នផល | |
|---|---|---|---|---|---|
| | | សរុប ហ.ត | ដាំបាន ហ.ត | ផលសរុប (តោន) | ទិន្នផល (តោន/ហ.ត) |
| ១ | ដំណាំស្រូវវស្សា | 539.6982 | 424.90 | 637.35 | 1.5 ត/1ហត |
| ២ | ដំណាំស្រូវចំការ | 175.00 | 175.00 | 262.50 | 1.5 ត/1ហត |
| ៣ | ដំណាំដំឡូងជ្វា | 1.00 | 1.00 | 1.20 | 1.2 ត/1ហត |
| ៤ | ដំណាំពោត | 0.50 | 0.50 | 0.30 | |
| ៥ | ដំណាំឈើហូបផ្លែ និងបន្លែគ្រប់មុខ | 558.7531 | 558.7531 | | |

*(តួលេខនេះដកស្រង់ចេញពីសៀវភៅឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៨)*

- បច្ចុប្បន្នការងារកសិកម្មដូចបានរៀបរាប់ខាងលើរួចមកហើយ គឺប្រជាពលរដ្ឋធ្វើស្រែចំការពឹងផ្អែកលើទឹកភ្លៀងទាំងស្រុង ។ បច្ចុប្បន្នឃុំនេះកំពុងដំណើរការស្តារប្រឡាយ លើកទំនប់ការពារទឹកប្រៃ និងឱ្យប្រជាពលរដ្ឋជ្រើសពូជស្រូវដែលមានទិន្នផលខ្ពស់ ហើយទាន់រដូវកាលដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងភូមិ និងឃុំទាំងមូល ។

<u>តារាងក្រឡាផ្ទៃតាមផលិតភាពដី និង ការប្រើប្រាស់ផលិតផល</u>

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា (ហិចតា) |
|---|---|---|---|
| 1 | **ដីមានផលិតភាពទាប** | | |
| | ដីចំការបោះបង់ដុះស្មៅ | | 40.00 |
| | ដីកប់ខ្មោច | | 18.00 |
| | ព្រៃកាប់ឆ្ការ | | 25.00 |
| | ចំការដំណាំ | | 107.00 |
| | ព្រៃលិចទឹក | | 631.00 |
| | ព្រៃលិចទឹកក្រាស | | 45.00 |
| | វាលស្មៅលិចទឹក | | 975.00 |
| | ល្បាយដីព្រៃលាយដីចំការ | | 3,155.00 |
| | វាលស្មៅ | | 1,061.00 |
| | ដីហេដ្ឋរចនាសម្ព័ន្ធ | | 5.00 |
| | បឹង | | 2.00 |
| | ដីព្រៃកោងកាង | | 2,766.00 |
| | ព្រៃស្រោង | | 19,085.00 |
| | ចំការឈើហូបផ្លែ | | 416.00 |
| | ស្រះ | | 0.31 |
| | ព្រៃកោងកាងស្តើង | | 381.00 |
| | អាងស្តុកទឹក | | 1.43 |
| | ស្រែក្នុងបឹង ឬ អូរ | | 6.68 |
| | ដីស្រែជាមួយភូមិ | | 147.00 |
| | ព្រៃដុះតាមមាត់ទឹក | | 31.60 |
| | អូរ ឬ ស្ទឹង | | 13.00 |
| | សមុទ្រ | | 620.00 |
| | ព្រៃដុះឡើងវិញ | | 560.00 |

| | | |
|---|---|---|
| | ព្រៃកម្ពោត | 802.00 |
| | ព្រៃកម្ពោតលាយដើមឈើធំមួយៗ | 214.00 |
| | កសិកម្មពនេចរ | 347.00 |
| | ដីលំនៅដ្ឋានភូមិ | 166.00 |
| | ដីស្រែវស្សា | 423.00 |
| 2 | **ដីមានផលិតភាពមធ្យម** | |
| | ដីវាលស្មៅ | 19.59 |
| | ដីព្រៃកោងកាង | 61.90 |
| | ព្រៃស្រោង | 1,083.00 |
| | ព្រៃកោងកាងស្តើង | 11.00 |
| | សមុទ្រ | 76.00 |
| | ព្រៃដុះឡើងវិញ | 159.00 |
| | កសិកម្មពនេចរ | 19.80 |
| 3 | **ដីមានផលិតភាពខ្ពស់** | |
| | ល្បាយដីព្រៃលាយដីចំការ | 140.78 |
| | វាលស្មៅ | 182.67 |
| | ព្រៃស្រោង | 5,317.00 |
| | អាងស្តុកទឹក | 7.00 |
| | ព្រៃក ឬ អូរ | 0.51 |
| | ព្រៃដុះឡើងវិញ | 351.40 |
| | ព្រៃកម្ពោត | 95.76 |
| | ព្រៃកម្ពោតលាយដើមឈើធំមួយៗ | 186.00 |
| | ដីស្រែវស្សា | 0.01 |

*(ប្រភពៈផ្នែក GIS នៃមន្ទីរ ដនសស ខេត្តកោះកុង)*

ផែនទីផលិតភាពដី ក្នុងឃុំអណ្តូងទឹក




### ១.៣.៤. ធនធានធម្មជាតិ

#### ១.៣.៤.១. ធនធានព្រៃឈើ

នៅឃុំអណ្តូងទឹកទាំងមូលមានធនធានព្រៃឈើទំហំសរុប ៥៧.០៨៩,៤០៦៩ ហ.ត ដែលស្ថិតនៅតំបន់អភិរក្សឧទ្យានជាតិបូទុមសាគរ និងដែនអភិរក្សវ៉ាយអេជ របស់រដ្ឋបាលព្រៃឈើ ។ ព្រៃឈើទាំងនេះបានផ្តល់សក្តានុពលមួយចំនួនសំរាប់ប្រយោជន៍សាធារណៈដូចជា ដើមគគីរខ្សាច់ ដូនចែម ត្រាច ធ្នុង ព្យួល ចំម៉ាស់ ផ្ចឹកឧត្តម កំញាណ ផ្ទៀកនាងដែង ជីវ៉ាយវែង សំពាក់សំឡី ។ អនុផលព្រៃឈើមានដូចជា ផ្តៅ វល្លិ៍រមៀត វល្លិ៍អន្ទង់ កន្ទុយដំរី ផ្សិតគគីរខ្សាច់ ផ្លែសេមាន់ ផ្លែសំរ៉ង់ ផ្លែគុយ ផ្លែព្រូស ផ្លែភ្ញៀវ ផ្លែក្រាល ផ្លែថ្កូវ ផ្លែសង្គម ផ្លែម៉ាក់ប្រាំង ផ្លែពួច ផ្លែព្រីង ជ័រទឹក ជ័ររ៉ុង ជ័រចុង ។ ប្រភេទសត្វព្រៃមានដូចជា ជ្រូកព្រៃ ឈ្លូស ប្រើស ជ្រូកព្រូល កាំប្រម៉ា អណ្តើក កន្ធាយ ពង្រូល ត្រកួត អន្សងកន្ទ្រង សំពោច ទន្សាយ មាន់ព្រៃ ខ្យង ស្វា ទោច រញ្ជី កំប្រុក ខ្ទីង ខ្លារខិន ខ្លាធំ ខ្លាឃ្មុំ ដំរី ក្រពើ ពូវាំង កងកេង ត្រដក់ននៀល កុកក្រៀល ប្រវឹក ទាព្រៃ ក្ងោក មាន់ទឹក ក្លំ សព្វ កំផ្លុក ពពូល ស្ទាំង ទីទុយ ខ្លែង មៀម ភេ ពស់ថ្លាន់ ពស់វែកពស់ពភ្លាក់ ពស់ចំណង ។ល។



### ១.៣.៤.២. ធនធានជលផល

ក្នុងឃុំអណ្តូងទឹកមានបឹងចំនួន ៥ កន្លែង និងតំបន់ពិសេស ២ កន្លែងទៀត នៅក្បាលព្រែកកន្ទួត ក្បាលព្រែកតាអុក និងសហគមន៍នេសាទ ១ កន្លែង ។

១- ត្រពាំងពងទឹក ប្រមាណជា ២០ ហ.ត

២- ត្រពាំងកូនសត្វ ប្រមាណជា ១៥ ហ.ត

៣- អាងទឹកជីត្រេះ ប្រមាណជា ៤៥ ហ.ត

៤- ត្រពាំងព្រៃ ប្រមាណជា ១,៥០ ហ.ត

៥- បឹងតាមាឃ ប្រមាណជា ១២៥ ហ.ត

៦- សហហគមន៍នេសាទប្រមាណជា ៩.៨០៩ ហ.ត ( ទិន្នន័យនេះនៅមានការកែសំរួល)

ក្នុងបឹងនីមួយៗ សំបូរទៅដោយធនធានជលផលដូចជា : ត្រីកន្ទ្រប់ ត្រីឆ្លាត ត្រីក្រាញ់ ត្រីរ៉ស់ ត្រីអណ្តែង ត្រីចង្វារ ត្រីឆ្ពិន ត្រីឆ្តោរ បង្កង ត្រីកន្ធរ ត្រីស្រកានាគ ត្រីក្រជនជ័យ ត្រីឆ្លូញ ត្រីកំភ្លាញ កំពិស ។ល។ ការនេសាទភាគច្រើនមានដូចជា មង សន្ទូច លប បង្កៃ ឈ្នៀង អង្រុត ឧបករណ៍ខុសច្បាប់មានដូចជា ស្បៃមុង ដែកឆក់ បូម ដាក់ថ្នាំបំពុល ។ ចំពោះធនធានជលផលសមុទ្រ បច្ចុប្បន្នការថយចុះស្ទើរតែគ្រប់ប្រភេទ ដែលបណ្តាលមកពីការប្រើឧបករណ៍ខុសច្បាប់ដូចជា ទូកដុន ទូកអូស មកពីក្រៅឃុំផង ក្នុងឃុំផង ។ បច្ចុប្បន្នរដ្ឋបាលជលផលបានបង្កើតសហគមន៍នេសាទ និង សហគមន៍ចិញ្ចឹមត្រីតាមបឹងធម្មជាតិ និង ត្រពាំងធម្មជាតិ ។



*(ប្រភពៈខណ្ឌរដ្ឋបាលជលផលខេត្តកោះកុង)*

### ១.៣.៥. ធនធានរ៉ែ

ក្នុងឃុំអណ្តូងទឹកមានតែប្រភេទរ៉ែដូចជា ខ្សាច់ ថ្ម គ្រួសក្រហម ប៉ុណ្ណោះ រ៉ែថ្ម និងរ៉ែគ្រួសក្រហម ភាគច្រើននៅតាម តំបន់ភ្នំ រីឯរ៉ែខ្សាច់ភាគច្រើននៅតាមព្រែក អូរ ។

មានក្រុមហ៊ុន ហ្គ្រីនអ៊ិនវ៉ាយរិនមិនគ្រុប បានមកវិនិយោគរ៉ែខ្សាច់នៅក្នុងឃុំអណ្តូងទឹក ២ កន្លែង ពីស្ពានអណ្តូងទឹកដល់មាត់ពាមក្រៅ មួយកន្លែងទៀតពីចំណុចព្រែកតានងដល់ឃុំជីផាតស្រុកថ្មបាំង ។ ការវិនិយោគរ៉ែខ្សាច់នេះមូលដ្ឋានគ្មានប្រាក់ចំណូលទេគឺចំណូលសំរាប់រដ្ឋ ។

## ១.៤. ទីផ្សារ និងខ្សែសង្វាក់ផលិតផល :

### ១.៤.១. ទីផ្សារ និងតំលៃកសិផល អនុផលព្រៃឈើ និងផលនេសាទ

| | | | |
|---|---|---|---|
| - ផ្លែសំរ៉ង់ | ១ គ.ក្រ | មានតំលៃ | ៥.០០០៛ |
| - ផ្តៅ | ១ ដើម | មានតំលៃ | ៥០០៛ |
| - ជ័រចុង | ១ គ.ក្រ | មានតំលៃ | ៥០.០០០៛ |
| - វល្លិ៍រមៀត | ១ គ.ក្រ | មានតំលៃ | ២០០៛ |
| - បង្គារ | ១ គ.ក្រ | មានតំលៃ | ១២.០០០៛ |
| - បង្កង | ១ គ.ក្រ | មានតំលៃ | ៣០.០០០៛ |
| - ក្តាមថ្ម | ១ គ.ក្រ | មានតំលៃ | ១៨.០០០៛ |
| - ត្រីឆ្កង់ | ១ គ.ក្រ | មានតំលៃ | ៨.០០០៛ |
| - ត្រីរ៉ស់ | ១ គ.ក្រ | មានតំលៃ | ១០.០០០៛ |

- ត្រែងឈាម ១ គ.ក្រ មានតំលៃ ៣.០០០៛
- ត្រីក្បក ១ គ.ក្រ មានតំលៃ ៤.០០០៛
- ខ្យងហូល ១ គ.ក្រ មានតំលៃ ២.០០០៛

ចំពោះផលិតផលទាំងអស់នេះជាទូទៅមានទីផ្សារក្នុងមូលដ្ឋាន និងទៅលក់ក្រៅមូលដ្ឋានឃុំអណ្តូងទឹក។ ផលិតផលនាំចូលមកឃុំអណ្តូងទឹកមានដូចជា អង្ករ ស្កស ស្កក្រហម បន្លែ ជីគីមី ថ្នាំសំលាប់សត្វល្អិត និងផលិតផលសំភារៈផ្សេងៗជាច្រើនទៀត ។

*(ប្រភព:ឯកសារព័តិមានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

### ១.៤.២. ខ្សែសង្វាក់ និង ចរាចរផលិតផល :

នៅក្នុងឃុំអណ្តូងទឹកប្រជាពលរដ្ឋមួយចំនួនមានម៉ាស៊ីនកិនស្រូវតូចៗជាលក្ខណៈគ្រួសារ ពួកគាត់បានទិញស្រូវស្តុកទុក ហើយបញ្ចេញលក់វិញនៅរដូវវស្សា ពួកគាត់មិនបាននាំស្រូវ ឬអង្ករលក់ចេញទៅក្រៅស្រុកទេ គឺពួកគាត់បញ្ចេញលក់តែនៅក្នុងភូមិ ឃុំ របស់ពួកគាត់ ពីព្រោះក្នុងឃុំអណ្តូងទឹកនេះធ្វើស្រែទទួលផលបានតិចតួចមិនអាចទ្រទ្រង់ស្បៀងក្នុងស្រុកបានឡើយ ។

- ចំពោះចរាចរផលនេសាទនៅក្នុងមូលដ្ឋានឃុំគឺ អនុវត្តទៅតាមស្ថានភាពរបស់អ្នកនេសាទ ដែលក្នុងនោះប្រជាពលរដ្ឋដែលរស់នៅតាមដងព្រែក និង ឆ្នេរសមុទ្រមានសកម្មភាពដូចខាងក្រោម :
  - o ឈ្មួញប្រមូលទិញពីអ្នកនេសាទមកស្តុកទុកក្លាសេតាមស្តង់នៅក្នុងមូលដ្ឋាន
  - o ឈ្មួញប្រមូលទិញត្រីតាមស្តង់ដឹកយកទៅលក់នៅក្រុងព្រះសីហនុ នៅទីរួមខេត្តកោះកុង និងនៅទីក្រុងភ្នំពេញ ។
- ផលដំណាំចំការដូចជា :

ស្វាយ ខ្នុរ សាវម៉ាវ ធូរេន មង្ឃុត ដូង ផលិតផលទាំងនោះបានលក់ដូរនៅក្នុងមូលដ្ឋាន មិនទាន់បានទទួលទិន្នផលខ្ពស់សំរាប់នាំចេញឡើយ ។

- ដំណាំស្វាយចន្ទីគឺមានឈ្មួញទិញស្តុកទុកសំរាប់នាំចេញទៅលក់នៅក្រៅប្រទេសដូចជាប្រទេសថៃ និងប្រទេសវៀតណាម តំលៃទិញក្នុងមូលដ្ឋានគឺ ១ គ.ក្រ ១.៨០០៛ ឬ ២.២០០៛ (ក្នុងតំលៃមធ្យម) ។

### ១.៤.៣. ឱកាស_ឧបសគ្គ

- ធនធានព្រៃលិចទឹក និងព្រៃកោងកាង

ចំពោះធនធានជលផលគឺជាផ្នែកមួយដែលមានសារៈសំខាន់ ដល់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចសង្គម ព្រៃកោងកាងគឺជាជំរក និងចំណីអាហារយ៉ាងសំខាន់សំរាប់ពួកសត្វ ឬត្រីគ្រប់ប្រភេទ ហើយប្រជាពលរដ្ឋនៅឃុំអណ្តូងទឹក និងឃុំផ្សេងៗទៀតអាចទាញយកផលនេសាទពីតំបន់នេះយកមកផ្គត់ផ្គង់ជីវភាពគ្រួសារបានមួយផ្នែក ។ ទន្ទឹមនេះដែរផលនេសាទមានការថយចុះដោយសារមូលហេតុ :

- កំណើនរបស់ប្រជាពលរដ្ឋ
- ការនេសាទហួសកំរិត

- ការប្រើឧបករណ៍ខុសច្បាប់ដូចជា :

ឧបករណ៍ឆក់ បំពុល ទូកអូស ឌុន ឈិប រុញ ។ល។

- ឃុំអណ្ដូងទឹកបានបង្កើតសហគមន៍នេសាទមួយ ដែលមានទីតាំងនៅភូមិតាមាឃ សហគមន៍នេសាទនេះមួយផ្នែកជាប់ព្រៃលិចទឹក នៃតំបន់ការពារធម្មជាតិ ។ ការបង្កើតសហគមន៍ជាឱកាសមួយក្នុងការការពារធនធានធម្មជាតិ និងជីវចំរុះឱ្យមាននិរន្តរភាពព្រមទាំងបង្កើនការរកប្រាក់ចំណូលរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ ។

# ជំពូក ២

# ការវិភាគពីតំរូវការសំរាប់អនាគត ឧបស័គ្គ និងសក្តានុពល

## ២.១. តំបន់សើម

តំបន់ព្រៃលិចទឹក ឆ្នេរសមុទ្រ និងដងព្រែកមួយចំនួនជាតំបន់ដីសើមដែលស្ថិតនៅក្នុងតំបន់អភិរក្សឧទ្យានជាតិបូទុមសាគរ និងរដ្ឋបាលព្រៃឈើដែលជាតំបន់មានជីវចំរុះយ៉ាងពិសេស និងជាជំរកត្រីពងកូន ។ សព្វថ្ងៃតំបន់នេះសំបូរទៅដោយព្រៃកោងកាង និង ព្រៃលិចទឹកមួយចំនួនដែលស្ថិតក្នុងដែនការពារអភិរក្សនៃឧទ្យានជាតិបូទុមសាគរ ។ ហើយតំបន់ព្រៃឈើ និង ព្រៃលិចទឹកនៅក្នុងឃុំអណ្តូងទឹកមានការការពារគ្រប់គ្រង

- តំបន់ព្រៃឈើ និង ព្រៃលិចទឹកនៅក្នុងឃុំអណ្តូងទឹកមានការការពារ និង គ្រប់គ្រងដោយក្រុមហ៊ុន និង ស្ថាប័នរដ្ឋដែលពាក់ព័ន្ធមានដូចជា :
    - o តំបន់ការពារអភិរក្សឧទ្យានជាតិបូទុមសាគរ ( ក្រសួងបរិស្ថាន) ទំហំ ២៣.៦៨០,៤១ ហ.ត
    - o តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង ( ក្រសួងបរិស្ថាន) ទំហំ ៥៥៤,៤៤ ហ.ត
    - o តំបន់អភិរក្សព្រៃឈើ ( រដ្ឋបាលព្រៃឈើ និង វ៉ាយអេដ)
    - o តំបន់សហគមន៍នេសាទតាមាយ ( មានស្នាក់ការនៅភូមិតាមាយ) ទំហំ ៩.៨០៩ ហ.ត
    - o ដីក្រុមហ៊ុនដាំដំណាំអំពៅ ទំហំ ២៤១,៣៤ ហ.ត
    - o ក្រុមហ៊ុនព្រៃសម្បទានធីពាណិជ្ជ ទំហំ ១២.៧០៤,៥៣ ហ.ត
    - o ក្រុមហ៊ុនព្រៃសម្បទានតាឡាម ទំហំ ១.២៩១,00 ហ.ត

*( ប្រភព:ផ្នែក GIS នៃមន្ទីរ ដនសស ខេត្តកោះកុង)*

## ២.២. ការប្រឈម/ឧបស័គ្គ

- នៅក្នុងឃុំអណ្តូងទឹកមានបញ្ហាប្រឈមជាច្រើន ហើយបញ្ហាប្រឈមនោះមានពាក់ព័ន្ធដល់ធនធានធម្មជាតិ ក៏ដូចជាការប្រើប្រាស់ដីដែលមានដូចខាងក្រោម :
- និយាយពីមូលហេតុជាឧបស័គ្គដូចជាប្រជាជនមួយចំនួនលួចកាប់ព្រៃឈើរានយកដីធ្វើកម្មសិទ្ធិទាំងព្រៃលិចទឹក និងព្រៃភ្នំដោយខុសច្បាប់ ។
- ផលនេសាទមានការថយចុះនៅតំបន់សមុទ្រ និងតំបន់ទឹកសាប
- ប្រព័ន្ធប្រឡាយស្រោចស្រពមិនអាចបំរើតម្រូវការទឹកជូនប្រជាជនបានគ្រប់គ្រាន់
- ដីខ្សោះជីវជាតិ និងដំណាំមួយចំនួនត្រូវសត្វល្អិតបំផ្លាញ
- មិនទាន់មានបច្ចេកទេសផ្នែកកសិកម្មគ្រប់គ្រាន់
- កំលាំងអូសទាញមិនគ្រប់គ្រាន់ ព្រមទាំងមានជំងឺរវៀងរាល់ឆ្នាំ
- ទិន្នផលស្រូវចុះទាបប្រជាពលរដ្ឋមួយចំនួនធ្វើស្រែហូបមិនគ្រប់គ្រាន់ទិញអង្ករនៅទីផ្សារបន្ថែម ។

## ២.៣. កំណត់តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្រ្តឃុំអណ្តូងទឹក

នៅក្នុងដំណើរការនៃការអភិវឌ្ឍន៍គោលដៅជាយុទ្ធសាស្ត្រ ឃុំបានធ្វើការលើកឡើងនូវគម្រោងផែនការសំរាប់ពេលអនាគតដែលក្នុងនោះត្រូវបានកំណត់នូវផែនការជាអាទិភាពដូចខាងក្រោម :

- ការកសាងផ្លូវប្រវែង ៤.០០០ម ជាបឋមត្រូវបានកំណត់យកការជួសជុលផ្លូវចាស់ និងការកសាងផ្លូវថ្មី ដែលក្នុងនោះរួមមាន : ការលើកផ្លូវដីស ការក្រាលគ្រួសក្រហម ការចាក់បេតុងលើផ្លូវគ្រួសក្រហម ហើយនឹងការរៀបចំសហគមន៍ថែទាំផ្លូវដើម្បីធានាដល់ការប្រើប្រាស់មានភាពយូរអង្វែង ។

- ឃុំមានគំរោងកសាងស្ពានកាត់ផ្លូវ ២ កន្លែង គឺព្រែកកន្ទួត និងព្រែកតាអុក ផ្លូវ ១ ខ្សែនេះគឺភ្ជាប់ពីផ្លូវជាតិលេខ ៤៨ នៅចំណុចអូរម្កាក់ ឆ្ពោះទៅឃុំថ្មស ឆ្លងកាត់ភូមិជីមាល, ប្រៃ, ជីត្រេះ, តាអុក, ប្រទាល ក្នុងឃុំអណ្តូងទឹក ។

- ដើម្បីធានានូវការប្រើប្រាស់ទឹក និងដើម្បីជំរុញការលើកកំពស់ទិន្នផលស្រូវទៅអនាគត ឃុំមានគោលការណ៍ក្នុងការរៀបចំស្តារត្រពាំង ប្រឡាយ និងការកសាងប្រឡាយមេ ប្រឡាយរង ហើយអនុវត្តបានកត្តានេះយើងអាចជំរុញដល់ការធ្វើស្រែបង្កើនរដូវផងដែរ ។

- បច្ចុប្បន្ននៅឃុំអណ្តូងទឹកទាំងមូលពុំទាន់ធានាបានូវការប្រើប្រាស់ទឹកស្អាត និងការថែទាំសុខភាពអនាម័យនៅឡើយ ជាបណ្តើរៗការយល់ដឹងពីប្រជាពលរដ្ឋបាននឹងកំពុងចាប់អារម្មណ៍ទៅលើការសាងសង់អណ្តូងទឹក ហើយជាអាទិភាព ឃុំក៏មានគំរោងផែនការក្នុងការកសាងអណ្តូងលូ អណ្តូងស្នប់ និងធុងចម្រោះ សំរាប់បំរើឱ្យការប្រើប្រាស់ទឹកស្អាត និង ជំរុញការកសាងបង្គន់អនាម័យគ្រប់លំនៅដ្ឋានជាទូទៅក្នុងមូលដ្ឋានឃុំ ។

- នៅក្នុងការគាំទ្រលើការសិក្សាអប់រំ ឃុំបានកំណត់ជាគោលការណ៍ក្នុងការសាងសង់នូវអគារសិក្សាបន្ថែម នៅលើទីតាំងថ្មីមួយកន្លែងគឺនៅភូមិជីត្រេះ ថ្នាក់បឋមសិក្សា ១ ខ្នង ១ បន្ទប់ ធ្វើអំពីឈើ ឃុំបានសាងសង់សាលាបឋមសិក្សា ១ ខ្នង ៤ បន្ទប់ ធ្វើអំពីថ្ម នៅលើទីតាំងចាស់ក្នុងភូមិតាមាយ ។

- ចំពោះសាលាមត្តេយ្យពុំទាន់មានទីតាំងសាលាដាច់ដោយឡែកទេ ក្នុងឃុំអណ្តូងទឹកមានថ្នាក់មត្តេយ្យ ១ ថ្នាក់ស្ថិតក្នុងសាលាបឋមសិក្សាអណ្តូងទឹក ។ នៅក្នុងឃុំអណ្តូងទឹកមានសាលាបឋមសិក្សា ៧ ខ្នង មានទីតាំងនៅភូមិអណ្តូងទឹក ៤ ខ្នង នៅភូមិតាមាយ ១ ខ្នង នៅភូមិប្រទាល ១ ខ្នង នៅភូមិជីត្រេះ ១ ខ្នង ។ ចំណែកឯអនុវិទ្យាល័យ និងវិទ្យាល័យមាន ២ ខ្នង ស្ថិតក្នុងទីតាំងតែមួយ គឺក្នុងភូមិអណ្តូងទឹក ។ ជាមួយគ្នានេះដែរឃុំនៅបានចាប់អារម្មណ៍ទៅលើការបើកថ្នាក់អក្ខរកម្មនៅតាមភូមិនៅពេលយប់ដោយប្រើប្រាស់ផ្ទះប្រជាពលរដ្ឋណាដែលមានទីធ្លាធំទូលាយ ។

- ចំពោះវិស័យសុខភាពសាធារណៈ នៅក្នុងឃុំមានមណ្ឌលសុខភាពមួយកន្លែង ២ អគារ ប៉ុន្តែមិនអាចបំរើសេវាកម្មជូនប្រជាពលរដ្ឋបានគ្រប់គ្រាន់នៅឡើយទេ ដូច្នេះជាគោលការណ៍ឃុំបានលើកគំរោងផែនការកសាងប៉ុស្តិ៍សុខភាពនៅតាមភូមិ គឺស្ថិតក្នុងភូមិប្រទាលលើទីតាំងគំរោងរបស់ឃុំ ។

- នៅក្នុងការថែរក្សាធនធានធម្មជាតិ ឃុំបានធ្វើការចាប់អារម្មណ៍ទៅលើការស្តារត្រពាំង ស្រះ ប្រឡាយមេ ប្រឡាយរង ការដាំដើមកោងកាងឡើងវិញ ហើយនឹងការរៀបចំបោះបង្គោលព្រំប្រទល់ព្រៃលិចទឹក ត្រពាំង សហគមន៍ឃុំឱ្យត្រឹមត្រូវ និងទាន់ពេលវេលា ដើម្បីជៀសវាងការជ្រៀតចូលពីជនខិលខូច ។ ការអនុវត្តន៍បាននូវយុទ្ធសាស្ត្រនេះ អាច

ផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនក្នុងតំបន់ ក្នុងការបង្កើនប្រាក់ចំណូលតាមរយៈការទាញយកផលពីធនធានទាំងនេះ ។

## ២.៤. គំរូចការសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១. អត្រាកំណើន

ស្ថានភាពអត្រាកំណើនប្រជាជននៅក្នុងឃុំអណ្តូងទឹក បើពិនិត្យទៅតាមបណ្តាឆ្នាំនីមួយៗ ឃើញថាមានការថយចុះគួរឱ្យកត់សំគាល់ ព្រោះប្រសិនបើមើលទៅលើបណ្តាឆ្នាំជាអាទិ៍ដូចជាឆ្នាំ ២០០៦ ចំនួនគ្រួសារ ១.០៨០ ចំនួនប្រជាពលរដ្ឋ ៥.៦៦៧ នាក់ ឆ្នាំ ២០០៧ ចំនួនគ្រួសារ ១.០៥៧ ចំនួនប្រជាពលរដ្ឋ ៥.៨៨១ នាក់ ឆ្នាំ ២០០៨ ចំនួនគ្រួសារ ១.០៤៩ ចំនួន ប្រជាពលរដ្ឋ ៥.៥៣២ នាក់ កត្តាទាំងនេះតាមការសាកសួរព័តិមានគឺបណ្តាលមកពីការធ្វើចំណាកស្រុកចេញទៅរកមុខរបរនៅក្រៅមូលដ្ឋាន ។ ពិតមែនតែក្នុងឃុំអណ្តូងទឹកមានការថយចុះនៃចំនួនគ្រួសារ និងចំនួនប្រជាពលរដ្ឋក៏ប៉ុន្តែនៅមានគ្រួសារមួយចំនួនឥតមានដីលំនៅដ្ឋាន និងដីកសិកម្មដែរ ហើយគ្រួសារមួយចំនួនទៀតមានដីកសិកម្មមិនគ្រប់គ្រាន់ដែរ ។ បើសិនជាពិនិត្យមើលទៅលើកុមារ គឺមានកុមារខ្លះបានចូលរៀន ហើយកុមារខ្លះទៀតមិនបានចូលរៀនដោយសារផ្ទះឆ្ងាយពីសាលា ឬដោយសារជីវភាពគ្រួសារជួបការលំបាក ។ ហើយក្នុងនោះដែរចំពោះដីធ្លីនៅក្នុងឃុំក៏មានការខ្វះខាតដីធ្លីក្នុងការពង្រីកលើវិស័យកសិកម្មដែរ ដូច្នេះធ្វើឱ្យយើងត្រូវមានការកត់សំគាល់ទៅលើសក្តានុពលមួយចំនួនដូចជាលទ្ធភាពនៃការពង្រីកអគារសិក្សា ការបង្កើនមុខរបរ ការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្ម ការរៀបចំប្រព័ន្ធស្រោចស្រព ការអភិរក្សនូវធនធានធម្មជាតិ និងកំណត់នៃការប្រើប្រាស់ធនធានឱ្យបានសមស្របទើបបានល្អ ។

**តារាងការគណនាអត្រាកំណើនមធ្យម**

| ចំនួនគ្រួសារ ប្រ/ជ | 2006 | 2007 | 2008 | កំនើនមធ្យម | កំនើន/ឆ្នាំ |
|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | 1,080 | 1,057 | 1,049 | | |
| អត្រាកំណើនគ្រួសារ | 0.4% | -2.1% | -0.83% | -9% | 10 គ្រួសារ |
| ចំនួនប្រជាជនសរុប | 5667 | 5881 | 5532 | | |
| អត្រាកំនើន ប្រ/ជ | 6.1% | 3.8% | -5.9% | 2.2% | 122 នាក់ |

*( តួលេខដកស្រង់ចេញពីឯកសារព័តិមានស្តីពីស្ថានភាពឃុំ ឆ្នាំ ២០០៨)*

នៅក្នុងអត្រានៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋនៅក្នុងអំឡុងឆ្នាំ ២០០៦ ដល់ឆ្នាំ ២០០៧ ឃើញថាមានការថយចុះប្រមាណ ២៣ គ្រួសារ ប៉ុន្តែប្រជាជនមានការកើនឡើង ២១៤ នាក់ ហើយពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០០៨ មានការថយចុះប្រមាណ ៨ គ្រួសារ បើពិនិត្យទៅលើចំនួនប្រជាពលរដ្ឋឆ្នាំ ២០០៨ ឃើញថាមានការថយចុះប្រមាណ ៣៤៩នាក់ កត្តាបំរែបំរួលខាងលើបណ្តាលមកពីប្រជាជនមានការយល់ដឹងពីកម្មវិធីពន្យាកំណើត មួយផ្នែកទៀតបណ្តាលមកពីបំរែបំរួលផ្នែកសេដ្ឋកិច្ចតំបន់ ដូច្នេះប្រជាពលរដ្ឋនៅក្នុងឃុំមានការប្រែប្រួលតួលេខពីមួយឆ្នាំទៅមួយឆ្នាំ ។ ប៉ុន្តែសព្វថ្ងៃកំណើនសិស្សមានការកើនខុសពីឆ្នាំមុនៗ ។

### ២.៤.១.២. ការធ្វើចំណោលប្រជាសាស្ត្រ

**តារាងការធ្វើចំណោលប្រជាសាស្ត្រ**

| ស្ថិតិតាមក្រុមអាយុ | ឆ្នាំ ២០១២ | | ឆ្នាំ ២០១៧ | | ឆ្នាំ ២០២២ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | |
| អាយុក្រោម ០៥ ឆ្នាំ | 649 | 306 | 714 | 337 | 780 | 368 | |
| អាយុ ០៥ ឆ្នាំ | 177 | 59 | 195 | 65 | 213 | 71 | |
| អាយុពី ៦-១១ ឆ្នាំ | 781 | 395 | 861 | 435 | 940 | 475 | |
| អាយុពី ១២-១៤ ឆ្នាំ | 508 | 259 | 560 | 285 | 611 | 311 | |
| អាយុពី ១៥-១៧ ឆ្នាំ | 486 | 215 | 536 | 237 | 585 | 259 | |
| អាយុពី ១៨-២៤ ឆ្នាំ | 848 | 377 | 934 | 415 | 1020 | 453 | |
| អាយុពី ២៥-៦០ ឆ្នាំ | 2,254 | 1,033 | 2,482 | 1,137 | 2,710 | 1,242 | |
| អាយុពី ៦១ ឡើងទៅ | 317 | 118 | 349 | 129 | 381 | 141 | |
| ចំនួន ប្រ/ជ សរុប | 6,020 | 2,762 | 6,631 | 3,040 | 7,240 | 3,320 | |
| ចំនួនគ្រួសារសរុប | 1,142 | | 1,258 | | 1,373 | | |

អត្រាកំណើនប្រជាជននៅក្នុងឃុំអណ្តូងទឹក បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំម្តង សំរាប់រយៈពេល ១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាជនមធ្យម ២,២ % ក្នុងនោះស្មើនឹង ១២២ នាក់ ក្នុង ១ ឆ្នាំ ហើយនឹង ១% ស្មើនឹង ១០ គ្រួសារ ក្នុង ១ ឆ្នាំ នោះបើពិនិត្យទៅលើបរិមាណផ្ទៃដីដែលអាចប្រើប្រាស់បាននៅមានកំរិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៍ដល់ការអភិវឌ្ឍន៍ដែរ ព្រោះអត្រាកំណើនរបស់ប្រជាជននៅក្នុងឃុំអណ្តូងទឹកគឺវាពាក់ព័ន្ធការអភិវឌ្ឍន៍លើធនធានមនុស្សដែលមាននៅក្នុងឃុំ ពិសេសបរិមាណដីសំរាប់ធ្វើកសិកម្ម និងបច្ចេកទេសក្នុងការបង្កើនផលិតផលដើម្បីបំរើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងឃុំ ។

### ២.៤.២. តំរូវការសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋាននៅជនបទ គឺសំដៅទៅដល់ដីសំរាប់ប្រើប្រាស់ដូចជាសង់លំនៅដ្ឋាន និងសំរាប់ដាំដំណាំរួមផ្សំ ក្នុងនោះគិតពីឆ្នាំ ២០០៨ ជាឆ្នាំគោលដែលមានទំហំដីលំនៅដ្ឋាន ២១៦,៧១៩៤ ហ.ត សំរាប់ប្រជាជន ១.០៤៩ គ្រួសារ ដូច្នេះទំហំដីសំរាប់ ១ គ្រួសារគិតជាមធ្យមគឺ ០,២១ ហ.ត ទំហំនេះអាចសមស្របសំរាប់សង់លំនៅដ្ឋាន ។

- តំរូវការលំនៅដ្ឋានសំរាប់ឆ្នាំ ២០២២ គឺមាន :

  ចំនួនកំណើនគ្រួសារនៅឆ្នាំ ២០២២

- ចំនួនកំណើនគ្រួសារឆ្នាំ ២០២២ = ៣២៤ គ្រួសារ x ០,២១ ហ.ត = ៦៨,០៤ ហ.ត

**សរុប = ៦៨,០៤ ហ.ត**

### ២.៤.៣. តំរូវការដីកសិកម្ម

តំរូវការដីសំរាប់ធ្វើកសិកម្ម គឺរួមមានដីសំរាប់ស្រែវស្សា និងចំការដំណាំសំរាប់ឆ្នាំគោល គឺឆ្នាំ ២០០៨ មានទំហំ ១.២៨០,៧៩៨៣ ហ.ត សំរាប់ប្រជាជនសរុប១.០៤៩គ្រួសារ ដូច្នេះទំហំដីគិតជាមធ្យមក្នុងមួយគ្រួសារមាន១,២២ ហ.ត។ តែប្រជាជននៅក្នុងឃុំអណ្តូងទឹកមានមុខរបរសំខាន់មួយចំនួនដូចជាមុខរបរនេសាទ ។

- តាមស្ថិតិឆ្នាំ ២០០៨ ប្រជាពលរដ្ឋផ្អែកលើវិស័យកសិកម្មមានប្រមាណ ៥៦២គ្រួសារ ដែលអាចមានដីមធ្យមទំហំ ២,២៧ ហ.ត ហើយដីនេះសមស្របសំរាប់ប្រជាជនក្នុង ១ គ្រួសារ ។

តំរូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

- ចំនួនគ្រួសារដែលបច្ចុប្បន្នពុំទាន់មានដីកសិកម្ម = ៨២ គ្រួសារ x ២,២៧ ហ.ត = ១៨៦,១៤ ហ.ត
- គ្រួសារដែលមានដីស្រែតិចជាង ១ ហិចតាចំនួន ១៧១ គ្រួសារ x ២ = ៣៤២ ហ.ត
- កំណើនគ្រួសារឆ្នាំ ២០២២

  ៣២៤ គ្រួសារ x ២.២៧ ហ.ត = ៧៣៥,៣៨ ហ.ត
- សរុប = ១.២៦៣,៥២ ហ.ត

ខាងលើនេះជាការវិភាគទំហំដី តែបើយើងវិភាគទៅតាមចំនួនប្រជាជនផ្ទៃដីដាំដំណាំស្រូវគឺយើងឃើញថាទិន្នផលស្រូវក្នុង ១ ឆ្នាំ ១ ហ.តស្មើ ១,៥ តោន ហើយប្រជាជនក្នុង ១ នាក់ ត្រូវការស្រូវតែ ២៣០ គ.ក្រ ក្នុង ១ ឆ្នាំ បើតាមស្ថិតិផ្ទៃដីស្រែវស្សា ដីស្រែជាមួយភូមិ និងដីស្រែក្នុងអូរ ឬ បឹង ឃុំសរុបប្រមាណ ៦៨៦,៧៥ ហ.ត ទទួលបានផលស្រូវ ១.០៣០,១៣ តោន ។ ហើយតំរូវការសំរាប់ប្រជាជនឆ្នាំគោល ២០០៨ ប្រមាណ ៥.៥៣២ នាក់ ត្រូវការស្រូវជាក់ស្តែង ចំនួន ១.២៧២,៣៦ តោន ដូច្នេះតំរូវការស្រូវសំរាប់ផ្គត់ផ្គង់ការហូបចុកនៅមានកង្វះខាតប្រមាណ ២៤២,២៣ តោន ស្មើ ១៩,០៤%នៃតំរូវការជាក់ស្តែងក្នុងឆ្នាំគោល ។ តែបរិមាណស្រូវដែលផលិតបាននេះធ្វើត្រឹមតែមួយរដូវកាលនឹងនៅពុំទាន់បានអនុវត្តទៅតាមបច្ចេកទេសកសិកម្ម ប.វ.ស (ប្រពលវប្បកម្មដំណាំស្រូវ) នៅឡើយទេ តែប្រសិនបើបច្ចេកទេស ប.វ.ស ត្រូវបានផ្សព្វផ្សាយ និង អនុវត្តដោយកសិករនៅក្នុងឃុំទាំងមូល នោះបរិមាណស្រូវក្នុង ១ ហិចតា ទាបបំផុតអាចកើនដល់ ២,២ តោន ដូចនេះនៅពេលអនាគត ឆ្នាំ ២០២២ ប្រជាជនមានការកើនឡើងដល់ ៧.២៤០ នាក់ ( ១៣០,៨៧ %) ត្រូវការស្រូវសំរាប់ការហូបចុកប្រមាណ ១.៦៦៥,២០ តោន ដែលត្រូវប្រើប្រាស់ដីស្រែចំនួន ៧៥៧ ហិចតា ដូច្នេះបើប្រៀបធៀបទៅនឹងដីស្រែដែលមានបច្ចុប្បន្ន ឃុំនៅខ្វះផ្ទៃដីដាំស្រូវចំនួន ៧០,២៥ ហិចតាបន្ថែមទៀតដើម្បីឱ្យការផ្គត់ផ្គង់ស្រូវនៅក្នុងមូលដ្ឋានបានគ្រប់គ្រាន់តាមតំរូវការ និងឈានទៅរកការលក់ចេញទៅទីផ្សារខាងក្រៅបាន ការគិតគូរក្នុងការពង្រីកដីស្រែអនាគតគួរបន្ថែមលើផ្ទៃដីស្រែបច្ចុប្បន្នក្នុងទំហំប្រមាណ ៥៨០,១៥ ហិចតា ។ដីស្រែដែលអាចពង្រីកនៅថ្ងៃអនាគតមានតែ ៤៧៤ ហិចតាមិនគ្រប់គ្រាន់តាមតំរូវការអនាគតបានឡើយ ។ ដូច្នេះគ្រួសារដែលខ្វះដីកសិកម្ម ឃុំទុកបញ្ចូលគ្រួសារទាំងនោះនៅក្នុងដីសម្បទានសង្គមកិច្ចដែលឃុំបានគ្រោងទុក ។

### ២.៤.៤. តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និង ធនធានធម្មជាតិ

នៅក្នុងឃុំអណ្តូងទឹក មានធនធានធម្មជាតិជាច្រើនដូចជា ព្រៃលិចទឹក ព្រៃកោងកាង ព្រៃលិចទឹកជាប់មាត់ព្រែក ព្រៃភ្នំ វាលស្មៅ បឹង អូរ ដែលបានកំណត់នៅក្នុងតំបន់រសើប និងមួយចំនួនស្ថិតក្នុងតំបន់សហគមន៍ ព្រមទាំងដីព្រៃមួយ

ចំនួនទៀតស្ថិតក្នុងតំបន់អភិរក្ស ។ តំបន់អភិរក្សនៃតំបន់ការពារធម្មជាតិទាំងនេះសំបូរទៅដោយជីវចំរុះដូចជាធនធានជលលផល ធនធានសត្វព្រៃ ហើយតំបន់ខាងលើត្រូវបានកំណត់ដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ ១១ ឆ្នាំ ១៩៩៣ ហើយត្រូវបានការពារយ៉ាងម៉ឺងម៉ាត់ពីមន្ត្រីការពារធនធានធម្មជាតិ នៃក្រសួងបរិស្ថាន ។

### ២.៤.៥. តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជនដោយមិនបានចែកចេញដោយឡែកនោះទេក្នុងនោះមាន (ដីវត្ត ដីកប់ខ្មោច ដីអាស្រម ក៏គិតគូរក្នុងនោះដែរ) តែក្នុងនោះក៏មានការគិតគូរជារួមលើកលែងតែហេដ្ឋារចនាសម្ព័ន្ធសង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការគិតគូរដោយឡែក ។ និយាយរួមដីសំរាប់តំរូវការហេដ្ឋារចនាសម្ព័ន្ធត្រូវបានកំណត់ជារួមជាមួយនឹងដីត្រៀមបំរុងសំរាប់ពង្រីកទីប្រជុំជន ។

**តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ :**

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 00 | 01 | 01 |
| សាលាបឋមសិក្សា | 06 | 08 | 02 |
| សាលាអនុវិទ្យាល័យ | 01 | 02 | 01 |
| សាលាវិទ្យាល័យ | 01 | 02 | 01 |
| មណ្ឌលសុខភាព | 01 | 01 | 00 |
| ប៉ុស្តិ៍សុខភាព | 00 | 01 | 01 |
| ស្នាក់ការសហគមន៍នេសាទ | 01 | 01 | 00 |
| ស្រះទឹកស្អាត | 39 | 39 | 00 |
| អណ្តូងទឹកស្អាត (លូ) | 37 | 37 | 00 |
| អណ្តូងទឹកស្អាត (ស្នប់) | 158 | 158 | 00 |
| កន្លែងចាក់សំរាម | 00 | 01 | 01 |
| ទីតាំងផ្សារ | 01 | 01 | 00 |
| ប៉ុស្តិ៍នគរបាល | 00 | 01 | 01 |

*(ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

#### ២.៤.៥.១. តំរូវការដីសាលារៀន

ផ្ទៃដីសំរាប់កសាងសាលារៀននៅក្នុងនេះគឺមិនមានការកំណត់ផ្ទៃដីឱ្យបានច្បាស់លាស់នៅឡើយ ដោយកន្លងមកដីសាលារៀនត្រូវបានគិតបញ្ចូលទៅក្នុងផ្ទៃដីភូមិ ហើយប្រសិនបើតំរូវការឱ្យមានការសាងសង់បន្ទប់រៀនថ្មី គឺអាចធ្វើការសាងសង់នៅក្នុងបរិវេណសាលារៀនចាស់បាន ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសង្គមនៅក្នុងមូលដ្ឋានឃុំអណ្តូងទឹក បច្ចុប្បន្ននៅមានកំរិតនៅឡើយ តែសព្វថ្ងៃឃុំបានកំពុងធ្វើការអភិវឌ្ឍន៍បណ្តើរៗ ដូចជានៅចុងឆ្នាំ ២០០៨ និងដើមឆ្នាំ ២០០៩ បានសាងសង់សាលាបឋមសិក្សា ២ កន្លែង មួយកន្លែងស្ថិតនៅភូមិជីត្រេះមាន ០១ បន្ទប់ធ្វើអំពីឈើ និងមួយកន្លែងទៀតស្ថិតនៅភូមិតាមាឃមាន ០៣ បន្ទប់ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ក៏ការអភិវឌ្ឍន៍លើវិស័យអប់រំនៅក្នុងឃុំអណ្តូងទឹក នៅពុំទាន់បំពេញបានតំរូវការសិក្សារបស់សិស្សានុសិស្សនៅឡើយ ជាអាទិ៍ដូចជានៅក្នុងគំរោងផែនការ ១៥ ឆ្នាំ ខាងមុខ តំរូវការខាងអគារសិក្សាផ្អែកតាមបរិមាណសិស្សានុសិស្ស គឺមត្តេយ្យសាលាបឋមសិក្សា ក៏ដូចជាអនុវិទ្យាល័យ ហើយពិនិត្យទៅតាមការគណនាកំណើនប្រជាពលរដ្ឋឃើញថា តំរូវការទាំងនេះអាចផ្តល់ឱកាសឱ្យឃុំអាចអភិវឌ្ឍន៍ទៅតាមលទ្ធភាពជាបណ្តើរៗ ដែលក្នុងនោះសាលាមត្តេយ្យមាន ០១សាលា នៅភូមិអណ្តូងទឹក ហើយសាលាបឋមសិក្សា ឃុំមានគំរោងពង្រីក ០២ សាលាទៀតនៅក្នុងភូមិអណ្តូងទឹក ។ ដោយឡែកចំពោះសាលាអនុវិទ្យាល័យនៅរួមជាមួយវិទ្យាល័យមាន ០១ អគារមាន ០៥ បន្ទប់ ដូច្នេះឃុំមានគំរោងសាងសង់អគារបន្ថែម ០១ អគារទៀតនៅពេលខាងមុខ ។ សាលាវិទ្យាល័យមានគំរោង ពង្រីក ០១ អគារទៀត ចំនួន ០៥ បន្ទប់ ។

**តារាងកំណើនកុមារ ថ្នាក់រៀន និង សាលានៅឆ្នាំ ២០១២-២០២២**

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយ្យសិក្សា | 177 | 01 | 05 | 195 | 00 | 00 | 213 | 00 | 02 |
| ថ្នាក់បឋមសិក្សា | 781 | 00 | 02 | 861 | 01 | 07 | 940 | 01 | 03 |
| ថ្នាក់អនុវិទ្យាល័យ | 508 | 00 | 00 | 560 | 01 | 06 | 611 | 00 | 01 |
| ថ្នាក់វិទ្យាល័យ | 486 | 01 | 05 | 536 | 00 | 01 | 585 | 01 | 05 |

- តំរូវការសាលារៀន និងបន្ទប់រៀនត្រូវបានគណនាដោយផ្អែកលើកុមារគ្រប់អាយុចូលរៀនតាមកំរិតសិក្សានីមួយៗ ( តាមអត្រាចូលរៀន% ) ។
- ជាទូទៅកុមារអាយុចាប់ពី ៣-៥ ឆ្នាំ គ្រប់អាយុចូលមត្តេយ្យហើយ ប៉ុន្តែនៅក្នុងឃុំនៅមិនទាន់មានសាលាបែបនេះនៅឡើយ ក្នុងដំណាក់កាលដំបូងនេះសាលាបានផ្តល់ឱកាសឱ្យកុមារអាយុ ៥ ឆ្នាំ បានចូលរៀន ដូច្នេះធ្វើឱ្យកុមារអាយុក្រោម ៥ ឆ្នាំ ខ្វះមូលដ្ឋានគ្រឹះនៃការសិក្សា បញ្ហាចោទនៅពេលនេះគឺកង្វះខាតគ្រូ និងសាលា។

កំណើនកុមារកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំជាលំដាប់ កុមារទាំងនេះត្រូវការសាលារៀនទៅថ្ងៃអនាគត

- ឆ្នាំ ២០១២ ថ្នាក់មត្តេយ្យតំរូវការសង់សាលា ០១ ខ្នង មាន ០៥ បន្ទប់ សំរាប់ឱ្យសិស្សដែលខ្ចីថ្នាក់បឋម ០១ បន្ទប់ ។ សិស្សមត្តេយ្យ ឆ្នាំ ២០១២ មានចំនួន ០២ បន្ទប់ និង សិស្សមត្តេយ្យឆ្នាំ ២០២២ មានចំនួន ០២ បន្ទប់ ។
- ឆ្នាំ ២០១២ ថ្នាក់បឋមអាចខ្ចីបន្ទប់សាលាមត្តេយ្យ ០២ បន្ទប់មករៀនបាន ឆ្នាំ ២០១៧ តំរូវការសង់សាលាបឋម ០១ ខ្នងចំនួន ០៥ បន្ទប់ សិស្សបឋមដែលខ្ចីថ្នាក់មត្តេយ្យនៅឆ្នាំ ២០១២ អាចមករៀននៅសាលាបឋមវិញ។ សាលាបឋមនៅឆ្នាំ ២០២២ សង់ ០១ ខ្នងទៀតចំនួន ០៥ បន្ទប់ សំរាប់សិស្សកើនក្នុងឆ្នាំ ២០២២ ចំនួន ០៣ បន្ទប់ ហើយបន្ទប់ចំនួន ០២ ដែលសល់អាចធ្វើជាបណ្ណាល័យ និង ទីចាត់ការសំរាប់សាលា ។

- ឆ្នាំ ២០១២ សិស្សអនុវិទ្យាល័យអាចរៀននៅសាលាដដែលបាន ឆ្នាំ ២០១៧ សាលាអនុវិទ្យាល័យតំរូវការសង់សាលា ០១ ខ្នង ចំនួន ០៥ បន្ទប់ នៅឆ្នាំ ២០២២ សិស្សដែលកើនក្នុងឆ្នាំនេះអាចរៀននៅសាលាដែលសង់នៅឆ្នាំ ២០១៧ ពីព្រោះសិស្សដែលកើនក្នុងឆ្នាំ ២០២២ តែ ០១ បន្ទប់ប៉ុណ្ណោះ ។

- ឆ្នាំ ២០១២ សាលាវិទ្យាល័យតំរូវការសង់ ០១ខ្នង ចំនួន ០៥ បន្ទប់ ឆ្នាំ ២០១៧ សិស្សវិទ្យាល័យកើន ០១ ថ្នាក់អាចរៀននៅសាលាដែលសង់នៅឆ្នាំ ២០១២ បាន ឆ្នាំ ២០២២ កំណើនសិស្សកើនឡើងច្រើនតំរូវសង់សាលា ០១ ខ្នងចំនួន ០៥ បន្ទប់ ។

- ក្នុង ១ ថ្ងៃ ត្រូវរៀន ២ ពេល សិស្សក្នុងថ្នាក់មានចំនួនមធ្យម៥0 នាក់ បើពិនិត្យទៅលើចំនួនសិស្សក្នុងថ្នាក់ឃើញថាមានអត្រាសមល្មមអាចផ្តល់ឱកាសឱ្យកុមារ និងយុវជនបានចូលរៀនគ្រប់គ្នា ។

- សាលារៀននៅឃុំអណ្តូងទឹកបច្ចុប្បន្នភាគច្រើនជាអគារសង់ពីថ្មមិនជាចោទបញ្ហាអ្វីទេដល់សិស្សសាលា ។

- ផ្ទៃដីសំរាប់សាងសង់សាលារៀននៅក្នុងឃុំនេះគឺមិនមានការកំណត់ផ្ទៃដីឱ្យច្បាស់លាស់នៅឡើយទេ ដោយកន្លងមកដីសាលារៀនត្រូវបានគិតបញ្ចូលទៅក្នុងដីភូមិ ហើយប្រសិនបើតំរូវការឱ្យមានការសាងសង់សាលារៀនថ្មីគឺអាចសាងសង់នៅក្នុងបរិវេណសាលារៀនចាស់បាន ។

### ២.៤.៥.២. សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

#### ក- សេវាកម្មសុខភាព

ស្ថិតក្នុងដំណាក់កាលនេះ ឃុំអណ្តូងទឹកក៏ពុំទាន់មានប៉ុស្តិ៍សុខភាពនៅតាមភូមិ សំរាប់ជួយសំរួលដល់ការទ្រទ្រង់សុខភាពរបស់ប្រជាពលរដ្ឋបន្ថែមលើមណ្ឌលសុខភាពបានឡើយ ។

- ចំងាយមធ្យមពីភូមិទៅមណ្ឌលសុខភាពឃុំ ចំពោះភូមិចំនួន ៥ មានចំងាយ ៨ គ.ម ពីមណ្ឌលសុខាភាព ហើយភូមិ ២ មានទីតាំងជាប់មណ្ឌលសុខភាពស្រុក ។

- ផ្អែកតាមស្ថានភាពភូមិសាស្ត្រនៃឃុំអណ្តូងទឹក ដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពីមណ្ឌលសុខភាពឃុំ បណ្តាលឱ្យមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្តល់សេវាកម្មផ្នែកសុខភាពមិនទាន់គ្រប់គ្រាន់ឡើយ ។

ចំពោះការការពារសុខភាពប្រជាពលរដ្ឋនៅឃុំអណ្តូងទឹកនៅចោទជាបញ្ហានៅឡើយក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ ជួបបញ្ហាដែលបណ្តាលមកពីស្ថានភាពប្រជាជនក្នុងឃុំរស់នៅឆ្ងាយពីគ្នាពីភូមិមួយទៅភូមិមួយប្រជាជនភាគច្រើនគ្មានលទ្ធភាពចូលមកព្យាបាលនៅក្នុងមណ្ឌលសុខភាពឃុំឡើយ ដូច្នេះកង្វះខាតលើមណ្ឌលសុខភាពមានកំរិតខ្ពស់ ហើយនៅរយៈពេលខាងមុខ យើងមិនអាចបង្កើតបានជាគោលការណ៍បើពិនិត្យទៅលើប៉ុស្តិ៍សុខភាពឃើញថាពុំទាន់មាន ដូច្នេះជាអាទិភាព ឃុំត្រូវលើកផែនការសាងសង់ប៉ុស្តិ៍សុខភាពឱ្យមាននៅតាមភូមិនីមួយៗ ទើបអាចជួយសំរាលដល់ការលំបាកលើការថែទាំសុខភាពក្នុងមូលដ្ឋាន ក្នុងនោះយើងត្រូវបង្កើតនៅភូមិជីមាល ភូមិប្រៃ ភូមិជីត្រេះ ភូមិតាអុក ភូមិតាមាយ និងភូមិប្រទាល ។ ដោយឡែកភូមិអណ្តូងទឹកមានមណ្ឌលសុខភាពនៅទីនោះស្រាប់ ។

### ខ- ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំអណ្តូងទឹក បច្ចុប្បន្ននៅតែជាបញ្ហាចំបងនៅឡើយ ព្រោះថាចំពោះអណ្តូងទឹក និង ស្រះទឹកនៅក្នុងឃុំដែលបានសាងសង់ពីមុននោះ មួយចំនួនត្រូវបានខូចដូច្នេះជាជំហានដំបូងផែនការអភិវឌ្ឍន៍ ត្រូវស្តារ និង ជួសជុលនូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលខាងមុខ ឃុំត្រូវបន្ថែមនូវគំរោងផែនការក្នុងការជីកស្រះទឹកស្តុកទឹកស្អាត និងអណ្តូងទឹកស្អាត ។

### ២.៤.៥.៣. ផ្នែកវប្បធម៌ និងសាសនា

នៅក្នុងការអភិវឌ្ឍន៍ទៅលើវិស័យវប្បធម៌ ជាកត្តាមួយចូលរួមចំណែកជំរុញឱ្យមានសន្ទុះដល់ការអប់រំផ្នែកព្រះពុទ្ធសាសនា ។ រាល់ទីតាំងនីមួយៗតាមបណ្តាភូមិត្រូវបានផ្តល់លទ្ធភាព និង ជួយសំរួលដល់ប្រជាជននៅតាមមូលដ្ឋានផ្ទាល់ ដើម្បីមានឱកាសចូលរួមពង្រីកដល់ការផ្សព្វផ្សាយតាមរយៈការអប់រំដល់យុវជនដែលជាសរសរទ្រូងនៃប្រទេសជាតិឱ្យជៀសផុតពីអំពើខុសច្បាប់ទាំងឡាយដែលរដ្ឋាភិបាលបានកំណត់ ។ ជាអាទិភាពសំរាប់ឃុំអណ្តូងទឹកបច្ចុប្បន្នសំរាប់កន្លែងគោរពប្រពៃណីសាសនានាថ្ងៃអនាគតពុំទាន់មានតំរូវការបន្ថែមឡើយ ។

**តារាងការអភិវឌ្ឍន៍ និងអភិរក្សផ្នែកវប្បធម៌ និងសាសនា**

| វប្បធម៌ និងសាសនា | ចំនួនក្នុងឆ្នាំនេះ | ចំនួន ១៥ ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាឆទាន | 00 | 00 | 00 |
| ទីកន្លែងសក្ការៈបូជា | 02 | 02 | 00 |
| វត្តអារាម | 02 | 02 | 00 |
| ផ្សេងៗ | 00 | 00 | 00 |

*(ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំឆ្នាំ ២០០៨)*

### ២.៤.៥.៤. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមសភាពជាក់ស្តែងនៃបរិមាណផ្លូវដែលមានក្នុងឃុំអណ្តូងទឹកឃើញថា ផ្លូវមួយចំនួនត្រូវធ្វើការកែលំអដូចជាផ្លូវគ្រួសក្រហមដែលបានសាងសង់ពីមុនមកបច្ចុប្បន្នត្រូវខូច ហើយនៅក្នុងឆ្នាំ ២០០៩ នេះ ឃុំបានធ្វើការជួសជុលឡើងវិញបានចំនួន ០៣ ខ្សែ ប្រវែងសរុប ៤.០០០ ម នៅក្នុងភូមិអណ្តូងទឹក ជីមាល និង ភូមិប្រែ ហើយនៅសល់ពីនោះឃុំនឹងធ្វើការជួសជុលបន្ត នៅរយៈពេល ១៥ ឆ្នាំខាងមុខ ឃុំនឹងលើកគំរោងសាងសង់ផ្លូវក្រាលគ្រួសក្រហមបន្ថែមលើផ្លូវដីសប្រវែង ៦.០០០ម និងដាក់លូកាត់ផ្លូវគឺក្នុងភូមិអណ្តូងទឹក ជីមាល និងជីត្រេះ ជាមួយគ្នានេះដែរ ឃុំក៏បានលើកគំរោងផ្លូវគ្រួសក្រហម ដែលស្ថិតនៅតាមភូមិមួយចំនួនតភ្ជាប់ពីផ្លាពីភូមិ១ ទៅភូមិ ១ ។

ដោយឡែកចំពោះផ្លូវដីសដែលត្រូវបានក្លាយពីផ្លូវថ្មើជើង និង ផ្លូវរទេះ ឃុំបានធ្វើការសិក្សាទៅលើផ្លូវ ចំនួន ០២ ខ្សែ ដែលមានប្រវែង ១.០០០ ម ដែលផ្លូវនីមួយៗមានទិសដៅចូលទៅតាមភូមិ ។

សូមបញ្ជាក់ថាមានផ្លូវមួយចំនួនដែលមានទ្រង់ទ្រាយជាផ្លូវចូលទៅលំនៅដ្ឋានដែរ ប៉ុន្តែមានទំហំធំជាងភ្លឺស្រែដូច្នេះមានការដាក់បញ្ចូលផ្លូវនេះជាផ្លូវលំដីស ហើយនឹងត្រូវធ្វើការសាងសង់ឱ្យត្រូវតាមស្តង់ដារ ។

នៅក្នុងដំណើរការអភិវឌ្ឍន៍ទៅលើប្រព័ន្ធទឹក  ឃុំបានធ្វើការសិក្សាទៅលើប្រភពទឹកដែលមានស្រាប់ដូចជា  បឹង ត្រពាំង ប្រឡាយមេ ដោយផ្អែកទៅលើស្ថានភាពភូមិសាស្ត្រ និង លទ្ធភាពអំណោយផលរបស់ឃុំអណ្តូងទឹកនោះ ឃុំបានលើគំរោងផែនការអភិវឌ្ឍន៍សំរាប់រយៈពេល ១៥ ឆ្នាំខាងមុខ ដោយធ្វើការស្តារប្រឡាយមេចំនួន ០៣ ខ្សែប្រវែង៧០០ ម នៅភូមិជីត្រេះ តាអុក និង ភូមិប្រទាល  ។ ក្នុងករណីដែលឃុំអនុវត្តបាននូវផែនការខាងលើនោះឃុំអាចធ្វើស្រែបង្កើនរដូវ និងអាចធានាបានសន្តិសុខស្បៀងក្នុងឃុំទាំងមូល  ។

ស្ថានភាពលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅក្នុងឃុំអណ្តូងទឹក  ភាគច្រើនរស់នៅតាមតំបន់មាត់សមុទ្រ  និង  មាត់ព្រែកធំៗ  មួយចំនួនទៀតរស់នៅតាមដងផ្លូវជាតិលេខ  ៤៨  និង  ផ្លូវលំក្រាលគ្រួសក្រហមដែលមានចំនួន  ០៥  ភូមិ ត្រូវឆ្លងសាឡង់ ដូច្នេះជាចាំបាច់ប្រជាជនត្រូវឆ្លងទៅមកពីភូមិ ១ ទៅភូមិ ១ បញ្ហានេះជាបញ្ហាចោទ សំរាប់  ប្រជាជន ០៥ភូមិក្នុងឃុំអណ្តូងទឹក ព្រោះបច្ចុប្បន្នព្រែកកន្ទួត និង ព្រែកតាអុកមិនទាន់បានធ្វើស្ពានឆ្លងនៅឡើយ ហេតុនេះមានមិនអាចបំពេញបាននូវតំរូវការឆ្លងបានគ្រប់គ្រាន់នោះទេ   ។    ផ្អែកតាមបញ្ហាខាងលើ  ឃុំបានលើកគំរោងផែនការលើការសាងសង់ស្ពានថ្មធំៗចំនួន ២ កាត់ព្រែកដែលនៅភូមិជីមាល និងនៅភូមិតាអុក បន្ថែមទៀតដើម្បីបំពេញតម្រូវការ ។

ជាមួយគ្នានេះដែរ    ចំពោះគំរោងផែនការសាងសង់ទ្វារទឹក    គឺឃុំបានផ្តោតជាសំខាន់ទៅតាមតំរូវការនៃការសាងសង់ប្រព័ន្ធប្រឡាយទឹក   ដែលឃុំបានលើកគំរោង   ក្នុងនោះឃុំបានសិក្សា   និងកំណត់បាននូវចំនួនទ្វារទឹកដែលត្រូវសាងសង់ក្នុងពេលអនាគតចំនួន ០១ ថ្មីទៀតបន្ថែមលើទ្វារទឹកចាស់ ០១ ស្ថិតនៅភូមិប្រៃ ។

បច្ចុប្បន្នលូឆ្លងផ្លូវនៅក្នុងឃុំអណ្តូងទឹក  មានការខូចខាតមួយចំនួន  ដោយសារផ្លូវគ្រួសក្រហមត្រូវខូចខាតធ្វើឱ្យលូត្រូវខូចបែក និងលុបជីជិតមិនអាចប្រើប្រាស់បាន ដូច្នេះតំរូវការក្នុងពេលអនាគតតំរូវឱ្យមានការសាងសង់លូឆ្លងផ្លូវ និង លូរំដោះទឹកចំនួន ០៣ ដែលមានទីតាំងនៅភូមិជីមាល និងភូមិជីត្រេះ ។

# ជំពូក ៣
# ផែនការប្រើប្រាស់ដីអនាគត

## ៣.១. ស្ថានភាពដី សក្តានុពលដី និងតំរូវការដី

### ៣.១.១. ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំអណ្តូងទឹក ធនធានដីដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ អភិរក្ស និង អភិវឌ្ឍន៍ទៅលើធនធានដីទាំងនោះ ឱ្យមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដីព្រៃលិចទឹកដែលបាន ផ្តល់នូវសារៈប្រយោជន៍ផ្នែកបរិស្ថានធម្មជាតិមួយដ៏ល្អប្រសើរសំរាប់មជ្ឈដ្ឋានរស់នៅនៃធនធានជលផលក្នុងតំបន់នោះ ។ នៅក្នុងក្របខ័ណ្ឌនៃការរស់នៅរបស់ពពួកភាវរស់ គឺជាបណ្តាញនៃប្រព័ន្ធអេកូឡូស៊ីនៅក្នុងមជ្ឈដ្ឋាននាទីព្រៃលិចទឹកដែល បានផ្តល់នូវសារៈប្រយោជន៍ឱ្យគ្នាទៅវិញទៅមកជាអាទិ៍ដូចជា ព្រៃលិចទឹកផ្តល់នូវទីជំរកដល់ពពួកភាវរស់ និងពពួកសត្វ ផ្សេងៗដែលរស់នៅក្នុងព្រៃលិចទឹក ដូចជាពពួកសត្វសំខាន់ៗ ត្រី មេអណ្តើក កន្ធាយ ពស់ ស្វា អន្សង ត្រកួត និង សត្វស្លាបជាច្រើនប្រភេទទៀត។ ល ។ ទាំងនេះគឺជាសក្តានុពលមួយដែលផ្តល់នូវសារៈប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុង មូលដ្ឋានសំរាប់ការដកយកអនុផលពីព្រៃលិចទឹក ដូចជាវល្លិ៍ ឫសឈើ ឈើសំរាប់យកទៅធ្វើថ្នាំបូរាណព្យាបាលជំងឺ និងជា របាំងការពារខ្យល់ ។ តំបន់ព្រៃឈើ វាលស្មៅ ព្រែក និង សមុទ្រ តំបន់ទាំងនេះសុទ្ធតែផ្តល់នូវសារៈប្រយោជន៍ សំរាប់ប្រជាពលរដ្ឋនៅមូលដ្ឋាន ។

### ៣.១.២. តំរូវការដីតាមប្រភេទ

ឃុំអណ្តូងទឹកគឺជាឃុំមួយដែលមានប្រជាជនរស់នៅតាមដងព្រែក និងតំបន់ឆ្នេរសមុទ្រដែលជាដីសាធារណៈ របស់រដ្ឋមានចំនួន ៣២២ គ្រួសារ ដែលខ្វះដីស្រែ និងដីលំនៅដ្ឋាន ផ្អែកលើតំរូវការនៃការប្រើប្រាស់ដីឃុំបានរៀបចំគំរោង ផែនការទៅលើតំរូវការពង្រីកដីភូមិដោយបានកំណត់លើផ្ទៃដីសង្គមកិច្ច ២ កន្លែង ក្នុងនោះ ១ កន្លែង ស្ថិតនៅភូមិ អណ្តូងទឹក ចំណុចត្រពាំងធំចំនួន ៣០០ ហ.ត ដីទាំងអស់បច្ចុប្បន្នគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ និងអង្គការវ៉ាយអេដ ។ មួយកន្លែងទៀតស្ថិតនៅភូមិជីមាល ក្នុងចំណុចស្រែក្នុងចំនួន ៣៥០ ហ.ត ក្នុងនោះមានដីសំរាប់លំនៅដ្ឋាន ដីសំរាប់ដីស្រែ និង ដីចំការតំបន់នេះមានទឹកគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋប្រើប្រាស់គ្រប់រដូវ ប៉ុន្តែមិនអាចធ្វើស្រែប្រាំងបានទេពីព្រោះ ខ្វះប្រព័ន្ធស្រោចស្រពដីទាំងនេះគឺជាផែនការអនាគតរបស់ឃុំសំរាប់ពង្រីកដីភូមិ ដីស្រែ ដីចំការ រយៈពេល ១៥ ឆ្នាំ សព្វថ្ងៃដីនេះគ្រប់គ្រងដោយរដ្ឋបាលព្រៃឈើ និងអង្គការវ៉ាយអេដ ។

- នៅក្នុងឃុំអណ្តូងទឹកមានវាលកប់ខ្មោចចំនួន ៦ កន្លែង គឺភូមិអណ្តូងទឹកនៅក្បែរវត្តមុន្នីរាមអណ្តូងទឹក ភូមិ ជីមាល ១ កន្លែង ភូមិប្រៃ ១ កន្លែង ភូមិជីត្រេះ ១ កន្លែង ភូមិតាមាឃ ១ កន្លែង និង ភូមិប្រទាល ១ កន្លែង ។
- ទំនប់ការពារទឹកប្រៃមានប្រវែង ៣.៨០០ ម ក្នុងភូមិជីមាល និងភូមិអណ្តូងទឹក ដែលមានដីស្រែចំនួន ៦៣០ ហ.ត ក្នុងនោះផ្ទៃដីស្រែចាស់ ២៦០ ហ.ត ផ្ទៃដីស្រែពង្រីកថ្មី ២៧០ ហ.ត គំរោង ១៥ ឆ្នាំ ទំនប់ការពារទឹកប្រៃនៅភូមិ ជីត្រេះ និងភូមិប្រៃមានប្រវែង ៩.៤៨៥ ម ការពារដីស្រែដែលមានស្រាប់ចំនួន ៧២ ហ.ត ហើយដីស្រែដែលត្រូវពង្រីកថ្មី ៤៨០ ហ.ត គំរោងឃុំសំរាប់ ១៥ ឆ្នាំ ខាងមុខ ។

- ដីចំការដំណាំរយៈពេលខ្លី ប្រភេទដីនេះមានគំរោងពង្រីកបន្ថែមតាមរយៈការពង្រីកដីភូមិ ព្រោះដីចំការដំណាំរយៈពេលខ្លីភាគច្រើនជាដីដែលស្ថិតនៅជាមួយដីលំនៅដ្ឋាន បច្ចុប្បន្នផ្អែកទៅតាមស្ថានភាពជាក់ស្តែងឃុំមានមានផែនការលើកគំរោងពង្រីកដីសំរាប់ដំណាំប្រភេទនេះក្នុងរយៈពេល ១៥ ឆ្នាំខាងមុខ ។

- ដីចំការដំណាំឈើហូបផ្លែនៅរយៈពេល ១៥ ឆ្នាំខាងមុខ ការពង្រីកដីប្រភេទនេះគឺជាគោលការណ៍របស់ឃុំដោយកំណត់យកប្រភេទដីទីទួលដែលអាចមានលទ្ធភាពក្នុងការដាំដំណាំចំការឈើហូបផ្លែ ។

- បញ្ហាផ្ទៃដីការពារដូចជាតំបន់ឧទ្យានជាតិបូទុមសាគរ និង តំបន់អភិរក្សព្រៃឈើដែលការពារដោយរដ្ឋបាលព្រៃឈើ ទោះទទួលរងនូវការរំលោភយកដីមកធ្វើស្រែចំការពីជនខិលខូចយ៉ាងណាក៏ដោយ ក៏ឃុំនៅតែមានគោលការណ៍ និង វិធានការណ៍ដើម្បីដកហូតយកមកទុកជាដីសាធារណៈរបស់រដ្ឋ សំរាប់ប្រើប្រាស់ធ្វើជាប្រយោជន៍រួមដដែល ។ ដូច្នេះផ្ទៃដី ទឹក និងខ្សែទឹកដែលមានក្នុងឃុំ មិនអាចកែប្រែ ឬកែសំរួល ឱ្យក្លាយជាប្រយោជន៍ក្រៅពីប្រភពទឹកជាធនធានធម្មជាតិបានឡើយ ។

- ផ្ទៃដីសហគមន៍នេសាទមាន ១ កន្លែង ស្ថិតនៅភូមិតាមាឃ ឃុំអណ្តូងទឹក សហគមន៍នេះគឺជាការផ្ទេរអំណាចវិសហមជ្ឈការពីស្ថាប័នជលផលដល់សហគមន៍នេសាទ គ្រប់គ្រង និងប្រើប្រាស់ប្រកបដោយនិរន្តរភាព ។ ដូច្នេះប្រភេទដីនេះស្ថិតក្នុងក្របខណ្ឌជាដីសាធារណៈរបស់រដ្ឋ មិនអាចយកដីទាំងនេះប្រើប្រាស់សំរាប់ជាប្រយោជន៍ឯកជនបានឡើយ ។ ជាមួយគ្នានេះដែរ ឃុំក៏មានគោលការណ៍បង្កើតសហគមន៍នេសាទថ្មីបន្ថែមទៀត ទៅលើដីព្រៃលិចទឹកនៅភូមិតាមាឃ ត្រពាំងពងទឹកដែលស្ថិតនៅភូមិជីមាល ត្រពាំងស្វាយភូមិប្រៃ និងត្រពាំងព្រៃភូមិជីត្រេះ ក្នុងតំបន់ទាំងនេះឃុំមានគំរោងធ្វើបង្គោលបោះការពារព្រំដែនដីសហគមន៍ ដើម្បីការពារកុំឱ្យជនខិលខូចទន្រ្ទានយកដីធ្វើជាកម្មសិទ្ធិ ។

តារាងគំរូការនៃការប្រើប្រាស់ដីនាអនាគត

| ការប្រើប្រាស់ដីធ្លី | ក្រឡាផ្ទៃឆ្នាំនេះ (ហ.ត) | ក្រឡាផ្ទៃ ១៥ ឆ្នាំ (ហ.ត) | បំរែបំរួល (ហ.ត) |
|---|---|---|---|
| ដីភូមិ | 216.7154 | 335.1554 | 118.44 |
| ដីវាលកប់ខ្មោច | 19.738 | 19.738 | 00 |
| ដីវាលស្រែវស្សា | 539.6982 | 682.6436 | 142.9454 |
| ដីស្រោចស្រព | 00 | 00 | 00 |
| ដីចំការដំណាំរយៈពេលខ្លី | 107.0193 | 207.0193 | 100 |
| ដីចំការដំណាំឈើហូបផ្លែ | 451.7338 | 451.7338 | 00 |
| ដីព្រៃលិចទឹក | 631.1302 | 631.1302 | 00 |
| ដីវាលស្មៅ | 1,263.5136 | 1,263.5136 | 00 |
| ដីផ្ទៃទឹក និងខ្សែទឹក | 13.9587 | 13.9587 | 00 |
| ដីសហគមន៍ព្រៃឈើ | 00 | 1,759 | 1.759 |
| ដីតំបន់ទេសចរណ៍ធម្មជាតិ | 00 | 1,287 | 1,287 |

| | | | |
|---|---|---|---|
| ដីសម្បទានសង្គមកិច្ច | 00 | 648 | 648 |
| ដីសហគមន៍ចិញ្ចឹមឃុំ | 00 | 347 | 347 |

*( ប្រភព: ផ្នែកGIS នៃ មន្ទីរ ដនសស ខេត្តកោះកុង )*

## ៣.២. ការបែងចែកដីតាមតំរូវការប្រើប្រាស់

### ៣.២.១. ការវិភាគអន្តរអំពើ

ការគ្រប់គ្រង និងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើឱ្យមានការផ្តល់នូវផលប្រយោជន៏ និងមាននិរន្តរភាព ហើយនឹងមានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលក្នុងនោះមានដូចជា :

- ការប្រែប្រួលពីដីវាលស្មៅទៅជាដីស្រែសំរាប់ការបង្កបង្កើនផល នេះជាការពង្រីកលើវិស័យកសិកម្ម វាជាកត្តាអំណោយផលដល់ការបង្កើននូវផលិតផល ក៏ដូចជាសេដ្ឋកិច្ចក្នុងមូលដ្ឋាន ។ នៅក្នុងបរិបទនេះការប្រែប្រួលប្រភេទដីប្រសិនបើវាលស្មៅទាំងនេះគឺជាដីស្រែកាលពីសម័យប៉ុលពត ខ្លះទៀតគឺជាដីព្រៃរិចរិល បច្ចុប្បន្នឃុំមានគំរោងទុកដីទាំងនេះសំរាប់ពង្រីកដីស្រែរបស់ប្រជាពលរដ្ឋនៅថ្ងៃអនាគត ។

- ការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងមូលដ្ឋានឃុំ គឺជាកត្តាផ្តល់នូវផលប្រយោជន៏យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

- ការសាងសង់ផ្លូវគឺជាការសំរួលដល់ការធ្វើដំណើរ និងចរាចរណ៏គ្រប់ប្រភេទ ហើយនឹងចូលរួមក្នុងការកាត់បន្ថយការចំណាយទៅលើការងារដឹកជញ្ជូន ។ ការអភិវឌ្ឍន៏នេះថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ខ្លះៗក៏ដោយ ប៉ុន្តែវាផ្តល់នូវផលប្រយោជន៏ជាច្រើនដល់ប្រជាជនប្រើប្រាស់ ។

- ការសាងសង់ប្រឡាយដើម្បីធានាដល់ការស្រោចស្រព ក៏ជាកត្តាផ្តល់នូវសារប្រយោជន៏ក្នុងការបង្កើននូវប្រាក់ចំណូលតាមរយៈការបង្កបង្កើនផល និងដំណាំរួមផ្សំ ។ នៅក្នុងឃុំអណ្តូងទឹកតំរូវការប្រើប្រាស់ទឹកសំរាប់ស្រោចស្រព គឺជាកត្តាសំខាន់ថ្វីត្បិតតែការពង្រីកប្រព័ន្ធស្រោចស្រពនេះជួបការលំបាកយ៉ាងណាក៏ដោយ ក៏ឃុំនៅតែព្យាយាមរកវិធីសាស្រ្តដោះស្រាយ និងជំរុញឱ្យមាននិរន្តរភាពលើការងារនេះ ។

- ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើការពង្រីកអគារសិក្សា និងសាលា គឺជាការចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន ។ បច្ចុប្បន្នទោះបីឃុំមានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មី សំរាប់បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់នៅមានដីសំរាប់សាងសង់អគារសិក្សាបន្ថែមបាន ។ រីឯសាលាមត្តេយ្យដោយមើលឃើញការលំបាកសំរាប់កុមារដែលគ្មានលទ្ធភាពក្នុងការសិក្សានៅទីកន្លែងឆ្ងាយ គឺជាអាទិភាពឃុំត្រូវព្យាយាមរកដំណោះស្រាយឱ្យខានតែបានទៅតាមបណ្តាភូមិគោលដៅព្រោះថាមានសារៈសំខាន់ និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល និងការបំពាក់បំប៉នចំណេះដឹងដល់អនក្ខរជននៅក្នុងមូលដ្ឋាន ។

## ៣.២.២. ផែនទីប្រើប្រាស់ដីពេលអនាគត

***ផែនទីពង្រាងប្រើប្រាស់ដីពេលអនាគត ឃុំអណ្តូងទឹកឆ្នាំ ២០០៩-២០២២***




*( ប្រភពៈផ្នែកGIS នៃ មន្ទីរ ដនសស ខេត្តកោះកុង )*

### ៣.២.៣. ការបរិយាយការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុងឃុំអណ្តូងទឹក ត្រូវបានបែងចែកទៅតាមគោលការណ៍មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័ត ហើយបានអនុលោមទៅតាមមុខនាទីដូចខាងក្រោម :

- ដីស្រែវស្សាមានទំហំ ៧៥ ហ.ត បានបង្ហាញឱ្យឃើញថាមានការត្រួតគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្នក្នុងនោះ ការប្រើប្រាស់ដីបច្ចុប្បន្នដីព្រៃគម្ពោធ ៧.៨៩ ហ.ត ល្បាយដីព្រៃលាយដីចំការ ២៧.៩៨ ហ.ត ដីវាលស្មៅ៣៩.១៣ ហ.ត ដែលមានលេខកូចក្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត F2110-01 និងដីស្រែមួយចំនួនទៀតឃុំបានគ្រោងទៅលើដីសម្បទានសង្គមកិច្ចដែលបំរើអោយវិស័យកសិកម្ម ដែលមានលេខកូដក្បាលដី F6700-02 ។
- ដីសហគមន៍ព្រៃឈើដែលត្រួតលើគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្នមាន 0២ កន្លែង :
    - ១/ សហគមន៍ព្រៃឈើមានទំហំ ៦៦២ ហ.ត បង្ហាញឱ្យឃើញថា មានការត្រួតគ្នា រវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្នក្នុងនោះមានដីព្រៃស្រោង ៦៤0 ហ.ត ដីវាលស្មៅ ២២ ហ.ត ដែលមានលេខកូចកាប្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត F3710-01 ។
    - ២/ សហគមន៍ព្រៃឈើមានទំហំ ១.0៩៧ ហ.ត ដែលត្រួតគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្នដែលមានព្រៃស្រោង ១.0៨៤ ហ.ត ល្បាយដីព្រៃលាយដីចំការ ១ ហ.ត ដីវាលស្មៅ ១២ ហ.ត ដែលមានលេខកូចកាប្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត F3710-02 ។
- តំបន់ទេសចរធម្មជាតិមានចំនួន 0២កន្លែង ដែលមានទំហំសរុប ១.៣៩២.១៩ ហ.ត មានការត្រួតគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើ ប្រាស់ដីបច្ចុប្បន្ន ដែលមានព្រៃកោងកាង ទំហំ ១.១៨៣.៤៦ ហ.ត ព្រៃកោងកាងស្តើងទំហំ ១0៣.៨៧ ហ.ត ព្រៃស្រោង ១0៤.៨៦ ហ.ត ដែលមានលេខកូដក្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត F6500-01, 02 ។
- តំបន់វារីអគ្គិសនី ខ្នាតតូចនៅចំនុចព្រែកទឹកសាប ជាប់ក្នុងតំបន់ដីសម្បទានសង្គមកិច្ច ស្ថិតនៅក្នុងភូមិជីមាល ឃុំអណ្តូងទឹក ដោយឃុំបានគ្រោងដីទំហំ ៣៦ ហ.ត ដែលមានលេខកូដក្បាលដីនៅលើផែនទីប្រើប្រាស់ដីអនាគត F7300-01 ។
- ដីសម្បទានសង្គមកិច្ចដែលត្រួតស៊ីគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្នមាន 0២ កន្លែង :
    - ១/- ដីសម្បទានសង្គមកិច្ចមានទំហំ ២៤៥.៧៧ ហ.ត មានការត្រួតគ្នារវាងការប្រើប្រាស់ដីអនាគត និង ការប្រើប្រាស់ដីបច្ចុប្បន្ន ដែលមានដីកសិកម្មពនេរចរទំហំ ៣១.៥១ ហ.ត ដីព្រៃស្រោងទំហំ ៣៨.៤0 ហ.ត ដីព្រៃដុះឡើងវិញទំហំ ២៨.៤៤ ហ.ត ល្បាយដីព្រៃលាយដីចំការទំហំ ៤៩.៦៦ ហ.ត វាលស្មៅលិចទឹកទំហំ ១៨.៤២ ហ.ត ដីចំការបោះបង់ដុះស្មៅទំហំ ៣៣.៥៣ ហ.ត ដីព្រៃកម្ពោតទំហំ ៣៩.៣៧ ហ.ត ដីព្រៃកម្ពោតលាយឈើខ្ពស់ៗ ៦.៤៤ ហ.ត ដែលមានលេខកូដក្បាលដីនោលើផែនទីប្រើប្រាស់ដីអនាគត F6700-01 ។

២/- ដីសម្បទានសង្គមកិច្ចមានទំហំ ៣៩៧.៣២ ហ.ត ត្រួតត្អារវាងការប្រើប្រាស់ដីអនាគតទៅលើការ ប្រើប្រាស់ដីបច្ចុប្បន្ន ដែលមានព្រៃលិចទឹក ៩៥.៩៥ ហ.ត វាលស្មៅលិចទឹក ៣០១.៣៧ ហ.ត ដែលមានលេខកូដក្បាលដីនោលើផែនទី ប្រើប្រាស់ដីអនាគត F6700-02 ។

- សហគមន៍ចិញ្ចឹមឃ្មុំមានទំហំ ៣៤៦.៩៧ ហ.ត ដែលមានការត្រួតត្អារវាងការប្រើប្រាស់ដីអនាគត និងការប្រើប្រាស់ដីបច្ចុប្បន្នដែលមានព្រៃកោងកាង ៣២៨ ហ.ត ដីព្រៃលិចទឹក ១៨.៩៧ ហ.ត ដែលមានលេខកូដក្បាលដីនោលើផែនទី ប្រើប្រាស់ដីអនាគត F6910-01 ។

- ការប្រើប្រាស់ដីសំរាប់លំនៅដ្ឋាន ដីភូមិ គឺជាដីដែលផ្តល់នូវសក្តានុពលទៅលើការសាងសង់លំនៅដ្ឋាន ដោយមានការដាំដំណាំរួមផ្សំដូចជា ដូង ខ្នុរ ស្វាយ ទឹកដោះគោ ទៀប មៀន លុត ល្ហុង ចេក ។ល។ ជាមួយគ្នានោះដែរប្រភេទដីលំនៅដ្ឋានអាចមានដីស្រែមានលក្ខណៈជាទីសំណាប ឬជាដីសំរាប់ដាំដំណាំរយៈពេលខ្លី ដូចជា ពោត សណ្តែកត្រឡាច ននោង ល្ពៅ អំពៅ ស្ពៃ គ្រប់ប្រភេទ សណ្តែកគួរ ត្រប់ ត្រសក់ ផ្ទី ។ល។ ចំពោះដីលំនៅដ្ឋានសំរាប់អនាគតឃុំបានគ្រោងដីសំរាប់ពង្រីកដីលំនៅដ្ឋានដោយបញ្ចូលទៅក្នុងដីសម្បទានសង្គមកិច្ច ដែលមានលេខកូដ F6700-01 ។

- នៅក្នុងការប្រែប្រួលនូវប្រភេទដីស្រែមកជាដីលំនៅដ្ឋានតាមរយៈការរីកដាលនៃគ្រួសាររបស់ប្រជាពលរដ្ឋដោយការបែងចែកកេរ្តិ៍ទុកឱ្យកូន ។ រីឯស្ថានភាពនៃការរាលដាលសំរាប់ប្រភេទដីលំនៅដ្ឋាននេះ គឺភាគច្រើនរីកតាមបណ្តោយផ្លូវជាតិ ឬផ្លូវលំក្រាលក្រួសក្រហម និងក្បែរប្រភពទឹកដូចជាត្រពាំង ឬអណ្តូងលូ ឬអណ្តូងស្នប់ ។

- ការប្រែប្រួលក៏ដូចជាការកើនឡើងនៃប្រភេទដីស្រែ គឺដោយសារកាលពីឆ្នាំ ២០០៦ ឃុំបានធ្វើទំនប់ទប់ការពារទឹកប្រៃនៅភូមិជីមាល និងភូមិអណ្តូងទឹក ពីមុនដីស្រែដែលអាចធ្វើស្រែបានមានតែ ២៦០ ហ.ត ប៉ុណ្ណោះ បច្ចុប្បន្នតំបន់នេះកើនដីស្រែ ៣៧០ ហ.ត ដែលជាដីស្រែស្ថិតក្នុងគំរោងរបស់ឃុំរយៈពេល ១៥ ឆ្នាំ ។

ពីឆ្នាំ ២០០៩ ឃុំបានធ្វើទំនប់ការពារទឹកប្រៃនៅភូមិជីត្រេះ និងភូមិប្រៃមានប្រវែង ៩៤៨៥ម ការពារដីស្រែដែលមានស្រាប់ចំនួន ៧២ ហ.ត ហើយដីស្រែដែលត្រូវពង្រីកថ្មី ៤៨០ ហ.ត ដីស្រែនេះស្ថិតក្នុងគំរោងសំរាប់ ១៥ ឆ្នាំខាងមុខ ។

- ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសាធារណៈរបស់រដ្ឋ) គឺត្រូវទាមទារឱ្យមានការថែរក្សាឱ្យបានគង់វង់ ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារថែរក្សា អភិរក្ស និងអភិវឌ្ឍន៍ទៅលើធនធានទាំងនេះដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព ។

- ចំពោះប្រជាពលរដ្ឋដែលរស់នៅលើដីសាធារណៈរបស់រដ្ឋដូចជា : មាត់ព្រែក តំបន់ឆ្នេរសមុទ្រ បច្ចុប្បន្នអ្នកដែលរស់នៅចាស់មានការលំបាកក្នុងការផ្លាស់ប្តូរទីលំនៅ ប៉ុន្តែជាគោលការណ៍របស់ឃុំធ្វើការហាមឃាត់ការសាងសង់លំនៅដ្ឋានថ្មី ។ ឃុំមានគំរោង ១៥ ឆ្នាំខាងមុខ ដកគ្រួសារទាំងនេះឱ្យទៅរស់នៅលើដីសម្បទានសង្គមកិច្ចដែលឃុំគ្រោងទុក ។

### ៣.២.៣.១. ដីលំនៅដ្ឋាន (បញ្ញត្តិ គោលការណ៍ និងការប្រើប្រាស់ដី)

តាមស្ថានភាពជាក់ស្តែងដែលបានគ្រោងទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋ ៣២៤ គ្រួសារសំរាប់រយៈពេល ១៥ ឆ្នាំ ប៉ុន្តែនៅក្នុងការគិតគូរទៅលើការកំណត់ផ្ទៃដីភូមិ ក្នុង ១ គ្រួសារ ០,២១ ហិចតា ដោយផ្អែកទៅលើផ្ទៃដីដែលបានគ្រោងរបស់ឃុំ ៦៤៨ ហិចតាប៉ណ្ណោះ ហើយត្រូវបានកំណត់លើការបែងចែក និង អភិវឌ្ឍន៍ទៅតាមគោលដៅដូចខាងក្រោម :

**ទីតាំងដី លេខកូដ ៦៧០០**

ក្នុងការអភិវឌ្ឍន៍ ឃុំបានធ្វើការគិតគូរដោយបានផ្អែកទៅលើការពង្រីកដីលំនៅដ្ឋានក្នុងដីសម្បទានសង្គមកិច្ចស្ថិត នៅភូមិជីមាលចំណុចស្រែក្នុង ។ តំរូវការដីលំនៅដ្ឋានអនាគត ៦៨.០៤ ហិចតា

- ឆ្នាំ ២០១២ កំណត់ ៥ ឆ្នាំទី១ ប្រើប្រាស់ដីលំនៅដ្ឋានចំនួន ១៩.៥៣ ហិចតា
- ឆ្នាំ ២០១៧ កំណត់ ៥ ឆ្នាំទី២ ប្រើប្រាស់ដីលំនៅដ្ឋានអស់ចំនួន ២៤.៣៦ ហិចតា
- ឆ្នាំ ២០២២ កំណត់ ៥ ឆ្នាំទី៣ ប្រើប្រាស់ដីលំនៅដ្ឋានអស់ចំនួន ២៤.១៥ ហិចតា

**បញ្ញត្តិនៃការប្រើប្រាស់ដីសំរាប់សង់លំនៅដ្ឋានថ្មីគឺ :**

នៅក្នុងការពង្រីកដីលំនៅដ្ឋាន ឃុំមានគោលការណ៍រៀបចំដីភូមិដោយមានការកំណត់ និងជំរុញឱ្យមានដីភូមិ ដែលមានសណ្តាប់ធ្នាប់សាធារណៈល្អ ហើយក្នុងនោះត្រូវបានអនុវត្ត :

- រាល់ដីភូមិដែលត្រូវរៀបចំថ្មីត្រូវបានកំណត់ទុកដីចំណីផ្លូវស្របច្បាប់កំណត់ទុក
- ការសាងសង់លំនៅដ្ឋានក្នុងភូមិត្រូវបានអនុវត្តទៅតាមច្បាប់អនុញ្ញាត
- ជំរៅដីសំរាប់សង់លំនៅដ្ឋានមិនអាចលើសពី ១០០ ម៉ែត្រ ពីអ័ក្សផ្លូវ
- មិនត្រូវសាងសង់លំនៅដ្ឋានលើដីសាធារណៈរបស់រដ្ឋជាដាច់ខាត
- រាល់ដីភូមិដែលកើតថ្មីត្រូវមានការកំណត់ព្រំប្រទល់ដោយមានការឯកភាពរវាងភាគីពាក់ព័ន្ធ ហើយត្រូវបានបោះ បង្គោលរបងកំណត់ព្រំច្បាស់លាស់ ។
- ជំរុញ និង ផ្សព្វផ្សាយឱ្យមានការចូលរួម បង្កើននូវផលិតផលតាមរយៈការរៀបចំជាសួនដំណាំក្នុងដីភូមិដូចជា សួនបន្លែ និងដំណាំរួមផ្សំរយៈពេលខ្លី និងវែងដែលជាកត្តាជួយឱ្យក្នុងភូមិមានសភាពបៃតងដោយមានលទ្ធភាពបង្កើន ប្រាក់ចំណូលក្នុងគ្រួសារលើសកម្មភាពនេះ ។
- ចំពោះប្រជាពលរដ្ឋដែលរស់នៅលើដីសាធារណៈ (ដីមាត់ព្រែក មាត់សមុទ្រ ) បច្ចុប្បន្នអ្នកដែលរស់នៅចាស់ មានការលំបាកក្នុងការផ្លាស់ប្តូរ ហើយជាបណ្តើរៗឃុំនឹងព្យាយាមធ្វើការដោះដូរ និងរៀបចំឱ្យបានត្រឹមត្រូវ ប៉ុន្តែជា គោលការណ៍ឃុំធ្វើការហាមឃាត់ដាច់ខាតការសាងសង់លំនៅដ្ឋានថ្មី ។

**៣.២.៣.២. ដីស្រែវស្សា និងស្រែប្រាំង**

- ការប្រើប្រាស់ដីសំរាប់ដីស្រែនៅក្នុងឃុំអណ្តូងទឹកធ្វើស្រែតែមួយរដូវប៉ុណ្ណោះគឺរដូវវស្សា ដោយមានការប្រែប្រួល នៃកំណើនប្រជាពលរដ្ឋ ឃុំបានធ្វើការគិតគូរលើការពង្រីកដីស្រែដែលមានស្រាប់ ហើយជាដីស្រែដែលបានបោះបង់ ចោលពីមុននោះត្រូវបានធ្វើការរៀបចំកែលំអឡើងវិញដោយអនុលោមទៅតាមលក្ខណៈបច្ចេកទេសកសិកម្មដំណាំស្រូវ ដល់ប្រជាពលរដ្ឋដើម្បីផ្តល់ឱកាសដល់ពួកគាត់ចូលរួមក្នុងការបង្កើននូវទិន្នផលនៅក្នុងមូលដ្ឋាន ។
- ចំពោះដីស្រែដែលទុកចោលទំនេរនេះគឺជាដីដែលស្ថិតនៅចំណុចត្រពាំងធំភូមិអណ្តូងទឹកមួយកន្លែងដែលមានលេខ កូដ៦៧០០ និងមួយកន្លែងទៀតស្ថិតនៅភូមិជីមាលចំណុចស្រែក្នុងដែលមានលេខកូដ៦៧០០ បច្ចុប្បន្នឃុំបានគ្រោងទុកដី ទាំងពីរកន្លែងនេះជាដីសម្បទានសង្គមកិច្ចដែលមានទំហំសរុបទាំងដីលំនៅដ្ឋាន និងដីកសិកម្ម ៦៤៨ ហិចតា ។

### គោលការណ៍នៃការប្រើប្រាស់ដីកសិកម្ម

- នៅក្នុងកិច្ចអភិវឌ្ឍន៍សំរាប់ពេលអនាគត ឃុំមានគោលការណ៍ក្នុងការរៀបចំនូវការបង្កើនផលិតកម្មដំណាំស្រូវ ដែលក្នុងនោះត្រូវអនុវត្តនូវយុទ្ធសាស្ត្រមួយចំនួន ដែលអាចជួយដល់ការបង្កើនផលិតភាពកសិកម្មគឺៈ

- លើកកំពស់ការប្រើប្រាស់ជីរធម្មជាតិ និងជីរកំប៉ុស្តិ៍
- កាត់បន្ថយការប្រើប្រាស់ជីរគីមី
- កាត់បន្ថយការប្រើប្រាស់ថ្នាំពុល ជំរុញការអនុវត្តន៏កម្មវិធី IPM
- រៀបចំប្រពលវប្បកម្មដំណាំស្រូវ ( បវស)
-អភិវឌ្ឍន៍លើការស្តារ និងសាងសង់ប្រព័ន្ធស្រោចស្រព ដើម្បីប្រើប្រាស់ឱ្យអស់នូវផ្ទៃដីស្រែដែល មាន ។
- ជំរុញការធ្វើស្រែបង្កើនរដូវ
- បង្កើនការដាំដុះដំណាំរយៈពេលខ្លីទៅលើដីស្រែ ដែលមានលទ្ធភាពក្នុងការស្រោចស្រពដើម្បីឱ្យការ ប្រើប្រាស់ដីប្រកបដោយប្រសិទ្ធិភាព និងមានតម្លាភាព ឃុំបានកំណត់ដូចខាងក្រោម :
  - ហាមដាច់ខាតការពង្រីកដីលើដីសាធារណៈរបស់រដ្ឋ
  - ហាមដាច់ខាតការវាតដីស្រែចូលដីបឹង ត្រពាំង ឬ ប្រឡាយ
  - ហាមដាច់ខាតការកាប់រានចូលដីនាទីព្រៃលិចទឹកដើម្បីធ្វើស្រែ
  - វាល់ដីស្រែ ត្រូវមានភ្លឺសំរាប់សំគាល់ព្រំប្រទល់ច្បាស់លាស់

### ៣.២.៣.៣. ការប្រើប្រាស់ទឹក និងប្រព័ន្ធស្រោចស្រព

- ការប្រើប្រាស់ដីផ្ទៃទឹកនានានៅក្នុងឃុំ ជាកត្តាចម្បងសំរាប់ប្រជាជនក្នុងមូលដ្ឋានដើម្បីបំរើផលប្រយោជន៍ឱ្យ វិស័យកសិកម្ម និងការប្រើប្រាស់ទូទៅផ្អែកតាមធនធានទឹកដែលមានក្នុងឃុំរួមមាន ឃុំអាចមានលទ្ធភាពក្នុងការដក យកមកប្រើបានតែប្រភេទទឹកអូរ ត្រពាំង បឹង អណ្តូង ស្រះ តែប៉ុណ្ណោះ ដោយឡែកចំពោះប្រព័ន្ធប្រឡាយបច្ចុប្បន្នពុំ អាចមានលទ្ធភាព ក្នុងការប្រើប្រាស់បានឡើយ ( ប្រឡាយរីង រាក់ ) ។

### ប្រព័ន្ធស្រោចស្រព

ការប្រែប្រួលពីដីស្រែមកជាដីប្រព័ន្ធប្រឡាយ ឬ ដីប្រឡាយមេចាស់មកជាប្រឡាយថ្មីជាបញ្ហាចោទ ព្រោះថា មានការលំបាកសំរាប់ការដោះស្រាយនៅបញ្ហាប្រឈម ដោយបច្ចុប្បន្នមានបញ្ហាមួយចំនួននឹងត្រូវកើតមានឡើងក្នុងពេល ប្រឡាយចាប់ផ្តើមដំណើរការសាងសង់ និងស្តារដូចជាការរំលោភយកដីប្រឡាយធ្វើស្រែ ហើយបញ្ហាមួយផ្សេងទៀត ក្នុងករណីមានការសាងសង់ប្រឡាយថ្មី បញ្ហានឹងកើតឡើងដោយសារការមិនយល់ពីសារៈប្រយោជន៍ ក្នុងការប្រើប្រាស់ ប្រឡាយ ដូច្នេះបញ្ហានៃការប៉ះពាល់ដីស្រែធ្វើឱ្យឃុំប្រឈមមុខក្នុងការដោះស្រាយ ។

### បញ្ញត្តិ និង គោលការណ៍នៃការកសាង និងស្តារប្រឡាយ

- នៅក្នុងលក្ខខណ្ឌនៃការសាងសង់ និងស្តារប្រឡាយត្រូវមានការកំណត់ឱ្យបានច្បាស់ទៅលើការដោះស្រាយបញ្ហា ទើបដំណើរការប្រព្រឹត្តិទៅទទួលជោគជ័យ ។

- រៀបចំគណៈកម្មការចុះដោះស្រាយ អនុវត្ត និងថែទាំ

- ការសាងសង់ប្រឡាយថ្មីត្រូវអនុវត្តទៅតាមផែនការដែលបានគ្រោងទុក( ទំហំប្រឡាយ៤ ម. ជំរៅ ២,៥០ ម.) ដោយមានភ្លឺប្រឡាយសងខាង ២ ម៉ែត្រ ដោយចោតពីមាត់ប្រឡាយ ១,៥០ ម៉ែត្រ ។

- ការស្តារប្រឡាយចាស់ត្រូវអនុវត្តសមស្របទៅតាមទំហំប្រឡាយចាស់

- ត្រូវធ្វើការដោះស្រាយឱ្យបានរួចរាល់នូវការរំលោភយកដីប្រឡាយចាស់ និងកែសំរួលទៅតាមស្ថានភាពជាក់ស្តែង និង សមស្របតាមគោលការណ៍ច្បាប់ ។

**ការប្រើប្រាស់ទឹក**

ដោយឡែកចំពោះប្រជាពលរដ្ឋដែលរស់នៅលើផ្ទៃទឹក ព្រែក និងសមុទ្រ ត្រូវបានប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋានដូចជា ការប្រកបរបរនេសាទនៅលើដែននេសាទដោយមានការការពារ ថែរក្សា និង អភិរក្ស ។ ប៉ុន្តែកត្តានេះមានការពាក់ព័ន្ធទៅនឹងផលប៉ះពាល់បរិស្ថាន ដូចច្នេះនៅពេលអនាគតប្រសិនបើរដ្ឋាភិបាលមានគោលការណ៍ឱ្យប្រជាជនដែលរស់នៅតំបន់ព្រែក និងសមុទ្រត្រូវផ្លាស់ប្តូរលំនៅដ្ឋានមករស់នៅផ្នែកខាងលើគោកវិញ ឃុំនឹងធ្វើការចូលរួមរកដំណោះស្រាយឱ្យស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ការរៀបចំស្តារត្រពាំង ប្រឡាយ ស្រះ អណ្តូង បឹង ឡើងវិញគឺជាកត្តាចម្បងសំរាប់ការផ្តល់លទ្ធភាពក្នុងការអភិវឌ្ឍន៍លើប្រព័ន្ធស្រោចស្រព ព្រោះវាជាប្រភពទឹកមួយដ៏សំខាន់សំរាប់ឃុំអណ្តូងទឹកទាំងមូល ។

**បញ្ញត្តិនៃការស្តារប្រឡាយ ត្រពាំង ស្រះ អណ្តូង**

- ស្តារប្រឡាយ ត្រពាំង ស្រះ អណ្តូង ដោយអនុវត្តទៅតាមទំហំ និង ស្ថានភាពដែលមានស្រាប់

- រៀបចំច្រាំងប្រឡាយ ត្រពាំង ស្រះ ដែលបានខូចខាត បាក់ច្រាំង ឱ្យមានជើងទេរ ដោយមានការដាំស្មៅ ឬ រុក្ខជាតិការពារការហូរច្រោះ ។

- បង្កើតសហគមន៍ប្រើប្រាស់ និងថែទាំទឹកត្រពាំង ស្រះ អណ្តូង

- ចាត់វិធានការចំពោះអ្នកមកតាំងទីលំនៅថ្មីលើដីមាត់ព្រែក និង សមុទ្រ (ដីសាធារណៈរបស់រដ្ឋ)

- ដាក់ចេញជាគោលការណ៍សំរាប់ការការពារ និងថែរក្សាអនាម័យចំពោះអ្នកមានលំនៅដ្ឋានជាប់ត្រពាំង ស្រះ អណ្តូង និង អ្នកប្រើប្រាស់ទឹក ។

**៣.២.៣.៤. ការសាងសង់ស្ពានឆ្លងព្រែក និងទ្វារទឹក**

នៅក្នុងការអភិវឌ្ឍន៍លើហេដ្ឋារចនាសម្ព័ន្ធ ឃុំក៏បានចាប់អារម្មណ៍លើការសាងសង់ស្ពានឆ្លងព្រែក ដែលក្នុងនោះត្រូវបានគ្រោងការសាងសង់ស្ពានបេតុងនៅចំណុចព្រែកកន្ទួត និង ព្រែកតាអុក (បច្ចុប្បន្នឆ្លងសាឡង់ ឬ ទូកដរ ដែលត្រូវចំណាយប្រាក់) ដែលក្នុងនោះត្រូវបានដំណើរការតាមទីតាំង និងស្ថានភាពដូចខាងក្រោមៈ

**ទីតាំងនៃការសាងសង់ស្ពានបេតុង**

ការសាងសង់ស្ពានឆ្លងព្រែកគឺជាការចាំបាច់ ហើយឃុំបានធ្វើការកំណត់លើការសាងសង់ស្ពានបេតុងចំនួន ០២ កន្លែងប្រវែងសរុប ១៧០ ម៉ែត្រ មួយកន្លែងស្ថិតនៅកំពង់ចម្លងព្រែកកន្ទួត និងមួយកន្លេងទៀតស្ថិតនៅកំពង់ចម្លងព្រែកតាអុក ។

**ទីតាំងនៃការសាងសង់ទ្វារទឹក**

ជាមួយនឹងគំរោងផែនការក្នុងការសាងសង់ទ្វារទឹកគឺឃុំបានផ្តោតជាសំខាន់ទៅតាមតំរូវការនៃការសាងសង់ប្រព័ន្ធប្រឡាយទឹកដែលឃុំបានលើកគំរោង ក្នុងនេះឃុំបានសិក្សា និងកំណត់បាននូវចំនួនទ្វារទឹកដែលត្រូវសាងសង់ក្នុងពេលអនាគតចំនួន ០២ កន្លែងថ្មីទៀត ( បន្ថែមលើទ្វារទឹកចាស់ចំនួន ០២ ) ។ ទ្វារទឹកថ្មី ០២ ស្ថិតនៅភូមិជីមាលសំរាប់ការពារទឹកប្រៃ ។

**បញ្ញត្តិ និង គោលការណ៍នៃការសាងសង់ស្ពាន និង ទ្វារទឹក**

- ការសាងសង់ស្ពានត្រូវពិនិត្យទៅតាមស្ថានភាពជាក់ស្តែងលើកំពស់ទឹកខ្ពស់បំផុត
- ការជ្រើសរើសទីតាំងត្រូវអនុលោមទៅតាមស្ថានភាពនៃចរន្តទឹកហូរ និងស្ថានភាពព្រៃក ចៀសវាងកន្លែងដែលមិនសមស្របដែលធ្វើឱ្យចាល់ និងបង្វែរចរន្តទឹកហូរបណ្តាលឱ្យបាក់ច្រាំងព្រែក ។
- ការសាងសង់ត្រូវអនុវត្តទៅតាមបច្ចេកទេសឱ្យបានត្រឹមត្រូវ ហើយត្រូវគិតគូរ និងចៀសវាងនូវកត្តាដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ។
- នៅក្នុងស្ថានភាពនៃការសាងសង់ទ្វារទឹកត្រូវធ្វើការសិក្សាស្រាវជ្រាវ និង ធ្វើការវាយតម្លៃ ដោយស៊ីជម្រៅទៅលើចរាចរនៃប្រភពធនធានជលផល ។

**៣.២.៣.៥. ការប្រើប្រាស់ផ្លូវថ្នល់**

ការប្រើប្រាស់ដីសំរាប់ការសាងសង់ផ្លូវថ្នល់ ក៏មានបញ្ហាខ្លះដែរ ប៉ុន្តែអាចដោះស្រាយបាន ព្រោះថាផ្លូវដែលកើតឡើងគឺជាការផ្តើមចេញពីប្រជាពលរដ្ឋផ្ទាល់ដែលជាអ្នកធ្វើឱ្យកើតមានផ្លូវជាដំបូង ហើយឃុំក៏លើកគំរោងអភិវឌ្ឍន៍ទៅតាមការស្នើឡើងពីសំណាក់ប្រជាពលរដ្ឋ ។ បច្ចុប្បន្នការអភិវឌ្ឍន៍ទៅលើហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងឃុំ គឺអនុវត្តទៅលើផ្លូវចាស់មានស្រាប់ ដូច្នេះដំណោះស្រាយអាចដោះស្រាយបាន ។

**ទីតាំងនៃការសាងសង់ផ្លូវក្រាលគ្រួសក្រហម**

ជាមួយនឹងគំរោងផែនការក្នុងការសាងសង់ទ្វារទឹកគឺឃុំបានផ្តោតជាសំខាន់ទៅតាមតំរូវការនៃការសាងសង់ប្រព័ន្ធប្រឡាយទឹកដែលឃុំបានលើកគំរោង ក្នុងនេះផ្លូវក្រាលគ្រួសក្រហមចំនួន ០២ ខ្សែមានប្រវែង ៤.០០០ ម៉ែត្រ ផ្លូវលំទាំងពីរខ្សែនេះនឹងដំណើរការសាងសង់នៅ ៥ ឆ្នាំទី ១

- ផ្លូវក្រាលគ្រួសក្រហម ០១ ខ្សែ មានប្រវែង ២.២៤០ ម៉ែត្រ ស្ថិតនៅភូមិជីមាល( ពីមុនជាផ្លូវលំដីស) ។
- ផ្លូវក្រាលគ្រួសក្រហម ០១ ខ្សែ មានប្រវែង ១.៧៦០ ម៉ែត្រ ស្ថិតនៅភូមិអណ្តូងទឹកចំណុចភូមិខ្មែរតស្លាម ( ពីមុនជាផ្លូវលំដីស) ។

**ទីតាំងនៃការដាក់លូកាត់ផ្លូវ**

តំរូវការក្នុងពេលអនាគតតំរូវឱ្យមានការសាងសង់លូឆ្លងផ្លូវ និងលូរំដោះទឹកចំនួន ០៤ កន្លែង ដែលក្នុងនោះមានទីតាំងនៅភូមិជីមាល ភូមិអណ្តូងទឹក ភូមិជីត្រេះ និងភូមិតាមាឃ គ្រោងសាងសង់នៅ ០៥ ឆ្នាំទី១ ។

**បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ផ្លូវថ្នល់**

ក្នុងលក្ខណៈបច្ចេកទេសនៃការសាងសង់ផ្លូវត្រូវបានកំណត់សំរាប់ផ្លូវដូចខាងក្រោម :

- ផ្លូវក្រាលគ្រួសក្រហមក្នុងក្របខ័ណ្ឌមូលដ្ឋានឃុំត្រូវទុកដីចំណីផ្លូវ ១៥ ម៉ែត្រសងខាង
- ការកំណត់លើការប្រើប្រាស់ផ្លូវត្រូវអនុលោមទៅតាមច្បាប់
- បង្កើតសហគមន៍ថែទាំផ្លូវដោយមានចូលរួមពីប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- ហាមការដឹកជញ្ជូនលើសទម្ងន់
- ហាមការយកគោ ក្របី ជ្រូក ចងលើផ្លូវ
- រៀបចំផ្លាកសញ្ញាចរាចរតាមបណ្តោយផ្លូវ

**៣.២.៣.៦. ការសាងសង់អគារសិក្សាលើទីតាំងសាលាចាស់ និង ទីតាំងសាលាថ្មី**

នៅក្នុងឃុំអណ្តូងទឹកដោយតំរូវការអគារសិក្សាសំរាប់សាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ និង វិទ្យាល័យ ត្រូវបានគ្រោងបង្កើតសាលា និងសាងសង់អគារបន្ថែមដែលក្នុងនោះ :

- បង្កើតសាលាមត្តេយ្យចំនួន ០១ អគារមាន ០៥ បន្ទប់ដែលស្ថិតនៅភូមិអណ្តូងទឹក ក្នុងទីតាំងសាលាបឋមចាស់ ការសាងសង់នឹងត្រូវអនុវត្តនៅ ០៥ ឆ្នាំ ទី១ ។
- សាលាបឋមសិក្សាស្ថិតក្នុងភូមិតាមាយត្រូវសាងសង់ ០១ អគារ មាន ០៣ បន្ទប់ ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ។
- សាលាបឋមសិក្សាស្ថិតក្នុងភូមិជីត្រេះត្រូវសាងសង់ ០១ អគារ មាន ០២ បន្ទប់ ស្ថិតនៅទីតាំងថ្មី ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ។
- សាលាបឋមសិក្សាស្ថិតក្នុងភូមិអណ្តូងទឹកត្រូវសាងសង់ ០១ អគារ មាន ០៥ បន្ទប់ ស្ថិតនៅទីតាំងសាលាបឋមចាស់ ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី៣ ។
- សាលាអនុវិទ្យាល័យស្ថិតក្នុងភូមិអណ្តូងទឹកត្រូវសាងសង់ ចំនួន ០១ អគារ មាន ០៥ បន្ទប់ ស្ថិតនៅទីតាំងសាលាចាស់ ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ។
- សាលាវិទ្យាល័យស្ថិតក្នុងភូមិអណ្តូងទឹកត្រូវសាងសង់ចំនួន ០២ អគារ មាន ១០ បន្ទប់ ស្ថិតនៅទីតាំងសាលាចាស់ ការសាងសង់នឹងត្រូវអនុវត្ត នៅ ០៥ ឆ្នាំ ទី២ ចំនួន ០១ អគារ និង ០៥ ឆ្នាំទី៣ចំនួន ០១ អគារ ។

**៣.២.៣.៧. ការប្រើប្រាស់ដីក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន**

ការប្រើប្រាស់ដីសំរាប់នាទីព្រៃលិចទឹក (ដីសារណៈរបស់រដ្ឋ) គឺត្រូវទាមទារឱ្យមានការថែរក្សាឱ្យបានគង់វង្ស ដូច្នេះឃុំមានគោលបំណងធ្វើការរៀបចំនូវផែនការក្នុងការការពារ ថែរក្សា អភិរក្ស និង អភិវឌ្ឍន៍ទៅលើធនធានទាំងនេះ ដើម្បីផ្តល់នូវផលប្រយោជន៍ក្នុងការបង្កើនប្រាក់ចំណូលសំរាប់ប្រជាពលរដ្ឋតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព ។

នៅក្នុងការប្រែប្រួលពីដីវាលស្មៅទៅជាដីដែលមានព្រៃលិចទឹកនោះ គឺជាអាទិភាពដោយសារដីប្រភេទវាលស្មៅដែលស្ថិតក្នុងនាទីព្រៃលិចទឹកគឺជាដីព្រៃលិចទឹកដែលបានឆេះកន្លងមកក្លាយជាវាលស្មៅ ដូច្នេះជាគោលការណ៍ត្រូវការពារថែរក្សាទុកឱ្យព្រៃលិចទឹកដុះឡើងវិញដើម្បីធានាធនធានធម្មជាតិក្នុងតំបន់ ។

នៅក្នុងដំណើរការនៃការការពារធនធានធម្មជាតិ និង បរិស្ថាននៅក្នុងឃុំអណ្តូងទឹកត្រូវបានអនុវត្ត និងកំណត់ទៅតាមក្របខ័ណ្ឌនៃការទទួលខុសត្រូវលើការគ្រប់គ្រងរបស់ស្ថាប័ននីមួយៗ ដូចជាតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែងមានផ្ទៃក្រឡា ៥៥៤,៤៤ ហិចតា ដែននេសាទរបស់សហគមន៍នេសាទទឹកសាបមានផ្ទៃក្រឡា ២០៦,៥០ ហិចតា និងដែននេសាទរបស់សហគមន៍នេសាទទឹកប្រៃមានផ្ទៃក្រឡា ៩.៨០៩ ហិចតា ។

នៅក្នុងសហគមន៍នីមួយត្រូវបានរៀបចំជាកន្លែងអភិរក្សត្រីមេពូជគ្រប់សហគមន៍ ហើយជាមួយគ្នានេះដែរឃុំនៅមាននាទីព្រៃលិចទឹកដែលជាជំរកដ៏ប្រសើរសំរាប់ធនធានជលផល ដូច្នេះដើម្បីធានានូវសុវត្ថិភាពស្បៀង និង និរន្តរភាពធនធានធម្មជាតិក្នុងតំបន់ ឃុំបានយកចិត្តទុកដាក់ចូលរួមការពារ និង ថែរក្សាឱ្យមានស្ថិរភាពយូរអង្វែង ។

នៅក្នុងការការពារប្រភពធនធានជលផលតាមរយៈសហគមន៍នេសាទបានដំណើរការរៀបចំលើគំរោងផែនការក្នុងការកំណត់ការការពារ និង ប្រើប្រាស់ដូចខាងក្រោម :

- កំណត់កន្លែងអភិរក្សត្រីមេពូជទឹកសាប ០១ កន្លែងស្ថិតនៅភូមិជីមាលគឺត្រពាំងពងទឹកដែលមានផ្ទៃក្រឡា ២០ ហិចតា និង មួយកន្លែងទៀតស្ថិតនៅភូមិជីត្រេះគឺអាងទឹកជីត្រេះដែលមានផ្ទៃក្រឡា ៤៥ ហិចតា ។
- កំណត់កន្លែងអភិរក្សព្រៃលិចទឹកតាមមាត់ព្រែក សមុទ្រ ត្រពាំង បឹង (ការពារថែរក្សាព្រៃលិចទឹក និងសត្វគ្រប់ប្រភេទ) ។
- រៀបចំដាំដើមកោងកាងនៅតំបន់វាលភក់មាត់ព្រែកតាអុក និង មាត់ព្រែកកន្ទួតស្ថិតក្នុងភូមិតាអុកដែលមានទំហំ ២០ ហិចតា ។

**បញ្ញត្តិ និង គោលការណ៍នៃការប្រើប្រាស់ធនធាន**

- នៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និង ប្រើប្រាស់ធនធានរបស់សហគមន៍នេសាទត្រូវបានរៀបចំគ្រប់គ្រង និងប្រើប្រាស់ទៅលើព្រៃលិចទឹកដែលក្នុងនោះត្រូវបានបែងចែក :
  - កំណត់ការដកយកផល និង អនុផលព្រៃលិចទឹក ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការគ្រប់គ្រងសហគមន៍នេសាទ ។
  - ហាមការចាប់សត្វព្រៃគ្រប់ប្រភេទនៅក្នុងកន្លែងព្រៃអភិរក្ស ។
  - ហាមការចាប់សត្វដែលច្បាប់ជលផលបានកំណត់ ។
  - ហាមកាប់អូសព្រៃលិចទឹកធ្វើអាជីវកម្ម ។
  - ហាមការកាប់រានដីព្រៃលិចទឹក ។
  - ហាមការធ្វើស្រែក្នុងបឹងត្រពាំង (ដីសាធារណៈរបស់រដ្ឋ) ។
  - ហាមការបូមពង្រីងបឹង ត្រពាំង ឬ ស្រះ ដើម្បីចាប់ត្រី (ដីសាធារណៈរបស់រដ្ឋ) ។
  - ហាមការដាំឈូកក្នុងបឹង ត្រពាំង ស្រះ (ដីសាធារណៈរបស់រដ្ឋ) ។

ឃុំអណ្តូងទឹក,ថ្ងៃទី....៧.....ខែឧសភា....ឆ្នាំ ២០១០......

**មេឃុំ**

ហ៊ី-តាន់

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូនឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋខេត្តកោះកុង

"ដើម្បីមេត្តាពិនិត្យ និង សំរេច"

បូទុមសាគរ,ថ្ងៃទី....៧......ខែ.ឧសភាឆ្នាំ 2010....

**អភិបាលនៃគណៈអភិបាលស្រុក**

**និង ប្រធានក្រុមការងារជីវរដ្ឋ**

**ស្រុកបូទុមសាគរ**

អុន-តារ៉ះ

១៧៣ [illegible] ០៩៩

**បានឃើញ និង ឯកភាព**

កោះកុង,ថ្ងៃទី..០៥....ខែឧសភា...ឆ្នាំ ២០១០

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋ**

**ខេត្តកោះកុង**

ប៊ុន លើក

# ឧបសម្ព័ន្ធ ១

# ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

- **ដីលំនៅដ្ឋានភូមិ**

**ដីភូមិលាយសួនដំណាំ :**

ដីភូមិលាយសួនដំណាំនៅក្នុងមូលដ្ឋានឃុំអណ្តូងទឹក គឺដីដែលស្ថិតនៅតាមដងផ្លូវដែលមានស្ថានភាពជាដីទីទួលខ្ពស់ និងដោយការចាក់បំពេញធ្វើជាភូមិដ្ឋាន ។ ជាមួយនេះផងដែរដីភូមិទាំងនេះត្រូវបានដាំនូវដំណាំរួមផ្សំនានាជាច្រើនដូចជា : ស្ពៃ ម្ទេស ននោង ត្រឡាច ល្ពៅ ស្លឹកគ្រៃ ចេក ដូង ដំឡូង ស្វាយ ល្មុត ខ្នុរ... ។ល។ ដីភូមិលាយសួនដំណាំភាគច្រើននៅជាប់គ្នាតាមបណ្តោយផ្លូវភូមិមានទំហំមិនលើសពី ២.១០០ ម$^{២}$ ។

តាមស្ថានភាពជាក់ស្តែង បើតាមការអង្កេតឃើញថាប្រជាពលរដ្ឋនៅក្នុងឃុំអណ្តូងទឹកក្រៅពីធ្វើស្រែ និងដាំដំណាំរួមផ្សំនៅមានសក្តានុពលជាច្រើនទៀតដូចជា ព្រៃកធំតូច និង សមុទ្រ ដែលអាចផ្តល់កន្លែងនេសាទត្រី ទឹកប្រៃ និង មានកន្លែងសំរាប់នេសាទត្រីទឹកសាបដូចជាអូរ និង ត្រពាំង ប៉ុន្តែជាក់ស្តែងនៅរដូវប្រាំងពុំសូវមានប្រជាពលរដ្ឋចូលរួមក្នុងការដាំដុះដំណាំឡើយ។ ឆ្លងតាមការសាកសួរព័ត៌មានបានឱ្យដឹងថាកត្តាទាំងនេះបណ្តាលមកពីនៅក្នុងរដូវប្រាំងប្រជាពលរដ្ឋនាំគ្នាធ្វើការនេសាទត្រីនៅតាមព្រៃក និងក្នុងសមុទ្រដើម្បីចិញ្ចឹមជីវិត ។

- **ដីភូមិលាយដីស្រែ**

ដីភូមិលាយដីស្រែ គឺជាដីភាគច្រើនជាដីភូមិដែលស្ថិតនៅដាច់ៗពីគ្នា ហើយនៅក្នុងរង្វង់ដីភូមិមានដីស្រែផ្នែកខាងក្រោយនៃដីភូមិ ចំពោះដីស្រែក្នុងភូមិគេច្រើនប្រើសំរាប់ធ្វើទីសំណាប ម្យ៉ាងវិញទៀតចំពោះអ្នកមានដីភូមិជាប់ផ្ទះមានទំហំទូលាយ ហើយមានស្រះទឹក ឬអូរដាំដំណាំធានានៅរដូវប្រាំង ដូចជាពោត សណ្តែក ត្រសក់ ននោង ត្រឡាច ស្ពៃ នៃថាវ ...។ល។ ស្រែដែលនៅក្នុងដីភូមិច្រើនមានទំហំតូច ហើយមានទំហំមិនលើសពី ០,២១ ហ.ត ភាគច្រើនស្ថិតនៅផ្នែកខាងក្រោយនៃដីភូមិ ។ ដីភូមិលាយស្រែច្រើនស្ថិតនៅដាច់ពីគេ ព្រោះជាដីភូមិដែលគ្រួសារបែកផ្ទះថ្មី ។ ដីស្រែក្នុងភូមិបច្ចុប្បន្នត្រូវបានប្រើប្រាស់ធ្វើជាទីសំណាប និងដាំដំណាំរយៈពេលខ្លី ដូចជា : ពោត សណ្តែក និងបន្លែគ្រប់ប្រភេទ ប៉ុន្តែនាថ្ងៃអនាគតដីនេះនឹងក្លាយជាដីភូមិដែលត្រូវឪពុកម្តាយចែកឱ្យកូន ។ ដូច្នេះតាមការពិនិត្យសក្តានុពលលើការប្រើប្រាស់ដីឃើញថាគ្មានតម្លាភាពទៅនឹងកំណើន និង សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឡើយ ។

- **ដីស្រែវស្សា**

**ដីស្រែវស្សា ( ស្រូវសន្ទូង)**

ដីស្រែវស្សានៅឃុំអណ្តូងទឹក ត្រូវបានប្រើប្រាស់ក្នុងការធ្វើស្រែវស្សា ការធ្វើស្រែវស្សារបស់ប្រជាជននៅក្នុងឃុំអណ្តូងទឹក ថ្វីត្បិតពឹងផ្អែកទៅលើទឹកភ្លៀង ប៉ុន្តែស្រែមួយចំនួនដែលស្ថិតនៅជិតប្រភពទឹកមានលក្ខណៈល្អប្រសើរដោយមានទឹកកូនអូរ ប្រឡាយដែលបំបែកចេញពីត្រពាំង អាចជួយផ្តល់ទឹកនៅពេលជួបគ្រោះរាំងស្ងួតរយៈពេលខ្លី ។ នៅក្នុងការថែទាំស្រូវ កសិករដែលមានដីស្រែស្ថិតនៅទីខ្ពស់ត្រូវបានប្រើប្រាស់ជីគីមី ដោយឡែកចំពោះស្រែជំរៅមិនសូវ

ប្រើជីគីមីឡើយ ព្រោះជាប្រភេទដីមានជីវជាតិស្រាប់ ដូច្នេះគេអាចប្រើជីធម្មជាតិរួមផ្សំ ។ ដីស្រែវស្សានៅឃុំអណ្តូងទឹក គេអាចធ្វើបានផលពី ១ ទៅ ១,៥ តោន ក្នុងមួយហិកតា ដោយប្រើប្រភេទស្រូវជាបីប្រភេទ ដូចជា សគ្រាមុំ តាកែវ ហៃរិន និងប្រភេទស្រូវលេខ ២ ដូចជា ចាបស ក្រចកជ្រូក គ្រាប់ក្រូច ទិន្នផលពី ១ តោន ទៅ ១,៥ តោន ។ ដីស្រែស្រូវវស្សានៅក្នុងឃុំអណ្តូងទឹកសរុបរួមមានចំនួន ៥៣៩,៦៥៨២ ហ.ត ។ ពេលវេលានៃការធ្វើស្រែវស្សារបស់ប្រជាជននៅក្នុងឃុំអណ្តូងទឹកមានរយៈពេល ៧ ខែ ពីខែ ៦ ដល់ខែ ១២ ដីស្រែវស្សាបច្ចុប្បន្នក៏នៅពុំទាន់បំរើបាននូវសេចក្តីត្រូវការប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយ ព្រោះវាមានបញ្ហាចោទលើការខ្វះទឹក ពិសេសការរាំងស្ងួតដែលជាកត្តាធ្វើឱ្យប្រជាជននៅឃុំអណ្តូងទឹកធ្វើស្រែមិនបានអស់ដីស្រែ ឬធ្វើហើយមានការស្វិតខូចមិនទទួលបាននូវទិន្នផល ។ ករណីនេះដោយសារការខ្វះប្រព័ន្ធធារាសាស្ត្រក្នុងការជួយសង្គ្រោះពេលខ្វះទឹកនៅក្នុងកូនរដូវប្រាំង ឬការរាំងស្ងួត ។

- **ដីស្រែប្រាំង**

ឃុំអណ្តូងទឹកមិនមានដីសំរាប់ធ្វើស្រែប្រាំង ពីព្រោះក្នុងឃុំពុំមានប្រព័ន្ធប្រឡាយគ្រប់គ្រាន់ក្នុងការស្រោចស្រព។ ហើយផ្ទៃដីស្រែវស្សានៅរដូវប្រាំងត្រូវបានប្រជាជនមួយចំនួនដាំដំណាំរួមផ្សំ ដូចជា : ពោត សណ្តែក ត្រសក់ ឪឡឹក ត្រកួន សំរាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃពិសេសដីស្រែនៅជិតភូមិ និងជាប់ប្រភពទឹក ។

ការធ្វើស្រែប្រាំងប្រជាជនឃុំអណ្តូងទឹកមិនមែនខ្ជិលមិនគិតគូរនោះទេ ព្រោះតែស្រែប្រាំងនៅក្នុងឃុំនេះមានបញ្ហាមួយចំនួនដូចជា : កង្វះខាតប្រព័ន្ធស្រោចស្រពទឹក ប្រឡាយមេ ហើយប្រភពទឹកព្រែក អូរ ភាគច្រើនប្រៃនៅរដូវប្រាំង ហើយមិនទាន់មានបច្ចេកទេសកសិកម្មសំរាប់តំរូវការរបស់ប្រជាជននៅឃុំនេះនៅឡើយ ។

- **ដីព្រៃលិចទឹក**

ដីព្រៃលិចទឹកនៅក្នុងឃុំអណ្តូងទឹក មានជាច្រើនកន្លែងដោយសារឃុំនេះសំបូរព្រែកតូច ធំជាច្រើនដែលបែកចេញពីសមុទ្រ និង ជាឃុំដែលប្រជាពលរដ្ឋភាគច្រើនរស់នៅតាមឆ្នេរសមុទ្រ និង ដងព្រែក ពីព្រោះប្រជាជនភាគច្រើនជាអ្នកនេសាទ ។ ប៉ុន្តែតំបន់ព្រៃលិចទឹកទាំងអស់ក្នុងឃុំអណ្តូងទឹក គឺជាដីសាធារណៈរបស់រដ្ឋគ្រប់គ្រង និង ការពារដោយក្រសួងបរិស្ថាន ។ ឃុំមានគំរោងស្នើសុំដីព្រៃលិចទឹកពីនាយកឧទ្យានជាតិបូទុមសាគរ មួយកន្លែង នៅភូមិតាមាយ ដើម្បីទុកជាតំបន់សហគមន៍នេសាទដែលមានការកំណត់ត្រឹមត្រូវក្នុងការទាញយកផល ។ ព្រៃលិចទឹកក្នុងឃុំអណ្តូងទឹក ជាទូទៅព្រៃលិចទឹកទឹកប្រៃ ។ បច្ចុប្បន្នព្រៃលិចទឹករងនូវការបំផ្លិចបំផ្លាញ គឺវាអាស្រ័យដោយកំរិតជីវភាពបង្ខំ និង ការខ្វះខាតដី ពិសេសនៅពេលដីឡើងថ្លៃពួកគាត់លក់អោយឈ្មួញអស់នៅពេលខ្វះដីពួកគាត់ត្រូវស្វែងរកដីថ្មីដើម្បីបង្កបង្កើនផលឃុំមានគោលការណ៍ដូចជា :

១- ផ្សព្វផ្សាយច្បាប់ឱ្យបានទូលំទូលាយ និង អនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់

២- ដាំកូនឈើលិចទឹកឡើងវិញដើម្បីផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងពីសារៈសំខាន់ព្រៃលិចទឹក ។

៣- កំណត់ព្រំប្រទល់ជាទីព្រៃលិចទឹក និង ដាក់បង្គោលព្រំប្រទល់ ឱ្យបានច្បាប់លាស់

៤- ការពារនូវការរំលោភធ្ងន់ធ្ងរចំពោះអ្នកប្រព្រឹត្តបទល្មើសក្នុងការកាប់ទន្រ្ទានចូលក្នុងនទីព្រៃលិចទឹក

- **ដីវាលស្មៅ**

ដីវាលស្មៅក្នុងឃុំអណ្តូងទឹក ភាគច្រើនស្ថិតក្នុងតំបន់ការពារដោយឧទ្យានជាតិបូទុមសាគរ (គឺជាដីសាធារណៈរបស់រដ្ឋ )ដីវាលស្មៅតំបន់នេះគឺជាកន្លែងសត្វព្រៃរកចាប់ចំណី ឬកន្លែងចំណីសត្វព្រៃដូចជា : ទន្សាយ ប្រើស ឈ្លូស ក្តាន់ និង សត្វជាច្រើនប្រភេទទៀត ។

ផ្អែកតាមបញ្ហាខាងលើ និង ស្ថានភាពជាក់ស្តែងឃុំមានគំរោងផ្សព្វផ្សាយច្បាប់ស្តីពីតំបន់ឧទ្យានជាតិបូទុមសាគរដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ទាំងនេះ ដើម្បីថែរក្សាដីវាលស្មៅទាំងនោះឱ្យមាននិរន្តរភាពសំរាប់សត្វព្រៃ។

- **ប្រភពទឹក**

ស្ថានភាពប្រភពទឹកក្នុងឃុំអណ្តូងទឹកគឺទឹក អូរ ត្រពាំង ស្រះ អណ្តូង លូ រីអណ្តូងស្នប់ ប្រភពទឹកទាំងនេះគឺជាទឹកសាប ដែលបានផ្តល់នូវសារៈប្រយោជន៍យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ដូចជាការផ្គត់ផ្គង់ដល់វិស័យកសិកម្មក្នុងនោះរួមមានជាប្រភពស្រោចស្រពផលដំណាំផ្តល់ការប្រើប្រាស់ផ្សេងៗរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។

ព្រែកតូចធំដែលបែកចេញពីសមុទ្រ និង សមុទ្រមានសារៈប្រយោជន៍សំខាន់ណាស់សំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននេសាទបានគ្រប់រដូវ ប៉ុន្តែការនេសាទនេះមានដែនកំណត់ច្បាស់លាស់ និង ជាច្បាប់របស់រដ្ឋបាលជលផល ។

- **ទឹកត្រពាំង**

ទឹកត្រពាំងនៅក្នុងឃុំអណ្តូងទឹក ស្ថិតនៅទីតាំងខុសៗគ្នាដូចជា : ត្រពាំងពងទឹក និង ត្រពាំងកូនសត្វ ស្ថិតនៅភូមិជីមាល ត្រពាំងស្វាយនៅភូមិប្រៃ ត្រពាំងព្រៃ នៅភូមិជីត្រេះ ប្រភពទឹកនៅត្រពាំងទាំងនេះមានសារៈប្រយោជន៍ណាស់សំរាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋាននៅរដូវប្រាំង ទឹកត្រពាំងទាំងនេះសំរាប់គោក្របីរបស់អ្នកភូមិ និងដាំដំណាំបន្លែដូចជា : ត្រសក់ ត្រកួន សណ្តែកគួរ ជីរ ស្ពៃ គ្រប់ប្រភេទ ។ល។

- **ព្រែក**

ឃុំអណ្តូងទឹកមានព្រែកទឹកព្រៃធំៗបី ដែលមានកូនព្រែកបែកចេញពីព្រែកធំជាច្រើន និង តំបន់ឆ្នេរសមុទ្រភូមិដែលជាប់ព្រែកទឹកប្រៃដូចជាភូមិអណ្តូងទឹក ជីមាល ជីត្រេះ តាអុក ភូមិដែលជាប់តំបន់ឆ្នេរសមុទ្រមានភូមិតាមាយ ភូមិប្រទាល និង ភូមិអណ្តូងទឹកនៅប៉ែកខាងកើតជាប់សមុទ្រ ។

ចំពោះស្ថានភាពនៃទឹកព្រែក និង សមុទ្រ នៅក្នុងមូលដ្ឋានឃុំត្រូវបានផ្តល់នូវផលប្រយោជន៍ និង លទ្ធភាពក្នុងការប្រើប្រាស់ដល់ប្រជាពលរដ្ឋទាំងក្នុង និងក្រៅឃុំដូចជា :

-ផ្តល់នូវផលត្រីក្នុងការប្រើប្រាស់ និង ធ្វើអាជីវកម្មដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ

-ផ្តល់នូវជំរកសំរាប់ការចតទូក និង ផ្ទះ ។

| ល.រ | ចំណាត់ថ្នាក់ប្រើប្រាស់ដីលំអិត | រូបភាពនៃការប្រើប្រាស់ដី |
|---|---|---|

| | | |
|---|---|---|
| 1 | Code : 1200<br>ដីលំនៅដ្ឋាន : ផ្ទះ-ទីសំណាប-ឈើហូបផ្លែ |  |
| 2 | Code : 1210<br>ភូមិនៅលើទឹក : |  |
| 3 | Code : 2110<br>ស្រូវវស្សា : ធ្វើស្រែវស្សា |  |
| 4 | Code : 3500<br>ព្រៃលិចទឹក : |  |
| 5 | Code : 4100<br>វាលស្មៅ : |  |

| | | |
|---|---|---|
| 6 | Code :<br>ព្រែក : |  |
| 7 | Code : 2200<br>ចំការដំណាំ : ដំណាំរយៈពេលខ្លី | <br><br><br> |

| | | |
|---|---|---|
| 8 | Code :2310<br>ចំការដំណាំ : ឈើហូបផ្លែ |  |
| 9 | Code :<br>ប្រភពទឹក: ស្រះ |  |
| 10 | Code :3400<br>ព្រៃដុះឡើងវិញ: |  |
| 11 | Code :6420<br>ព្រៃកាប់ឆ្ការ: |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និង កាន់កាប់ដីបច្ចុប្បន្ន (ផែនទី A-3)

| ល.រ | ចំណាត់ថ្នាក់នៃការគ្រប់គ្រង និងកាន់កាប់ដី | | ក្រឡាផ្ទៃ (ហិកតា) |
|---|---|---|---|
| | តាមច្បាប់អនុញ្ញាត និងតួនាទី | តាមចំណាត់ថ្នាក់ដីរដ្ឋ និង ដីឯកជន | |
| 1 | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងតំបន់ឧទ្យានជាតិបូទុមសាគរ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ដីលំនៅដ្ឋានភូមិ | ដីសាធារណៈរបស់រដ្ឋ | 98.31 |
| | ហេដ្ឋារចនាសម្ព័ន្ធ | ដីសាធារណៈរបស់រដ្ឋ | 1.51 |
| | ដីកប់ខ្មោច | ដីសាធារណៈរបស់រដ្ឋ | 19.73 |
| | ដីស្រែវស្សា | ដីសាធារណៈរបស់រដ្ឋ | 285.13 |
| | ដីស្រែជាមួយភូមិ | ដីសាធារណៈរបស់រដ្ឋ | 66.77 |
| | ដីស្រែក្នុងបឹង ឬ អូរ | ដីសាធារណៈរបស់រដ្ឋ | 24.46 |
| | ដីចំការដំណាំ | ដីសាធារណៈរបស់រដ្ឋ | 14.79 |
| | ដីចំការឈើហូបផ្លែ | ដីសាធារណៈរបស់រដ្ឋ | 62.38 |
| | ដីកសិកម្មពនេចរ | ដីសាធារណៈរបស់រដ្ឋ | 37.67 |
| | ដីព្រៃស្រោង | ដីសាធារណៈរបស់រដ្ឋ | 14,737.65 |
| | ដីព្រៃដុះតាមមាត់ទឹក | ដីសាធារណៈរបស់រដ្ឋ | 29.71 |
| | ដីព្រៃដុះឡើងវិញ | ដីសាធារណៈរបស់រដ្ឋ | 878.51 |
| | ដីព្រៃលិចទឹក | ដីសាធារណៈរបស់រដ្ឋ | 252.14 |
| | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | 2,001.77 |
| | ដីព្រៃកោងកាងស្តើង | ដីសាធារណៈរបស់រដ្ឋ | 178.24 |
| | ល្បាយដីព្រៃលាយដីចំការ | ដីសាធារណៈរបស់រដ្ឋ | 2,640.38 |

| | | | |
|---|---|---|---|
| | ដីវាលស្មៅ | ដីសាធារណៈរបស់រដ្ឋ | 1,059.3 |
| | ដីចំការបោះបង់ដុះស្មៅ | ដីសាធារណៈរបស់រដ្ឋ | 3.12 |
| | ដីវាលស្មៅលិចទឹក | ដីសាធារណៈរបស់រដ្ឋ | 222.44 |
| | ដីព្រៃកម្ពោត | ដីសាធារណៈរបស់រដ្ឋ | 679.96 |
| | ដីព្រៃកម្ពោតលាយដើមឈើធំមួយៗ | ដីសាធារណៈរបស់រដ្ឋ | 382.90 |
| | ដីបឹង | ដីសាធារណៈរបស់រដ្ឋ | 4.80 |
| | អាង ឬ ទំនប់ទឹក | ដីសាធារណៈរបស់រដ្ឋ | 8.79 |
| | ស្ទឹង ព្រែក ឬ អូរ | ដីសាធារណៈរបស់រដ្ឋ | 12.49 |
| 2 | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតក្នុងព្រំប្រទល់ដីសម្បទានតាឡាម | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ដីលំនៅដ្ឋាន | ដីសាធារណៈរបស់រដ្ឋ | 6.81 |
| | ដីស្រែជាមួយភូមិ | ដីសាធារណៈរបស់រដ្ឋ | 0.06 |
| | ដីចំការឈើហូបផ្លែ | ដីសាធារណៈរបស់រដ្ឋ | 11.97 |
| | ដីព្រៃលិចទឹក | ដីសាធារណៈរបស់រដ្ឋ | 56.00 |
| | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | 8.62 |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | 4.88 |
| | ដីព្រៃកាប់ឆ្ការ | ដីសាធារណៈរបស់រដ្ឋ | 21.82 |
| 3 | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងព្រំប្រទល់ដីព្រៃសម្បទានធីពានិជ្ជ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ដីលំនៅដ្ឋានភូមិ | ដីសាធារណៈរបស់រដ្ឋ | 8.43 |
| | ហេដ្ឋារចនាសម្ព័ន្ធ | ដីសាធារណៈរបស់រដ្ឋ | 0.64 |
| | ដីស្រែវស្សា | ដីសាធារណៈរបស់រដ្ឋ | 5.99 |
| | ដីចំការឈើហូបផ្លែ | ដីសាធារណៈរបស់រដ្ឋ | 5.60 |
| | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | 0.29 |
| | ល្បាយដីព្រៃលាយដីចំការ | ដីសាធារណៈរបស់រដ្ឋ | 1.90 |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | 18.48 |
| 4 | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ដីស្រែវស្សា | ដីសាធារណៈរបស់រដ្ឋ | 20.61 |
| | ដីស្រែក្នុងបឹង ឬ អូរ | ដីសាធារណៈរបស់រដ្ឋ | 3.00 |
| | ដីចំការដំណាំ | ដីសាធារណៈរបស់រដ្ឋ | 3.28 |
| | ដីចំការឈើហូបផ្លែ | ដីសាធារណៈរបស់រដ្ឋ | 14.54 |

| | | | |
|---|---|---|---|
| | ដីព្រៃលិចទឹក | ដីសាធារណៈរបស់រដ្ឋ | 35.11 |
| | ដីព្រៃកោងកាង | ដីសាធារណៈរបស់រដ្ឋ | 164.00 |
| | ដីព្រៃកោងកាងស្តើង | ដីសាធារណៈរបស់រដ្ឋ | 50.20 |
| | ដីល្បាយដីព្រៃលាយដីចំការ | ដីសាធារណៈរបស់រដ្ឋ | 21.74 |
| | ដីវាលស្មៅ | ដីសាធារណៈរបស់រដ្ឋ | 6.72 |
| | ស្ទឹង ព្រែក ឬ អូរ | ដីសាធារណៈរបស់រដ្ឋ | 1.46 |
| | សមុទ្រ | ដីសាធារណៈរបស់រដ្ឋ | 65.18 |
| | ដីព្រៃកាប់ឆ្ការ | ដីសាធារណៈរបស់រដ្ឋ | 3.28 |
| 5 | ការប្រើប្រាស់ដីបច្ចុប្បន្នដែលស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ចចំការអំពៅ | ដីសាធារណៈរបស់រដ្ឋ-ដីឯកជនរបស់រដ្ឋ | |
| | ដីកសិកម្មពនេចរ | ដីសាធារណៈរបស់រដ្ឋ | 93.55 |
| | ដីព្រៃស្រោង | ដីសាធារណៈរបស់រដ្ឋ | 1.56 |
| | ដីព្រៃដុះឡើងវិញ | ដីសាធារណៈរបស់រដ្ឋ | 0.93 |
| | ដីព្រៃកោងកាងស្តើង | ដីសាធារណៈរបស់រដ្ឋ | 3.50 |
| | ដីវាលស្មៅ | ដីសាធារណៈរបស់រដ្ឋ | 61.39 |
| | ដីព្រៃកម្ពោត | ដីសាធារណៈរបស់រដ្ឋ | 80.39 |

*( ប្រភព:ផ្នែក GIS នៃមន្ទីរ ដនសស ខេត្តកោះកុង)*

## ឧបសម្ព័ន្ធ ៣

## បញ្ហាពាក់ព័ន្ធការប្រើប្រាស់ដី(បញ្ហាមូលហេតុ ដំណោះស្រាយ)

| បញ្ហា | ទីតាំង | មូលហេតុ | ដំណោះស្រាយ |
|---|---|---|---|
| ១ | ២ | ៣ | ៤ |
| ផ្លូវខូចខាតគ្មានផ្លូវធ្វើដំណើរ (ពិបាកធ្វើដំណើរ និងដឹកបញ្ជូន | ភូមិជីមាល,អណ្តូងទឹក, ប្រៃ,តាអុក | ក-ការហូរច្រោះ | ក,១-សាងសង់ផ្លូវដីស<br>ក,២-ជួសជុលផ្លូវក្រាលគ្រួសក្រហម<br>ក,៣-សាងសង់និងជួសជុល លូ ស្ពាន |
| | | ខ-ឡានដឹកហួស ចំណុះ | ខ,១-ដាក់បង្គោលសុវត្ថិភាព<br>ខ,២-បង្កើតសហគមន៍ថែទាំផ្លូវ<br>ខ,៣-រៀបចំលក្ខន្តិកៈក្នុងការប្រើប្រាស់ផ្លូវ |
| | | គ-ចងគោក្របីលើ ផ្លូវ | គ,១-ហាមមិនអោយចងគោក្របីលើផ្លូវ<br>គ,២-រៀបចំផ្លូវសំរាប់គោក្របី និង រទេះ<br>គ,៣-មានវិធានការចំពោះអ្នកប្រព្រឹត្តខុស |
| ខ្វះទឹកស្អាតប្រើប្រាស់ | ៧ ភូមិ | ក-ខ្វះសំភារ: បរិក្ខាផ្តល់ទឹកស្អាត | ក,១-ជីកអណ្តូងស្នប់<br>ក,២-ជីកអណ្តូង លូ<br>ក,៣-ជីកអណ្តូងដៃ |
| | | ខ-ខ្វះប្រភពទឹក ស្អាត | ខ,១-ជីកស្រះទឹកស្អាត<br>ខ,២-ធ្វើអាងតំកល់ទឹក |
| ខ្វះទឹកស្រោចស្រព | ភូមិជីមាល, ជីត្រេះ និងភូមិប្រៃ | ក-ប្រភពទឹករាក | ក,១-សាងសង់ និងស្តារប្រឡាយមេ<br>ក,២- សាងសង់ និងស្តារប្រឡាយរង<br>ក,៣-ស្តារអាងស្តុកទឹក |

| | | | |
|---|---|---|---|
| | | ខ-បរិក្ខារប្រព័ន្ធ<br>ស្រោចស្រពមិនគ្រប់<br>គ្រាន់ និងខូចខាត | ខ,១-ថែទាំនិងជួសជុលទំនប់ស្ទាក់ទឹក<br>ខ,២-សាងសង់និងជួសជុលទ្វារទឹក<br>ខ,៣- សាងសង់និងជួសជុលលូកាត់ផ្លូវ |
| ដីស្រែចំការខ្វះជីជាតិ | ៧ ភូមិ | ក-ប្រើប្រាស់យូរ<br>អង្វែង និងប្រើជីគីមី | ក,១-ប្រើប្រាស់ជីធម្មជាតិ<br>ក,២-ធ្វើជីកំប៉ុស្តិ៍<br>ក,៣-ផ្សព្វផ្សាយបច្ចេកទេសប្រើប្រាស់ជីគីមី<br>ក,៤-បណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែ បង្កើនរដូវ<br>ក,៥-វគ្គបណ្តុះបណ្តាលអំពីការកែប្រែគុណ ភាពដី |
| | | ខ-បាត់បង់ព្រៃឈើ | ខ,១-ដាំឈើហូបផ្លែ<br>ខ,២-ដាំដំណាំគ្រប់មុខ |
| | | គ-គ្មានបច្ចេកទេស រៀបចំស្រែ | គ,១-ផ្សព្វផ្សាយបញ្ឈប់ការដុតព្រៃ និង ជញ្រ្ជាំង<br>គ,២-លើកភ្លឺស្រែ |
| ដីស្រែ | ភូមិប្រទាល,អណ្តូង,ជីត្រេះ,<br>ជីមាល,តាអុក,តាមាឃ | ខ្វះដីស្រែសំរាប់បង្ក បង្កើនផល | សុំជួយពង្រីកដីស្រែ |
| ត្រពាំងរាក់ | ភូមិជីមាល និងភូមិប្រៃ | ខ្វះទឹកគោក្របីផឹក | សុំជួយស្តារត្រពាំង |
| ស្នាក់ការភូមិ | ភូមិជីមាល និង អណ្តូងទឹក | អត់មានស្នាក់ការ | សុំសាងសង់ទីស្នាក់ការភូមិ |
| មណ្ឌលសុខភាព | ភូមិប្រទាល | ខ្វះមណ្ឌលសុខភាព | សុំផ្តល់មណ្ឌលសុខភាព១ ខ្នង |

# ឧបសម្ព័ន្ធ ៤

## ក្របខណ្ឌនៃការអភិវឌ្ឍន៍ និង ជំរើសនៃការប្រើប្រាស់ដីធ្លីអនាគត
## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និង យុទ្ធសាស្ត្រ(តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អទិភាព | លេខរៀង នៅលើផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចង់បានផ្លូវល្អ | -ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ ២០០៨-២០១២របស់ឃុំ អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ឆ្នាំ ២០០៨ - ២០១២ ធ្វើឱ្យប្រជាពលរដ្ឋធ្វើដំណើរបានស្រួល | កែលំអរផ្លូវលំ ជនបទ | -លើកផ្លូវលំដីស<br>-ក្រាលគ្រួសក្រហម<br>-ជួសជុលផ្លូវគ្រួស ក្រហម<br>-សំអាតផ្លូវទឹក<br>-ពង្រឹងគណៈកម្មការ ថែរក្សាផ្លូវលំ | FRD3-01, FRD3-02, FRD3-03, FRD3-04 |
| ចង់ឱ្យមានទឹកស្អាត ប្រើប្រាស់ | -ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ ២០០៨ -២០១២ របស់ឃុំ អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ធ្វើឱ្យប្រជាពលរដ្ឋ ប្រើប្រាស់ប្រកប ដោយអនាម័យ | -រៀបចំប្រព័ន្ធ ទឹកស្អាតតាមលំនៅដ្ឋាន | -ជីកអណ្តូងស្នប់<br>-ជីកអណ្តូងលូ<br>-ជីកអណ្តូងដៃ<br>-ជីកអណ្តូងទឹកស្អាត<br>-ធ្វើអាងតំកល់ទឹក<br>-ផ្តល់ពាងយក្ស<br>-ធុងចម្រោះ | |
| ចង់ឱ្យប្រជាពលរដ្ឋ ចេះថែរក្សា | -ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ ២០០៨ -២០១២ របស់ឃុំ | ឆ្នាំ ២០១២ ប្រជាពលរដ្ឋមាន | ថែរក្សាអនាម័យ | -បណ្តុះបណ្តាលឱ្យ ថែរក្សាសុខភាព និង អនាម័យ | |

| | | | | | |
|---|---|---|---|---|---|
| សុខភាព និង អនាម័យ | អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ការថែរក្សាសុខ ភាព និងអនាម័យ | | -សាងសង់បង្គន់តាម លំនៅដ្ឋាន<br>-ជីកស្រះទឹកស្អាត តាមភូមិ<br>-ផ្តល់ធុងចម្រោះ | |
| ចង់បានទឹកប្រើ ប្រាស់ ស្រោច ស្រពគ្រប់គ្រាន់ | -ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ ២០០៨ -២០១២របស់ឃុំ អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ធ្វើឱ្យមានទឹក ប្រើប្រាស់គ្រប់រដូវ | កែលំអរប្រព័ន្ធ ធារាសាស្ត្រ | -សាងសង់ និង ស្តារ ប្រឡាយឡើងវិញ<br>-ស្តារអាងស្តុកទឹក<br>-សាងសង់និងជួស ជុលទំនប់ស្ទាក់ទឹក និងទំនប់ទឹកប្រៃ<br>-សាងសង់ស្ពានកាត់ ព្រែក<br>-សាងសង់និងជួស ជុលលូកាត់ផ្លូវ<br>-សាងសង់ទ្វារទឹក | FDN57-01<br>FDN64-01<br>FDN71-01, FDN71-02<br>FDN70-01, FDN70-02, FDN70-03, FDN70-04 |
| ចងឱ្យកុមារបាន ចូល រៀន គ្រប់៧ឆ្នា | - ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ២០០៨ -២០១២ របស់ឃុំ អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ឆ្នាំ ២០០៨- ២០១២ឱ្យកុមារ បានចូលរៀន គ្រប់៧ឆ្នា | លើកកំពស់ ធនធានមនុស្ស | -សាងសង់សាលា មត្តេយ្យតាមភូមិ<br>-ជួសជុលអគារសិក្សា<br>-ផ្តល់សំភារៈសិក្សា ដល់សិស្សក្រីក្រ<br>-ពង្រឹងគណៈកម្មការ ទ្រទ្រង់សិស្ស | |
| ចង់ឱ្យប្រជាពល រដ្ឋ រស់នៅប្រកប ដោយសុខុមាល ភាព | -ផែនការអភិវឌ្ឍន៍ ឃុំ៥ឆ្នាំ២០០៨ -២០១២ របស់ឃុំ អណ្តូងទឹក ស្រុក បូទុមសាគរ ខេត្តកោះកុង ។ | ធ្វើឱ្យប្រសើរ ឡើងនូវដីដែល មានជាតិជូ | កែលំអរដីឱ្យ មានជីជាតិ | -បណ្តុះបណ្តាលការ ប្រើប្រាស់ជីធម្មជាតិ<br>-បណ្តុះបណ្តាលការ ធ្វើជីកំប៉ុស្តិ៍<br>-ផ្សព្វផ្សាយបច្ចេក ទេសប្រើប្រាស់ជីគីមី<br>-បណ្តុះបណ្តាលបច្ចេក ទេសធ្វើស្រែ បង្កើនរដូវ<br>-វគ្គបណ្តុះបណ្តាល បច្ចេកទេសដាំឈើ | |

| | | | | | |
|---|---|---|---|---|---|
| | | | | ហូប ផ្លែនិង ដាំដំណាំឆ្លាស់<br>-ផ្សព្វផ្សាយពីសារៈ ប្រយោជន៍ជញ្ជ្រាំង<br>-បណ្តុះបណ្តាលពី ការថែរក្សាជីវចំរុះ តាមវាលស្រែ | |
| ចងឱ្យប្រជាពលរដ្ឋ មានមុខរបរគ្រប់គ្នា | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ២០០៨ - ២០១២ របស់ឃុំ អណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង ។ | ឆ្នាំ២០០៨- ២០១២ប្រជាពលរដ្ឋក្នុងឃុំ មានត្រី សំបូរ និង ហូប គ្រប់គ្រាន់ | -ពង្រឹកការអនុ វត្តន៏ច្បាប់<br>-បង្កើនប្រាក់ ចំណូលក្នុងគ្រួ សារ<br>-កលំអរប្រព័ន្ធ ធារាសាស្រ្ត<br>-កែលំអរបរិ ស្ថានធម្មជាតិ | -បង្កើនការចិញ្ចឹមត្រី<br>-បណ្តុះបណ្តាលបច្ចេក ទេសចិញ្ចឹមត្រី<br>-ផ្តល់ពូជត្រីចិញ្ចឹមជា លក្ខណៈគ្រួសារ<br>-បន្តផ្សព្វផ្សាយច្បាប់ ជលផល<br>-ស្តារត្រពាំងឱ្យជ្រៅ<br>-ទប់ស្កាត់ការរំលោភ យកដីត្រពាំង<br>-រៀបកន្លែងអភិរក្ស ត្រីមេពូជ<br>-រៀបចំរោងយាម កន្លែងអភិរក្ស<br>-រៀបចំកន្លែងអភិរក្ស ព្រៃលិចទឹក | |

*( ប្រភព:ឯកសារផែនការអភិវឌ្ឍន៍ឃុំ២០០៨)*

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬ សកម្មភាពសំខាន់របស់ឃុំក្នុងរយៈពេល ១៥ ឆ្នាំ

| ល.រ | គំរោងឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លីរយៈពេល ១៥ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១ | ៥ឆ្នាំទី២ | ៥ឆ្នាំទី៣ | |
| ២.៦.១ | គំរោងផ្នែកហេដ្ឋារចនាសម្ព័ន្ធ | | | | | | |
| | ២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត | | | | | | |
| | ១.១. ផ្លូវ | | | | | | |
| | ១.១.១. ផ្លូវលំ | 5,714.00 | ម | 4,000 | 1,714.00 | | |
| | ១.២. ប្រព័ន្ធស្រោចស្រព | | | | | | |
| | ១.២.១. ស្តារប្រឡាយ | 9,333.00 | ម | 4,000.00 | 3,333.00 | 2,000.00 | |
| | ១.២.២. ស្តារត្រពាំង | 05 | កន្លែង | 05 | | | |
| | ១.២.៣. កសាងទំនប់ការពារទឹកប្រៃ | 9,333.00 | ម | 5,000.00 | 3,000.00 | 1,333.00 | |
| | ១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត | ចំនួន | កន្លែង | | | | |
| | ១.៣.១. ចំនួនស្ពានថ្ម | 02 | កន្លែង | 02 | | | |
| | ១.៣.២. ចំនួនស្ពានឈើ | | | | | | |
| | ១.៣.៣. ចំនួនទ្វារទឹក | 04 | កន្លែង | 02 | 02 | | |
| | ១.៣.៤. ចំនួនលូឆ្លងផ្លូវ | 04 | កន្លែង | 04 | | | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | ២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និង សេវាកម្មផ្សេងៗ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | 03 | ខ្នង | 03 | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | 01 | ខ្នង | 01 | | | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | 02 | ខ្នង | 00 | 01 | 01 | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | 03 | ខ្នង | 01 | 01 | 01 | |
| | ២.៦.១.២.៥. សាងសង់ស្នាក់ការសហគមន៏ នេសាទ | 01 | ខ្នង | 01 | | | |
| | ២.៦.១.៣. សុខភាព និងអនាម័យ | | | | | | |
| | ២.៦.១.៤. មណ្ឌលសុខភាព | | | | | | |
| | ២.៦.១.៥. ប៉ុស្តិ៍សុខភាព | | | | | | |
| | ២.៦.១.៦. ស្រះទឹកស្អាត | | | | | | |
| | ២.៦.១.៧. អណ្តូងទឹកស្អាត | 70 | អណ្តូង | 40 | 30 | | |
| | ២.៦.១.៨. កន្លែងចាក់សំរាម | | | | | | |
| | ២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់ | | | | | | |
| | ២.៦.១.៤.១. ប៉ុស្តិ៍នគរបាល | 01 | កន្លែង | 01 | | | |
| | ២.៦.១.៤.២. ទីតាំងផ្សារ | | | | | | |
| | ២.៦.១.៥. កន្លែងគោរពបូជា | | | | | | |
| | ២.៦.១.៥.១. កន្លែងសក្ការបូជា | | | | | | |
| | ២.៦.១.៥.២. វត្តអារាម | | | | | | |
| | ២.៦.១.៥.៣. សាលាឆទាន | | | | | | |
| ២.៦.២ | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | ២.៦.២.១.១. ដីឡូនេសាទ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.១.២. ដីសហគមន៍ព្រៃឈើ | 1,759.00 | ហ.ត | 662 | 597 | 500 | |
| | ២.៦.២.១.៣. សហគមន៍ចិញ្ចឹមឃុំ | 347 | ហ.ត | | 347 | | |
| | ២.៦.២.១.៤. ដីតំបន់អភិរក្សទេសចរណ៍ធម្មជាតិ | 1,396.00 | ហ.ត | 600 | 400 | 396 | លេខកូដក្បាលដី F6500-01,02 |
| | ២.៦.២.១.៥. ដីសម្បទានសង្គមកិច្ច | 604 | ហ.ត | 604 | | | ដីសម្បទានដែលមានលេខកូដ F6700-02 ទុកសំរាប់ប្រើប្រាស់ពង្រីកដីស្រែ ចំពោះដីដែលមានលេខកូដ F6700-01 ទុកសំរាប់ដីលំនៅដ្ឋានអនាគតផងដែរ |
| | ២.៦.២.១.៦. ពង្រីកដីស្រែ | 75 | ហ.ត | 75 | | | |
| | ២.៦.២.១.៧. ដាំដើមកោងកាង | 20 | ហ.ត | 20 | | | |
| | ២.៦.២.១.៨. បង្គន់អនាម័យ | 500 | បង្គន់ | 500 | | | |
| | ២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈ សហគមន៍ភូមិ ឃុំ | | | | | | |
| | ២.៦.២.២.១. ដីភូមិ | 68.04 | ហ.ត | 19.53 | 24.36 | 24.15 | ត្រូវបានបញ្ចូលទៅក្នុងដីសម្បទានសង្គមកិច្ចដែលមានលេខកូដក្បាលដី F6700-01 |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | | | | | | |
| | ២.៦.២.២.៣. ដីវាលស្រែ | | | | | | |
| | ២.៦.២.២.៤. ដីស្រោចស្រព | | | | | | |
| | ២.៦.២.២.៥. ដីចំការដំណាំរយៈពេលខ្លី | | | | | | |
| | ២.៦.២.២.៦. ដីចំការដំណាំឈើហូបផ្លែ | | | | | | |
| | ២.៦.២.២.៧. វារីអគ្គិសនី | 36 | ហ.ត | | | 36 | |
| | ២.៦.២.៣. គំរោងផ្នែកបង្កើតជំនាញ និង មុខរបរ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើ ស្រែបង្កើនរដូវ | | | | | | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាលអំពីការ ប្រើប្រាស់ជី | 07 | វគ្គ | 07 | | | |
| | ២.៦.២.៣.៣. វគ្គបណ្តុះបណ្តាលអំពីការ កែប្រែគុណភាពដី | 07 | វគ្គ | 07 | | | |

*( ប្រភព:ឯកសារព័ត៌មានស្តីពីស្ថានភាពឃុំ២០០៨)*